# ឃរាវាសធម៌

## វត្តនិគ្រោធវ័ន "គល់ទទឹង"


រៀបរៀងដោយ

ខ្ញុំព្រះករុណាអាត្មាភាព

មុនីកោសល្យ ឆៅ_ហៃឡុន



ព.ស. ២៥៥៣

៥០០០ឆ្នាំ

WWW.5000-YEARS.ORG



ឯកសារនេះបាន ទាញចេញពី គេហទំព័រ

www.5000-years.org

# ឃរាវាសធម៌

## វត្តនិគ្រោធវ័ន "គល់ទទឹង"

រៀបរៀងដោយ

ខ្ញុំព្រះករុណាអាត្មាភាព

**មុនីកោសល្យ នៅ-ហៃឡុន**

ព.ស. ២៥៥៣

ចែកជាធម្មទាន

# សេចក្តីបញ្ជាក់

ខ្ញុំបានរៀបចំបោះពុម្ពសៀវភៅឃរាវាសធម៌ ជាលើកទី ២ នេះ បានបញ្ចូលធម៌ ពុទ្ធជយមង្គល មង្គលសូត្រ និង បរាភវសូត្រ បន្ថែមទៀត ព្រមទាំងបានកែលំអ អក្ខរាវិរុទ្ធ ខ្លះទៀតផង ។

# អារម្ភកថា

សៀវភៅឈ្មោះ **ឃរាវាសធម៌** នេះ កើតឡើងដោយអាស្រ័យហេតុដូចខាងក្រោមនេះ ។

១- ខ្ញុំព្រះករុណាអាត្មាភាព បានសិក្សារៀនសូត្រតាមគម្ពីរព្រះត្រៃបិដក បានឃើញព្រះពុទ្ធដីកាពីរោះៗ របស់ព្រះមានព្រះភាគសម្មាសម្ពុទ្ធជាម្ចាស់ និងព្រះអរិយសាវ័ក អរិយសាវិកាទ្រង់ត្រាស់សម្ដែងដល់គ្រហស្ថ អ្នកនៅគ្រប់គ្រងផ្ទះ បានបដិបត្តិដើម្បីសេចក្ដីសុខ សេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ក្នុងលោកនេះ ក្នុងលោកខាងមុខ និងជាបច្ច័យដល់ការបាន រួចផុតចាកទុក្ខ ។

២-ដោយអំណាចនៃសេចក្ដីជ្រះថ្លា នឹងព្រះធម៌ដ៏ពីរោះៗ ទាំងនោះ ខ្ញុំក៏មានចិត្តចាប់ភ្លឹករលឹកឃើញ ចង់ដកស្រង់ចងក្រងជាសៀវភៅធម៌ ចែកជាធម្មទានដល់គ្រហស្ថ អ្នកគ្រប់គ្រងផ្ទះដែលមិនមានបិដករៀន ឱ្យបានសិក្សារៀនសូត្រ បដិបត្តិតាមរយៈសៀវភៅនេះ ។

៣-ដើម្បីជាឱកាស បានសន្សំបុណ្យកុសល ដល់ខ្ញុំព្រះករុណាផង ដល់លោកម្ចាស់ ញាតិញោម ពុទ្ធបរិស័ទដែលមានបំណង នឹងចូលរួមធ្វើសៀវភៅធម្មទាន ឱ្យបានសម្រេចទៅតាមកម្លាំងកាយ វាចា ចិត្ត កម្លាំងបញ្ញា និងទ្រព្យធនសន្សំយកជានិស្ស័យបានច្រើនអង្គ ច្រើនរូបទៀតផង ។

អាស្រ័យហេតុនេះហើយ ដែលញាំងឆន្ទៈឱ្យកើតឡើងដល់ខ្ញុំ ហើយក៏ព្យាយាមប្រមូលចងក្រងបានជាអត្ថបទធម៌ រួចហើយយក ទៅប្រគេនលោកម្ចាស់ **ធម្មបាលោ សាន-សប្បាយ** លោកម្ចាស់ **ខន្តិបញ្ញោ តូ-សុភាព** ជាលោកគ្រូសូត្រស្តាំ លោកគ្រូសូត្រឆ្វេង វត្តនិគ្រោធវ័ន "គល់ទទឹង" សូមលោកជួយជាយោបល់ និងសូម អនុញ្ញាតប្រើប្រាស់កុំព្យូទ័រសង្ឃ លោកម្ចាស់ទាំងពីរព្រះអង្គបាន ជួយពិនិត្យផ្ទៀងផ្ទាត់ និងជួយឧបត្ថម្ភរហូតបានសម្រេចជាស្ថាពរ ។

សូមជាបច្ច័យបុណ្យកុសល កើតមានដល់លោក ម្ចាស់ គ្រប់ព្រះអង្គ ញាតិញោម ពុទ្ធបរិសទ័ទាំងអស់ ដែលបានជួយ ឧបត្ថម្ភគាំទ្រ ដោយកម្លាំងកាយ វាចា ចិត្ត ទ្រព្យ ធន ដើម្បីឱ្យ បានសម្រេច ជាសៀវភៅធម្មទាននេះ ព្រមទាំងអ្នកសិក្សា បាន បរិបូរណ៏ដោយបញ្ញា សម្មាទិដ្ឋិ បានសេចក្តីសុខ ក្នុងលោកនេះ ក្នុងលោកខាងមុខ រហូតដល់សុខព្រះនិព្វានគ្រប់ៗ គ្នាទៅហោង ។

វត្តនិគ្រោធវ័ន"គល់ទទឹង"

ថ្ងៃ សុក្រ ១៥ កើត ខែ បឋមាសាឍ

នព្វស័ក ពុទ្ធសករាជ ២៥៥១

រៀបរៀងដោយ ខ្ញុំព្រះករុណាអាត្មាភាព

**មុនីកោសល្យ នៅ-ហៃឡុន**

# បញ្ជីមាតិកា

**មាតិកា  យរាវាសធម៌** ទំព័រ


អារម្ភកថា .. ... ... ... ... ... ... ... ... ក

បញ្ជីមាតិកា . ... ... ... ... ... ... ... ... គ

រតនត្តយបូជា .... ... ... ... ... ... ... ... ១

ពុទ្ធរតនប្បណាម . ... ... ... ... ... ... ... ២

ធម្មរតនប្បណាម ... ... ... ... ... ... ... ៧

សង្ឃរតនប្បណាម ... ... ... ... ... ... ... ១១

រតនប្បណាម .. ... ... ... ... ... ... ... ១៧

នមស្ការយ៉ាងសង្ខេប .. ... ... ... ... ... ... ២០

សុភមង្គលគាថា . ... ... ... ... ... ... ... ២៣

យោកប្បកោដីបាលី ប្រែជាពាក្យកាព្យ .. ... ... ២៥

នមស្ការដោយអធិដ្ឋាន ... ... ... ... ... ... ២៧

នមស្ការបូជនីយវត្ថុ ជាទីគោរព . ... ... ... ... ២៨

នមស្ការពុទ្ធបាទ .. ... ... ... ... ... ... ... ២៩

នមស្ការធាតុចេតិយ ... ... ... ... ... ... ... ៣០

នមស្ការចំពោះព្រះសម្ពុទ្ធ ២៨ ព្រះអង្គ ... ... ... ៣៧

## មាតិកា ឃរាវាសធម៌

ទំព័រ


សុខាយាចនគាថា ... ... ... ... ... ... ... ៤៣

រតនបីប្រការដ៏ប្រសើរក្នុងលោក . ... ... ... ... ៤៥

ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សំដែងអំពីសទ្ធា .. ៤៦

បុញ្ញភាគប្បដិបត្តិ . ... ... ... ... ... ... ... ៤៨

ឧបាសកនិទ្ទេស .. ... ... ... ... ... ... ... ៥៨

សីលនៃឧបាសក . ... ... ... ... ... ... ... ៥៩

អាជីវនៃឧបាសក . ... ... ... ... ... ... ... ៦០

វិបត្តិនៃឧបាសក . ... ... ... ... ... ... ... ៦១

សម្បត្តិនៃឧបាសក .. ... ... ... ... ... ... ៦៣

គុណនៃឧបាសក . ... ... ... ... ... ... ... ៦៤

វិធីសមាទាននិច្ចសីល . ... ... ... ... ... ... ៦៧

វិធីសមាទានឧបោសថសីល.. ... ... ... ... ... ... ៧៤

សមាទានសីល ១០ .. ... ... ... ... ... ... ៨៣

អធិប្បាយអានិសង្សសីលសង្ខេប . ... ... ... ... ៨៩

បែបអ្នករក្សាសីល ១០ .. ... ... ... ... ... ... ៩១

វិធីភាវនា មាន ៣ យ៉ាង ... ... ... ... ... ៩៣

**មាតិកា យរាវាសធម៌** ទំព័រ

បីតិ ៥ យ៉ាង ... ... ... ... ... ... ... ... ៩៣
អង្គនៃនិច្ចសីល .. ... ... ... ... ... ... ... ៩៤
អង្គនៃឧបោសថសីល . ... ... ... ... ... ... ៩៧
អង្គនៃទសសីល .. ... ... ... ... ... ... ... ៩៩
អកុសលកម្មបថ ១០ យ៉ាង .. ... ... ... ... ១០០
អង្គនៃអកុសលកម្មបថ ... ... ... ... ... ... ១០១
កុសលកម្មបថ ១០ យ៉ាង .. ... ... ... ... ១០៤
ធម៌ ៤០ យ៉ាង នាំសត្វទៅកាន់នរក ... ... ... ១០៦
ធម៌ ៤០ យ៉ាង នាំសត្វទៅកាន់ស្ថានសួគ៌ ... ... ១០៨
ទោសនៃបុគ្គលទ្រុស្តសីលនិងអានិសង្សនៃបុគ្គលមានសីល. ១១០
បដិបទាប្រព្រឹត្តទៅនៃបុគ្គលទ្រុស្តសីល និង
បុគ្គលមានសីល .. ... ... ... ... ... ១១៣
អានិសង្សសីល ៥ .. ... ... ... ... ... ... ១២០
ឧបោសថសូត្រ . ... ... ... ... ... ... ... ១២៣
ឯកុបោសថិកាថេរិយាបទាន ... ... ... ... ... ១៤៥
សិង្គាលកសូត្រ . ... ... ... ... ... ... ... ១៤៨

**មាតិកា យរាវាសធម៌** ទំព័រ

ភាសិតោវាទសង្ខេប . ... ... ... ... ... ... ១៨៣
បច្ឆិមពុទ្ធវចនៈ . ... ... ... ... ... ... ... ១៩៣
ពុទ្ធជយមង្គលគាថា . ... ... ... ... ... ... ១៩៦
មង្គលសូត្រ. ... ... ... ... ... ... ... ... ២០៣
បរាភវសូត្រ ... ... ... ... ... ... ... ... ២០៩
វិធីបវារណាបច្ច័យ ៤ ចំពោះភិក្ខុសង្ឃ . ... ... ២១៩
បត្តិទានគាថា (យំ កិញ្ចិ) ..... ... ... ... ... ២២០
បត្តិទានគាថា (យា ទេវតា) ... ... ... ... ... ២២២
ធម៌សម្រាប់សូធ្យផ្សាយមេត្តាទាំង ១០ ទិស . ... ២២៥

## អ្នកមានឧបការៈគុណ

១-លោកម្ចាស់ **ធម្មបាលោ សាន-សប្បាយ**

២-លោកម្ចាស់ **វជិរប្បញ្ញោ គួ-សុភាព**

៣-លោកម្ចាស់ **បគុណធម្មោ ឡឿ-វុទ្ធី**

៤-លោកម្ចាស់ **អគ្គវង្សោ ឆាយ-កន**

៥-លោកម្ចាស់ **អគ្គធីរោ គង់-សុមិត្ត**

## អ្នកជួយពិនិត្យ

១-លោកម្ចាស់ **សទ្ធម្មជោតិបាលោ អ៊ុន-សំអឿន**

២-លោកម្ចាស់ **ភទ្ទវំសោ សួរ-ស៊ីម**

៣-លោកម្ចាស់ **សីលប្បញ្ញោ ផៃ-សុផល្លី**

៤-លោកម្ចាស់ **វជិរញ្ញាណោ វង-តុន**

៥-លោកម្ចាស់ **សុចិណ្ណ ញ៉ឹប-យ័ន្ត**

៦-លោកម្ចាស់ **វីរិយបញ្ញោ នៅ-សុវណ្ណ**

៧-លោកម្ចាស់ **ចន្ទមង្គលោ នៅ-ពីឡុត**

៨-លោកម្ចាស់ **វណ្ណសម្បន្នោ អាន-វណ្ណះ**

៩- សាមណេរ **សង្ឃជោត្តកោ គីម-ចាន់ណាត**

១០-សាមណេរ **សាសនធរោ តុប-ចាន់នី** សាមណេរ **ស៊ិត-សូលីដា** និងសាមណេរ **បញ្ញាបរមោ សឿន-សាន**

១១-ឧបាសិកា **ហុង-ចេង** និងឧបាសិកា **ខៀវ-អៀម** ជាវេយ្យាវច្ចៈ

# រតនត្តយបូជា

ថ្វាយគ្រឿងសក្ការៈដល់ព្រះរតនត្រ័យ

**ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ**

**អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច**

**ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ**

ប្រែថា : ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាម្ចាស់ ដោយគ្រឿងសក្ការៈទាំងឡាយ មានទៀន និង ធូបជាដើមនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង ។

## ពុទ្ធរតនប្បណាម

### ថ្វាយបង្គំព្រះពុទ្ធរតនៈ

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

ប្រែថា វីកិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គឥតមានគ្រូអាចារ្យណា ប្រដៅព្រះអង្គឡើយ ។

(សូធ្យបាលី ៣ ចប់ , សម្រាយតែ ១ ចប់ក៏បាន)

**យោ សន្និសិន្នោ វរពោធិមូលេ**
**មារំ សសេនំ មហតឹ វិជេយ្យា [១]**
**សម្ពោធិមាគច្ឆិ អនន្តញាណោ**
**លោកុត្តមោ តំ បណមាមិ ពុទ្ធំ**

ប្រែថា ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចម្រើននូវព្រះអានាបានស្សតិកម្មដ្ឋាន លើរតនបល្ល័ង្កក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជព្រមទាំងសេនាដ៏ច្រើនហើយ

---

១ ដែលធ្លាប់សូធ្យមកថា " វិជ្ជយោ " តែបានពិនិត្យផ្ទៀងផ្ទាត់ទៅឃើញថា "វិជេយ្យា " ទើបត្រឹមត្រូវ ត្រូវប្រែដូច " វិជិត្វា " ឬ " វិជេត្វា "

ទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះ ដោយគោរព ។

( ក្រាបថ្វាយបង្គំម្តង )

នមស្ការព្រះសម្មាសម្ពុទ្ធ ដូចសេចក្តីខាងលើនេះ គឺនមស្ការដោយសង្ខេប មិនបានញែកកាលចេញជា ៣ ឡើយ, បើនមស្ការដោយពិស្តារវិញ ទើបញែកកាលចេញជា ៣ ដូចសេចក្តីខាងក្រោមនេះ ។

**យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា**
**បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា**

ប្រែថា ព្រះសម្មាសម្ពុទ្ធទាំងឡាយ អង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធនិព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយ អង្គឯណា ដែលនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុងភទ្រកប្បនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ គ្រប់កាលទាំងពួង ។

( ក្រាបថ្វាយបង្គំម្តង )

រួចហើយគប្បីតាំងចិត្តរឭកដល់ពុទ្ធគុណទាំង ១០ ព្រះនាម ដោយបង្អោនកាយវាចាថា :

**ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ**

ប្រែថា **ឥតិបិ សោ ភគវា អរហំ** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា **អរហំ** ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេស ព្រមទាំងវាសនា គឺកាយបយោគនិងវចីបយោគ, **សម្មាសម្ពុទ្ធោ** ទ្រង់ព្រះនាមថា **សម្មាសម្ពុទ្ធោ** ព្រោះព្រះអង្គ ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណា ប្រដៅព្រះអង្គឡើយ, **វិជ្ជាចរណសម្បន្នោ** ទ្រង់ព្រះនាមថា **វិជ្ជាចរណសម្បន្នោ** ព្រោះព្រះអង្គបរិបូរណ៍ ដោយវិជ្ជា ៣ និងវិជ្ជា ៨ និងចរណៈ ១៥, **សុគតោ** ទ្រង់ព្រះនាមថា **សុគតោ** ព្រោះព្រះអង្គ មានដំណើរល្អ យាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន, **លោកវិទូ** ទ្រង់ព្រះនាមថា **លោកវិទូ** ព្រោះព្រះអង្គជ្រាបច្បាស់ នូវ

ត្រៃលោក, **អនុត្តរោ** ទ្រង់ព្រះនាមថា **អនុត្តរោ** ព្រោះព្រះអង្គប្រសើរ ដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន, **បុរិសទម្មសារថិ** ទ្រង់ព្រះនាមថា **បុរិសទម្មសារថិ** ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលមានឧបនិស្ស័យ គួរនឹងទូន្មានបាន, **សត្ថា ទេវមនុស្សានំ** ទ្រង់ព្រះនាមថា **សត្ថា ទេវមនុស្សានំ** ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ, **ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញុាំងអ្នកដទៃឱ្យត្រាស់ដឹងផង, **ភគវា** ទ្រង់ព្រះនាមថា **ភគវា** ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

រឭកដល់ពុទ្ធគុណរួចហើយ គប្បីប្រកាសប្ដេជ្ញាខ្លួន
ដោយពាក្យសច្ចៈថា

**នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ**
**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ**

ប្រែថា **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹង ទីរឭកនៃខ្ញុំព្រះករុណា មិនមានឡើយ, **ពុទ្ធោ មេ សរណំ វរំ** មានតែ

ព្រះពុទ្ធជាម្ចាស់ ជាទីពឹង ទីរឭក ដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តី ជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

ស្តេជ្វាដូច្នេះហើយ គប្បីសូត្រសូមខមាទោសនឹងព្រះពុទ្ធជាម្ចាស់ថា

**ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ**
**ពុទ្ធេ យោ ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ**

ប្រែថា **ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវល្អងធូលី ព្រះបាទនៃព្រះសម្មាសម្ពុទ្ធ ដ៏ប្រសើរខ្ពង់ខ្ពស់ ដោយអវយវៈដ៏ឧត្តម គឺត្បូង, **ពុទ្ធេ យោ ខលិតោ ទោសោ** ទោសឯណាដែលខ្ញុំព្រះករុណា ធ្វើឱ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះពុទ្ធជាម្ចាស់ **ពុទ្ធោ ខមតុ តំ មមំ** សូមព្រះពុទ្ធជាម្ចាស់ អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។

(ក្រាបថ្វាយបង្គំម្តង)

## ធម្មរតនប្បណាម

ក្រាបថ្វាយបង្គំព្រះធម្មរតនៈ

**អដ្ឋង្គិកអរិយបថោ ជនានំ មោក្ខប្បវេសាយ**

**ឧជូ ច មគ្គោ ធម្មោ អយំ សន្តិករោ**

**បណីតោ និយ្យានិកោ តំ បនមាមិ ធម្មំ**

ប្រែថា ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ ៨ ប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញ៉ាំងជន ដែលប្រាថ្នានូវព្រះនិព្វាន ឱ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះជាធម៌ធ្វើឱ្យត្រជាក់ រម្ងាប់បង់នូវភ្លើងទុក្ខភ្លើងកិលេស ជាធម៌ដ៏ឧត្តម ជាគុណញ៉ាំងសត្វឱ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសទ្ធម្មនោះ ដោយគោរព ។

( ក្រាបថ្វាយបង្គំម្តង )

នមស្ការដល់ព្រះសទ្ធម្ម ដូចសេចក្តីខាងលើនេះ គឺនមស្ការដោយសង្ខេប មិនបានញែកកាលចេញជា ៣ ឡើយ បើនមស្ការដោយពិស្តារវិញ ទើបញែកកាលចេញជា ៣ ដូចសេចក្តីខាងក្រោមនេះ

**យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា**
**បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា ។**

ប្រែថា ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ នឹងមានមកក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធទ្រង់ប្រតិស្ឋានទុកក្នុងកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយនោះ គ្រប់កាលទាំងពួង ។

រួចហើយគប្បីតាំងចិត្តរឭកដល់ធម្មគុណ
ដោយបង្អោនកាយវាចាថា

**ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ**
**ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ**

ប្រែថា **ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ជាធម៌ គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយដោយល្អ ( **ធម្មោ** ព្រះនព្វលោកុត្តរធម៌មាន ៩ ប្រការ គឺមគ្គ ៤ ផល ៤ និព្វាន ១ ) **សន្ទិដ្ឋិកោ** ជាធម៌ គឺ ព្រះអរិយបុគ្គលទាំងពួង ដឹងពិតឃើញពិត ដោយបច្ចវេក្ខណញ្ញាណ គឺថានឹង

បាន ដឹងដោយស្តាប់ ដោយជឿបុគ្គលដទៃនោះៗ ក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង **អកាលិកោ** ជាធម៌ឱ្យនូវផល មិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផល ក៏កើតក្នុងលំដាប់គ្នា មិនបានយឺតយូរឡើយ, **ឯហិបស្សិកោ** ជាធម៌ គួរដល់ឯហិបស្សវិធី គឺថា បើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃ ឱ្យចូលមកមើលបាន, **ឱបនយិកោ** ជាធម៌ គឺព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃភាវនា, **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌ គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ ក្នុងចិត្តនៃខ្លួន ។

រឭកដល់ព្រះធម្មគុណដូច្នេះរួចហើយ

គប្បីប្រកាសប្តេជ្ញាខ្លួន ដោយពាក្យសច្ចៈថា

**នត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។**

ប្រែថា **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹង ទីរឭកនៃខ្ញុំព្រះករុណាមិនមានឡើយ **ធម្មោ មេ សរណំ វរំ** មានតែព្រះធម៌ជាម្ចាស់ ជាទីពឹង ទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន**

**សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

ប្តេជ្ញាខ្លួនដូច្នេះរួចហើយ
គប្បីសូធ្យសូមខមាទោសនឹងព្រះធម៌ជាម្ចាស់ថា

**ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ**[២] **វរំ**
**ធម្មេ យោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ**

ប្រែថា **ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរ មានពីរប្រការ គឺព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ដោយអវយវៈដ៏ឧត្តមគឺត្បូង **ធម្មេ យោ ខលិតោ ទោសោ** ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឱ្យភ្លាំងភ្លាត់ ហើយក្នុងព្រះធម៌ជាម្ចាស់ **ធម្មោ ខមតុ តំ មមំ** សូមព្រះធម៌ជាម្ចាស់ អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។

( ក្រាបថ្វាយបង្គំម្តង )

---

[២] ក្នុងសៀវភៅបោះពុម្ពអក្សរសីហឡៈ (អក្សរអ្នកលង្កាទ្វីប) ថា "តិវិធំ" សំដៅសេចក្តីចំពោះព្រះធម៌ ៣ យ៉ាង គឺ ព្រះបរិយត្តិធម៌, បដិបត្តិធម៌ និងបដិវេធធម៌ ។

## សង្ឃរតនប្បណាម

ថ្វាយបង្គំព្រះសង្ឃរតនៈ

**សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ**

**សន្តិន្ទ្រិយោ សព្វមលប្បហីនោ**

**គុណេហិនេកេហិ សមិទ្ធិបត្តោ**

**អនាសវោ តំ បនមាមិ សង្ឃំ**

ព្រះអរិយសង្ឃឯណាដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រិយរម្ងាប់ហើយ មានមន្ទិល គឺរាគាទិក្កិលេសទាំងពួងបន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយនូវកិរិយាសម្រេចដោយគុណទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌ មិនមាន គឺថា ជាព្រះខីណាស្រព ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះអរិយសង្ឃនោះ ដោយគោរព ។

( ក្រាបថ្វាយបង្គំម្តង )

នមស្ការដល់ព្រះអរិយសង្ឃ ដូចសេចក្តីខាងលើនេះ គឺនមស្ការដោយសង្ខេប មិនបានញែកកាលចេញជា ៣ ឡើយ បើនមស្ការដោយពិស្តារវិញ ទើបញែកកាលចេញ ជា ៣ ដូចសេចក្តីខាងក្រោមនេះ

**យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា**
**បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា ។**

ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផលកន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃ នឹងបានសម្រេចមគ្គ និងផលក្នុងកាលខាងមុខក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផលក្នុងកាលជាបច្ចុប្បន្ននេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសង្ឃទាំងឡាយនោះ គ្រប់កាលទាំងពួង ។

( ក្រាបថ្វាយបង្គំម្តង )

រួចហើយគប្បីតាំងចិត្តរឮកដល់សង្ឃគុណ
ដោយបង្អោនកាយវាចាថា

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស**

**ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ**

ប្រែថា **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិ តាមគន្លងព្រះនព្វលោកុត្តរធម៌, **ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃ ជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា, **ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិ ដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ពានក្សេមផុតចាកទុក្ខទាំងពួង , **សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺ ប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា , **យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំងឡាយមាន ៤ គូ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ និងសោតាបត្តិផល ជាគូ ១ សកទាគាមិមគ្គ និងសកទាគាមិផល ជាគូ ១ អនាគាមិមគ្គ

និងអនាគាមិផល ជាគូ ១ អរហត្តមគ្គ និងអរហត្តផល ជាគូ ១ , **អដ្ឋ បុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺ ព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១ , **ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនោះ ជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ, **អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា , **បាហុនេយ្យោ** លោកគួរទទួលនូវអាគន្តុកទាន គឺ ទានដែលបុគ្គលតាក់តែង ដើម្បីញាតិនិងមិត្តដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា , **ទក្ខិណេយ្យោ** លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្មនិង ផលនៃកម្មហើយបូជា , **អញ្ជលិករណីយោ** លោកគួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ , **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន ។

រព្ញកដល់សង្ឃគុណដូច្នេះ រួចហើយ
គប្បីប្រកាសប្ដេជ្ញាខ្លួន ដោយពាក្យសច្ចៈថា

**នត្ថិ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ វរំ**
**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។**

ប្រែថា **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹង ទីរព្ញកនៃខ្ញុំព្រះករុណាមិនមានឡើយ, **សង្ឃោ មេ សរណំ វរំ** មានតែព្រះសង្ឃជាម្ចាស់ ជាទីពឹងទីរព្ញកដ៏ប្រសើររបស់ខ្ញុំព្រះករុណា, **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្ដីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

ប្ដេជ្ញាខ្លួនដូច្នេះ រួចហើយ គប្បីសូធ្យ
សូមខមាទោសនឹងព្រះសង្ឃជាម្ចាស់ថា

**ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ**
**សង្ឃេ យោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ ។**

ប្រែថា **ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសង្ឃដ៏ប្រសើរ មានពីរប្រការ គឺសម្មតិសង្ឃ និងអរិយសង្ឃដោយអវយវៈដ៏ឧត្តម គឺត្បូង ,

**សង្ឃេ យោ ខលិតោ ទោសោ** ទោសឯណា ដែលខ្ញុំព្រះករុណាធ្វើឱ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះសង្ឃជាម្ចាស់, **សង្ឃោ ខមតុ តំ មមំ** សូមព្រះសង្ឃជាម្ចាស់ អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

( ក្រាបថ្វាយបង្គំម្តង )

វិធីនមស្ការថ្វាយបង្គំនូវព្រះរតនត្រ័យ មិនចំពោះកាល និងថ្វាយបង្គំនូវព្រះរតនត្រ័យ ក្នុងកាលទាំង ៣ និង សេចក្តីរឭកគុណព្រះរតនត្រ័យ និងពាក្យប្តេជ្ញាខ្លួនចំពោះព្រះរតនត្រ័យ និង ថ្វាយបង្គំសូមខមាទោស ចំពោះព្រះរតនត្រ័យទាំង ៥ ន័យ ដែលបានពោលមកហើយខាងដើមនោះ ក៏ចប់តែប៉ុណ្ណេះដោយពិស្តារ ។

អ្នកដែលមានសទ្ធា ប្រាថ្នានឹងនមស្ការដល់ព្រះរតនត្រ័យនោះ បើមានពេលឱកាសល្មមនឹងសូធ្យនមស្ការទាំង ៣ បទ ឱ្យបានចប់សព្វគ្រប់ ដោយសេចក្តីពិស្តារ ដូចបែបខាងដើមនោះ ក៏ជាការឧត្តមប្រពៃក្រៃពេក តែបើពេលខ្លីមិនអាចនឹងសូធ្យឱ្យចប់សព្វគ្រប់បាន ក៏គ្រាន់តែសូធ្យសេចក្តីរឭកពុទ្ធគុណ ធម្មគុណ សង្ឃគុណ និងថ្វាយបង្គំ ហើយនឹងសូធ្យថ្វាយសក្ការបូជាដោយសេចក្តីសង្ខេបខ្លីៗ ដូចន័យតទៅនេះ វិញក៏បាន ។

## រតនប្បណាម

បែបសង្ខេបព្រមទាំងបូជាគ្រឿងសក្ការៈ

**ឥតិបិ សោ ភគវា អរហំ ។ល។ ពុទ្ធោ ភគវាតិ តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ**

ប្រែថា **ឥតិបិ សោ ភគវា អរហំ** ព្រះដ៏មានព្រះភាគ អង្គនោះ ទ្រង់ព្រះនាមថា **អរហំ** ព្រោះព្រះអង្គ ឆ្ងាយចាកសឹកសត្រូវពោល គឺកិលេស ព្រមទាំងវាសនា គឺកាយបយោគ និងវចីបយោគ ។ល។ **ភគវា** ទ្រង់ព្រះនាមថា **ភគវា** ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ចាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។ **តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គប្រកបព្រមហើយ ដោយគុណ មានគុណថា **អរហំ** ជាដើមនោះ ដោយសិរសា គឺត្បូង, **តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណេះ ។

( ក្រាបថ្វាយបង្គំម្តង )

**ស្វាក្ខាតោ ភគវតា ធម្មោ ។ល។ វិញ្ញូហីតិ តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ**

ប្រែថា **ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ជាធម៌ គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយដោយល្អ ។ល។ **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌ គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។ **តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះធម៌ ជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណ មានគុណថា **ស្វាក្ខាតោ** ជាដើមនោះ ដោយសិរសា គឺត្បូង, **តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះធម៌ជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណេះ ។

( ក្រាបថ្វាយបង្គំម្តង )

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ ។ល។**

**អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ តំ**

**សុបដិបន្នាទិ-គុណសំយុត្តំ សង្ឃំ សិរសា នមាមិ**

**តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ**

ប្រែថា **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃ ជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយ ដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌ ។ល។ **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន , **តំ សុបដិបន្នាទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសង្ឃជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណ មានគុណថា **សុបដិបន្នោ** ជាដើមនោះ ដោយសិរសា គឺត្បូង , **តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះសង្ឃជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយមានប្រមាណប៉ុណ្ណេះ ។

( ក្រាបថ្វាយបង្គំម្តង )

## នមស្ការយ៉ាងសង្ខេប

**នមោ តស្សារហន្តស្ស  ភគវន្តស្ស តាទិនោ**
**សម្មា សាមំ ច ពុទ្ធស្ស  ធម្មេ ទិភដ្ឋវាទិនោ**

ប្រែថា **នមោ តស្សារហន្តស្ស ភគវន្តស្ស តាទិនោ** កិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគជាម្ចាស់នោះ ព្រះអង្គជាព្រះអរហន្តដ៏វិសេស ជាបុគ្គលមិនញាប់ញ័រដោយលោកធម៌ទាំង ៨ ឡើយ ,

**សម្មា សាមំ ច ពុទ្ធស្ស ធម្មេ ទិភដ្ឋវាទិនោ** ព្រះអង្គត្រាស់ដឹងនូវធម៌ គឺ បុគ្គលគប្បីដឹងដោយប្រពៃ ចំពោះព្រះអង្គពិត ហើយទ្រង់សម្តែងញែកចែកនូវធម៌ទាំងឡាយនោះ ដល់សព្វសត្វទាំងពួង ។

( ក្រាបថ្វាយបង្គំម្តង )

**នមោ តស្សេវ ធម្មស្ស  និយ្យានិកស្ស វដ្តតោ**
**បរេតា នវវីធស្ស  ស្វាក្ខាតស្សេវ សច្ចតោ**

ប្រែថា **នមោ តស្សេវ ធម្មស្ស និយ្យានិកស្ស វដ្តតោ** កិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះធម៌ជាម្ចាស់នោះ ជាធម៌មានគុណជាទីស្រោចស្រង់ នូវសត្វឱ្យ

ចេញចាកវដ្តសង្សារ , **បរេភទា នវវិធស្ស ស្វាក្ខាតស្សេវ សច្ចតោ** ជាធម៌ មានប្រភេទ ៩ ប្រការ មានសោតាបត្តិមគ្គជាដើម មានព្រះនិព្វានជាទីបំផុត ដែលព្រះសម្មាសម្ពុទ្ធ សម្តែងទុកមកហើយ ដោយប្រពៃមែនពិត ។

( ក្រាបថ្វាយបង្គំម្តង )

**នមោ អរិយសង្ឃស្ស សញ្ជិភូតស្ស សត្ថុនោ**
**កិលេសានុសយេ សព្វេ បហានប្បដិបត្តិយា**

ប្រែថា **នមោ អរិយសង្ឃស្ស សញ្ជិភូតស្ស សត្ថុនោ** កិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះអរិយសង្ឃជាម្ចាស់នោះ ជាព្រះសង្ឃកើតហើយក្នុងពួកសាវ័កនៃព្រះសាស្តា , **កិលេសានុសយេ សព្វេ បហានប្បដិបត្តិយា** ជាព្រះសង្ឃប្រតិបត្តិដើម្បីលះបង់នូវលាមកធម៌ទាំងឡាយ ទាំងពួងដែលជាធម៌ រមែងតែងផ្តេកផ្តួលទៅតាមកិលេស ជាគ្រឿងញ៉ាំងចិត្តសន្តាននៃសត្វទាំងពួងឱ្យសៅហ្មង ។

( ក្រាបថ្វាយបង្គំម្តង )

**វិសុទ្ធករុណាញាណំ ពុទ្ធំ សម្ពុទ្ធបូជិតំ**
**ធម្មំ សទ្ធម្មសម្ភូតំ វន្ទេ សង្ឃំ និរង្គណំ**

ប្រែថា ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គមានព្រះហឫទ័យករុណាដល់សត្វដទៃ គឺថាទ្រង់បៀតបៀននូវកងទុក្ខ ដែលមានក្នុងសន្ដាននៃសត្វដទៃដោយព្រះញាណ ពោលគឺព្រះអរហត្តមគ្គដ៏ម៉ត់ចត់ស្អាតចាកមន្ទិល គឺរាគាទិក្កិលេស សូមថ្វាយបង្គំនូវព្រះធម៌ជាម្ចាស់ គឺព្រះសម្ពុទ្ធបូជាហើយ គឺថា ព្រះអង្គសម្ដែងហើយ សូមថ្វាយបង្គំនូវព្រះសង្ឃជាម្ចាស់ ដែលកើតដោយអរិយជាតិ ព្រោះព្រះសទ្ធម្ម ជាអ្នកមិនមានដំណើរទៅកាន់ភាវៈទាប គឺកិលេសឡើយ ។

( ក្រាបថ្វាយបង្គំម្ដង )

**នមេ ពុទ្ធំ តិលោកគ្គំ ញេយ្យសាគរបារគុំ**
**ភវាភវករំ ធម្មំ គណញ្ច គុណសាគរំ ។**

ប្រែថា ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសម្ពុទ្ធជាម្ចាស់ ព្រះអង្គជាបុគ្គលប្រសើរលើសសត្វក្នុងត្រៃលោក ព្រះអង្គមានញាណគឺគុណសម្រាប់ដឹងនូវញេយ្យធម៌ទាំងពួង ដ៏ជ្រាលជ្រៅបីដូចជាសាគរធំ ព្រះអង្គមានដំណើរទៅ ដល់ហើយនូវត្រើយសាគរ គឺញាណនៃព្រះអង្គផង ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធម៌ជាម្ចាស់ គឺគុណសំរាប់ទ្រទ្រង់នូវសត្វទាំងឡាយ ដែល

ជាអ្នកប្រតិបត្តិដ៏សមគួរ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា ជាម្ចាស់មិនឱ្យធ្លាក់ចុះទៅក្នុងអបាយភូមិទាំងឡាយផង, **ភវាភវករំ** ជាគុណតែងធ្វើនូវកម្មភព គឺកុសលាកុសលចេតនា ២៩ មានកុសលចេតនាជាដើម និងឧបបត្តិភព គឺភពទាំង ៩ មានកាមភពជាដើម ដែលកើតអំពីបច្ច័យ គឺកម្មភពឱ្យវិនាសសាបសូន្យទៅផង ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះអរិយសង្ឃ លោកមានគុណដ៏ជ្រាលជ្រៅ បីដូចជាសាគរផង ។

( ក្រាបថ្វាយបង្គំម្ដង )

## សុភមង្គលគាថា

ពាក្យពោលប្រកាសសូមសេចក្ដីល្អ

និងសេចក្ដីចម្រើនគ្រប់យ៉ាង

**ហោតុ សព្វំ សុមង្គលំ រក្ខន្តុ សព្វទេវតា**

**សព្វពុទ្ធានុភាវេន សោត្ថិ ហោតុ និរន្តរំ**

ប្រែថា **ហោតុ សព្វំ សុមង្គលំ** សុមង្គល គឺសេចក្ដីចម្រើនដ៏ល្អគ្រប់យ៉ាង ចូរមានដល់ខ្ញុំ, **រក្ខន្តុ សព្វទេវតា** ទេវតាទាំងពួងទាំងឡាយ ចូររក្សានូវខ្ញុំ, **សព្វពុទ្ធានុភាវេន** ដោយអានុភាព

នៃព្រះពុទ្ធគ្រប់ព្រះអង្គ, **សោត្ថិ ហោតុ និរន្តរំ** សូមសិរីសួស្តីចូរមានដល់ខ្ញុំ ឱ្យបានគ្រប់ពេល កុំបីមានចន្លោះឡើយ ។

**ហោតុ សព្វំ សុមង្គលំ រក្ខន្តុ សព្វទេវតា**
**សព្វធម្មានុភាវេន សោត្ថិ ហោតុ និរន្តរំ**

ប្រែថា **ហោតុ សព្វំ សុមង្គលំ** សុមង្គល គឺសេចក្ដីចម្រើនដ៏ល្អគ្រប់យ៉ាង ចូរមានដល់ខ្ញុំ, **រក្ខន្តុ សព្វទេវតា** ទេវតាទាំងពួងទាំងឡាយ ចូររក្សានូវខ្ញុំ, **សព្វធម្មានុភាវេន** ដោយអានុភាពនៃព្រះធម៌ទាំងពួង, **សោត្ថិ ហោតុ និរន្តរំ** សូមសិរីសួស្តីចូរមានដល់ខ្ញុំ ឱ្យបានគ្រប់ពេល កុំបីមានចន្លោះឡើយ ។

**ហោតុ សព្វំ សុមង្គលំ រក្ខន្តុ សព្វទេវតា**
**សព្វសង្ឃានុភាវេន សោត្ថិ ហោតុ និរន្តរំ**

ប្រែថា **ហោតុ សព្វំ សុមង្គលំ** សុមង្គល គឺសេចក្ដីចម្រើនដ៏ល្អគ្រប់យ៉ាង ចូរមានដល់ខ្ញុំ, **រក្ខន្តុ សព្វទេវតា** ទេវតាទាំងពួងទាំងឡាយ ចូររក្សានូវខ្ញុំ, **សព្វសង្ឃានុភាវេន** ដោយអានុភាពនៃព្រះសង្ឃទាំងពួង, **សោត្ថិ ហោតុ និរន្តរំ** សូមសិរីសួស្តីចូរមានដល់ខ្ញុំ ឱ្យបានគ្រប់ពេល កុំបីមានចន្លោះឡើយ ។

ចប់ត្រៃប្រណាមដោយសង្ខេបតែប៉ុណ្ណេះ

## យោ កប្បកោដី

បាលីប្រែជាពាក្យកាព្យ

**យោ កប្បកោដីហិបិ អប្បមេយ្យំ**

**កាលំ ករោន្តោ អតិទុក្ករានិ ខេទំ**

**គតោ លោកហិតាយ នាថោ**

**នមោ មហាការុណិកស្ស តស្ស**

ព្រះពុទ្ធជាទីពឹង ជាពំនឹងសព្វសត្តា
ព្រះអង្គកាលប្រាថ្នា ធ្វើកសាងអស់កាលយូរ ។
រាប់ដោយកោដិកប្បា ច្រើនគណនាហួសគិតគូរ
បានត្រាស់ជាសព្វញ្ញូ ត្រាស់ជាគ្រូលើភពឋាន ។
ធ្វើកម្មជាកម្រ សត្តនិករត្រាប់ពុំបាន
តោកយ៉ាកលំបាកប្រាណ ព្រោះប្រយោជន៍ដល់សព្វសត្វ។
ខ្ញុំសូមឱនសិរសា ចិត្តប្រាថ្នាបង្គំថ្វាត់
ព្រះពុទ្ធករុណាសត្វ នោះជាទីពឹងសព្វកាល ។

**អសម្ពុធំ ពុទ្ធនិសេវិតំ យំ**

**ភវាភវំ គច្ឆតិ ជីវលោកោ**

**នមោ អវិជ្ជាទិកិលេសជាលំ**

**វិទ្ធំសិនោ ធម្មវរស្ស តស្ស**

សត្វតែងកើតស្លាប់បង់ ព្រោះចំណងកម្មជាគោល
ឱ្យវិលវល់អន្ទោល ក្នុងភពតូចនិងភពធំ ។
ហេតុតែមិនដឹងធម៌ ជាម្ចាស់ល្អស្អាតសុខុម
គឺព្រះពុទ្ធសេពសម ចិត្តខ្ញុំសូមនមស្ការ ។
នូវធម៌ប្រពៃពិត វិសេសសុទ្ធនោះឯងណា
កាត់បង់នូវអវិជ្ជា គឺបណ្ដាញកិលេសហើយ ។

**គុណេហិ យោ សីលសមាធិបញ្ញា**
**វិមុត្តិញ្ញាណប្បភុតីហិ យុត្តោ**
**ខេត្តញ្ជនានំ កុសលត្ថិកានំ**
**តមរិយសង្ឃំ សិរសា នមាមិ**

ព្រះសង្ឃអង្គសាវ័ក មានសំវរៈសទ្ធាទ្រង់
កបដោយគុណសីលត្រង់ និងសមាធិបញ្ញា ។
និងវិមុត្តិញ្ញាណ កិលេសគ្មានក្នុងអាត្មា
ជាបុញ្ញក្ខេត្តា ជនត្រូវការជាកុសល ។
ខ្ញុំសូមឱនសិរសី ដល់ព្រះអរិយបុគ្គល
ជាបុត្តព្រះទសពល ជាមង្គលដល់សព្វសត្វ ។

# នមស្ការដោយអធិដ្ឋាន

ឥច្ចេវមច្ចន្ត   នមស្សនេយ្យំ
នមស្សមានោ រតនត្តយំ យំ
បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ
តស្សានុភាវេន ហតន្តរាយោ

ខ្ញុំសូមនមស្ការ   លើកហត្ថាឱនសិរសី
បង្គំគុណទាំងបី   ខ្ពស់លើសលប់ត្រៃលោកា ។
សូមបុណ្យកងកុសល   ឱ្យបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា   ដូចជលសាធំទូលាយ ។
សូមឱ្យកំចាត់បង់   អពមង្គលទាំងឡាយ
ឱ្យចៀសចេញចាកឆ្ងាយ   ក្តីអន្តរាយកុំបីមាន ។
ដោយកម្លាំងអានុភាព   បុញ្ញលាភជាប្រធាន
កងបុញ្ញរាសីមាន   សូមបានក្សាន្តកុំមានមោះ ។
ដោយគុណនមស្ការ   ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ   ដាក់ដល់ឋាននិព្វានហោង ។

( ក្រាបថ្វាយបង្គំម្តង )

# នមស្ការបូជនីយវត្ថុ ជាទីគោរព

វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេសុ បតិដ្ឋិតំ
សារីរិកធាតុ មហាពោធឹ ពុទ្ធរូបំ សកលំ សទា ។

ប្រែថា: ខ្ញុំសូមថ្វាយបង្គំ ឆ្ពោះព្រះបរមចេតិយ
ព្រមទាំងព្រះសារី រិកធាតុនៃព្រះពុទ្ធ ។
និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត
លំឱនចិត្តបរិសុទ្ធ លើកកម្បង់អញ្ជលី ។
និងព្រះពុទ្ធរូប តំណាងអង្គព្រះមុនី
ដែលឋិតនៅគ្រប់ទី ឋាននានានោះទាំងអស់ ។
( ដោយតេជៈនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់
ដែលតែងតែរំលស់ រំដោះទុក្ខភ័យអន្តរាយ ។
សូមឱ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ
សត្រូវទោះជិតឆ្ងាយ សូមឱ្យក្លាយមកជាមិត្ត ។
សូមទាន់ព្រះអរី- យមេត្រេយ្យថ្ងៃវិសិដ្ឋ
សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង)។

# នមស្ការពុទ្ធបាទ

**វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ**

**តិលោកកេតុំ តិភវេកនាថំ**

**យោ លោកសេដ្ឋោ សកលំ កិលេសំ**

**ឆេត្វាន ពោធេសិ ជនំ អនន្តំ**

ប្រែថា ព្រះសម្មាសម្ពុទ្ធឯណា ព្រះអង្គប្រសើរក្នុងលោក ទ្រង់កាត់បង់នូវកិលេសទាំងអស់បានហើយ ញុំាងជនជាអនន្ត ឱ្យត្រាស់ដឹងហើយ ខ្ញុំសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គឆ្លងផុតអំពីច្រាំងនៃភពហើយ ព្រះអង្គជាទង់ជ័យនៃត្រៃលោក មានតែព្រះអង្គមួយជាទីពឹងនៃសព្វសត្វក្នុងត្រៃភព ។

**យំ នម្មទាយ នទិយា បុលិនេ ច តីរេ**

**យំ សច្ចពន្ធគិរិកេ សុមនាចលគ្គេ**

**យំ តត្ថ យោនកបុរេ មុនិនោ ច បាទំ**

**តំ បាទលញ្ឆនមហំ សិរសា នមាមិ**

ស្នាមព្រះបាទឯណា ( ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក ) លើផ្នូរខ្សាច់ទៀបឆ្នេរនៃស្ទឹងឈ្មោះនម្មទា ស្នាមព្រះបាទឯណា ( ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក ) លើភ្នំសច្ចពន្ធ

និងលើភ្នំសុមនកូដ ស្នាមព្រះបាទឯណា ( ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក ) ក្នុងយោនកបុរី ខ្ញុំសូមក្រាបថ្វាយបង្គំដោយត្បូងចំពោះទៅព្រះបាទ និង ស្នាមព្រះបាទទាំងនោះ នៃព្រះសក្យមុនី ។

**សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ យោនកបុរេ**
**នម្មទាយ នទិយា បញ្ចបាទវរំ ឋានំ អហំ វន្ទាមិ ទូរតោ**

ខ្ញុំសូមនមស្ការអំពីចម្ងាយ នូវឋានដែលមានព្រះបាទដ៏ប្រសើរ ៥ កន្លែង គឺឋានលើភ្នំសុវណ្ណមាលិកៈ ១ លើភ្នំសុវណ្ណបព៌ត ១ លើភ្នំសុមនកូដ ១ ក្នុងយោនកបុរី ១ ក្បែរស្ទឹងនម្មទា ១ ។

## នមស្ការធាតុចេតិយ

**មហាគោតមសម្ពុទ្ធោ កុសិនារាយ និព្វុតោ**
**ធាតុវិត្ថារកំ កត្វា តេសុ តេសុ វិសេសតោ**

ប្រែថា ព្រះគោតមបរមសម្ពុទ្ធដ៏ប្រសើរ ព្រះអង្គបរិនិព្វានហើយ ជិតក្រុងកុសិនារា ធ្វើនូវកិរិយាផ្សាយ ព្រះសារីរិកធាតុក្នុងទីទាំងឡាយនោះៗដោយផ្សេងៗគ្នា

**ឧណ្ហីសំ ចតស្សោ ទាឋា  អក្ខកា ទ្វេ ច សត្តមា**
**អសម្ភិន្នា វ តា សត្ត  សេសា ភិន្នា វ ធាតុយោ**

ព្រះសារីរិកធាតុទាំងឡាយនោះ ដែលមិនបែកចេញ មាន ៧ អង្គ គឺព្រះឧណ្ហីសធាតុ[៣] ១ ព្រះទាឋធាតុ[៤] ៤ ព្រះអក្ខកធាតុ[៥] ២ ព្រះសារីរិកធាតុដ៏សេសក្រៅពីនោះ សុទ្ធតែបែកចេញ ( ជាបំណែកតូចៗ )

**មហន្តា បញ្ច នាឡី ច  មជ្ឈិមា ច ឆ នាឡិយោ**
**ខុទ្ទកា បញ្ច នាឡី ច  សម្ភិន្នា តិវិធា មតា**

ព្រះបរមធាតុទាំងឡាយដែលបែកចេញ លោកពោលថា មាន ៣ យ៉ាង គឺព្រះធាតុខ្នាតធំ វាល់បានចំនួន ៥ នាឡិ ព្រះធាតុខ្នាតកណ្តាល វាល់បានចំនួន ៦ នាឡិ ព្រះធាតុខ្នាតតូច វាល់បានចំនួន ៥ នាឡិ ។

**មហន្តា ភិន្នមុគ្គា ច  មជ្ឈិមា ភិន្នតណ្ឌុលា**
**ខុទ្ទកា សាសបមត្តា  ឯវំ ធាតុប្បមាណិកា**

ព្រះបរមធាតុទាំងឡាយ មានប្រមាណយ៉ាងនេះ គឺ

---

៣. ឆ្អឹងថ្ងាស ។ ៤. ព្រះចង្កូមកែវ ។ ៥. ឆ្អឹងដងកាំបិត ។

ព្រះធាតុខ្នាតធំ មានទំហំប៉ុនកំណាត់គ្រាប់សណ្ដែកបាយ ព្រះធាតុខ្នាតកណ្ដាល មានទំហំប៉ុនកំណាត់គ្រាប់អង្ករ ព្រះធាតុខ្នាតតូច មានទំហំប៉ុនគ្រាប់ស្ពៃ ។

**មហន្តា សុវណ្ណវណ្ណា មជ្ឈិមា ផលិកប្បភា**
**ខុទ្ទកា ពកុលវណ្ណា តាមិ វន្ទាមិ ធាតុយោ**

ព្រះបរមធាតុទាំងឡាយ (មានពណ៌ផ្សេងគ្នាយ៉ាងនេះ) គឺព្រះធាតុខ្នាតធំ មានពណ៌ដូចមាស ព្រះធាតុខ្នាតកណ្ដាល មានពណ៌ដូចកែវផលិក ព្រះធាតុខ្នាតតូចមានពណ៌ដូចផ្កាផ្កុល ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះបរមធាតុទាំងឡាយនោះ ។

**ឯកោ ថូបោ រាជគ្គហេ ឯកោ វេសាលិយា អហុ**
**ឯកោ កបិលវត្ថុស្មឹ ឯកោ ច អលកប្បកេ**
**ឯកោ ច រាមគាមស្មឹ ឯកោ ច វេដ្ឋទីបកេ**
**ឯកោ បាវេយ្យកេ មល្លេ ឯកោ ច កុសិនារកេ**

ព្រះស្តូប ១ ប្រតិស្ឋាននៅក្នុងក្រុងរាជគ្រឹះ, ព្រះស្តូប ១ ប្រតិស្ឋាននៅក្នុងក្រុងវេសាលី, ព្រះស្តូប ១ ប្រតិស្ឋាននៅក្នុងក្រុងកបិលព័ស្តុ, ព្រះស្តូប ១ ប្រតិស្ឋាននៅក្នុងក្រុងអលកប្បកៈ,

ព្រះស្តូប ១ ប្រតិស្ឋាននៅរាមគ្រាម, ព្រះស្តូប ១ ប្រតិស្ឋាន នៅក្នុងក្រុងវេដ្ឋទីបកៈ, ព្រះស្តូប ១ ប្រតិស្ឋាន នៅក្នុងក្រុងបាវេយ្យកៈ ក្នុងមល្លរដ្ឋជនបទ, ព្រះស្តូប ១ ប្រតិស្ឋាននៅក្នុងក្រុងកុសិនារា ។

**ឯតេ សារីរិកា ថូបា ជម្ពូទីបេ បតិដ្ឋិតា**
**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ**

ព្រះស្តូប ( ទាំង ៨ ) នុ៎ះ ជាព្រះស្តូបបញ្ចុះព្រះបរមសារីរិកធាតុ ប្រតិស្ឋាននៅក្នុងជម្ពូទ្វីប ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះបរមធាតុទាំងឡាយ ( ក្នុងព្រះស្តូប ទាំង ៨ នោះ ) ដែលទេវតា និង មនុស្សទាំងឡាយ តែងបូជា ។

**ឯកា ទាឋា តិទសបុរេ ឯកា នាគបុរេ អហុ**
**ឯកា គន្ធារវិសយេ ឯកា សីហឡទីបកេ**

ព្រះទាឋធាតុអង្គ ១ ប្រតិស្ឋាននៅក្នុងឋានត្រៃត្រិង្ស ព្រះទាឋធាតុអង្គ ១ ប្រតិស្ឋាននៅក្នុងពិភពនាគ ព្រះទាឋធាតុអង្គ ១ ប្រតិស្ឋាននៅក្នុងគន្ធាររដ្ឋ ព្រះទាឋធាតុអង្គ ១ ប្រតិស្ឋាននៅក្នុងសីហឡទ្វីប ។

ឥមា ចតស្សោ ឋានេសុ សត្ថុ ទាឋា បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ

ព្រះទាឋធាតុទាំងឡាយនេះ របស់ព្រះបរមសាស្ដា ប្រតិស្ឋានទៅក្នុងទីទាំងឡាយ ៤ កន្លែង ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយដែលទេវតា និង មនុស្សទាំងឡាយតែងបូជា ។

ឧទ្ធំ ទក្ខិណទាឋា ច តាវតឹសេ បតិដ្ឋិតា
អធោ ទក្ខិណទាឋា ច សីហឡទីបេ បតិដ្ឋិតា
វាមទាឋា ច ឧទ្ធម្បិ គន្ធាររដ្ឋេ បតិដ្ឋិតា
វាមទាឋា ច អធោបិ នាគលោកេ បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ

ព្រះទាឋធាតុស្ដាំខាងលើ ប្រតិស្ឋានទៅក្នុងស្ថានតាវត្តិង្ស
ព្រះទាឋធាតុស្ដាំខាងក្រោម ប្រតិស្ឋានទៅក្នុងសីហឡទ្វីប
ព្រះទាឋធាតុឆ្វេងខាងលើ ប្រតិស្ឋានទៅក្នុងដែនគន្ធារៈ
ព្រះទាឋធាតុឆ្វេងខាងក្រោម ប្រតិស្ឋានទៅក្នុងពិភពនាគ
ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយដែលទេវតា និង មនុស្សទាំងឡាយតែងបូជា ។

**ព្រហ្មលោកេ ទុស្សធាតុ ទាឋមក្ខកធាតុយោ**
**សព្វេ ព្រហ្មាភិបូជេន្តិ ថូបំ ទ្វាទសយោជនំ**

ព្រះទុស្សធាតុ និងព្រះអក្ខកធាតុខាងឆ្វេង ប្រតិស្ឋាន នៅក្នុងព្រហ្មលោក ព្រហ្មទាំងឡាយទាំងអស់គ្នា តែងបូជា នូវព្រះស្តូបកម្ពស់ ១២ យោជន៍ ( ដែលបញ្ចុះនូវព្រះធាតុទាំង នោះ ) ។

**តាវតឹសម្ហិ ទេវានំ ចូឡាមណិម្ហិ កេសកំ**
**សព្វេ ទេវាភិបូជេន្តិ បសន្នា ពុទ្ធសាសនេ**
**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ**

ទេវតាទាំងឡាយទាំងពួង ដែលជាអ្នកជ្រះថ្លាក្នុងព្រះ ពុទ្ធសាសនា តែងបូជានូវព្រះកេសធាតុ ដែលប្រតិស្ឋាននៅក្នុង ចូឡាមណីចេតិយរបស់ទេវតាទាំងឡាយ ក្នុងឋានត្រៃត្រិង្ស ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះធាតុទាំងឡាយ ដែលទេវតា និងមនុស្សទាំងឡាយតែងបូជា ។

**ចត្តាឡីស សមា ទន្តា កេសា លោមា នខាបិ**
**ច ទេវា ហរន្តិ ឯកេកំ ចក្កវាឡបរម្បរា**
**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ**

ព្រះទន្តធាតុទាំងឡាយ ៤០ គត់ផង ព្រះកេសធាតុទាំងឡាយផង ព្រះលោមធាតុទាំងឡាយផង ព្រះនខធាតុទាំងឡាយផង ទេវតាទាំងឡាយនាំទៅនូវព្រះធាតុ ១ អង្គៗ កាន់ចក្រវាឡដទៃ និងដទៃ គឺព្រះធាតុ ១ អង្គៗ ក្នុងចក្រវាឡមួយៗ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយ ដែលទេវតា និងមនុស្សទាំងឡាយតែងបូជា ។

**អដ្ឋារស វេ្វ វស្សសតេ ធម្មាសោកោ គតោ អាហុ**
**ចតុរាសីតិសហស្សា ចេតិយា ច ការាបិតា**
**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ**

នាកាលព្រះពុទ្ធសករាជបាន ២១៨ ឆ្នាំ មានព្រះមហាក្សត្រមួយអង្គទ្រង់ព្រះនាម **ធម្មាសោក** ក្នុងកាលនោះ ព្រះអង្គបានកសាងព្រះចេតិយចំនួន ៨ ហ្មឺន ៤ ពាន់ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយ ( ក្នុងព្រះចេតិយទាំងនោះ ) ដែលទេវតា និង មនុស្សទាំងឡាយតែងបូជា ។

## នមស្ការចំពោះព្រះសម្ពុទ្ធ ២៨ ព្រះអង្គ

**នមោ មេ សព្វពុទ្ធានំ ឧប្បន្នានំ មហេសិនំ** ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ ចំពោះព្រះពុទ្ធជាម្ចាស់ គ្រប់ព្រះអង្គ ដែលបានត្រាស់រួចមកហើយ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ( ព្រះសម្ពុទ្ធទាំងនោះ គឺ )

**តណ្ហង្ករោ មហាវីរោ** ព្រះតណ្ហង្ករៈ ព្រះអង្គមានព្យាយាមធំ

**មេធង្ករោ មហាយសោ** ព្រះមេធង្ករៈ ព្រះអង្គមានយសធំ

**សរណង្ករោ លោកហិតោ** ព្រះសរណង្ករៈ ព្រះអង្គធ្វើឱ្យជាប្រយោជន៍ ដល់សត្វលោក

**ទីបង្ករោ ជុតិន្ធរោ** ព្រះទីបង្ករៈ ព្រះអង្គទ្រទ្រង់នូវបញ្ញាដ៏រុងរឿង

**កោណ្ឌញ្ញោ ជនបាមោក្ខោ** ព្រះកោណ្ឌញ្ញៈ ព្រះអង្គ ជាប្រធាននៃពពួកជន

**មង្គលោ បុរិសាសភោ** ព្រះមង្គលៈ ព្រះអង្គជាបុរសដ៏ប្រសើរ

**សុមនោ សុមនោ ធីរោ** ព្រះសុមនៈ ព្រះអង្គជាអ្នកប្រាជ្ញមានព្រះហឫទ័យដ៏ល្អ

**រេវតោ រតិវឌ្ឍនោ** ព្រះរេវតៈ ព្រះអង្គញាំងសេចក្តីត្រេក

អរឱ្យចម្រើន

**សោភិតោ គុណសម្បន្នោ** ព្រះសោភិតៈ ព្រះអង្គបរិបូរណ៍ដោយព្រះគុណ

**អនោមទស្សី ជនុត្តមោ** ព្រះអនោមទស្សី ព្រះអង្គឧត្តមជាងពពួកជន

**បទុមោ លោកបជ្ជោតោ** ព្រះមទុមៈ ព្រះអង្គញ៉ាំងលោកឱ្យភ្លឺស្វាង

**នារទោ វរសារថី** ព្រះនារទៈ ព្រះអង្គដូចជាសារថីដ៏ប្រសើរ

**បទុមុត្តរោ សត្តសារោ** ព្រះបទុមុត្តរៈ ព្រះអង្គជាខ្លឹមសារនៃពពួកសត្វ

**សុមេធោ អប្បដិបុគ្គលោ** ព្រះសុមេធៈ ព្រះអង្គរកបុគ្គលប្រៀបដូចគ្មាន

**សុជាតោ សព្វលោកគ្គោ** ព្រះសុជាតៈ ព្រះអង្គប្រសើរលើសជាងសត្វលោកទាំងពួង

**បិយទស្សី នរាសភោ** ព្រះបិយទស្សី ព្រះអង្គប្រសើរជាងនរជន

**អត្ថទស្សី ការុណិកោ** ព្រះអត្ថទស្សី ព្រះអង្គប្រកបដោយករុណា

**ធម្មទស្សី តមោនុទោ** ព្រះធម្មទស្សី ព្រះអង្គបន្ទោបង់នូវងងឹត

**សិទ្ធត្ថោ អសមោ លោកេ** ព្រះសិទ្ធត្ថៈ ព្រះអង្គឥតមានអ្នកណាស្មើ ក្នុងលោក

**តិស្សោ ច វទតំ វរោ** ព្រះតិស្សៈ ព្រះអង្គប្រសើរជាងអ្នកប្រាជ្ញខាងសម្ដីទាំងឡាយ

**ផុស្សោ ច វរទោ ពុទ្ធោ** ព្រះពុទ្ធទ្រង់ព្រះនាម ផុស្សៈ ព្រះអង្គប្រទាននូវធម៌ដ៏ប្រសើរ

**វិបស្សី ច អនូបមោ** ព្រះវិបស្សី ព្រះអង្គឥតមានអ្នកណាប្រៀបផ្ទឹមបានឡើយ

**សិខី សព្វហិតោ សត្ថា** ព្រះសិខី ព្រះអង្គជាគ្រូប្រៀនប្រដៅ ធ្វើឱ្យជាប្រយោជន៍ដល់សត្វទាំងពួង

**វេស្សភូ សុខទាយកោ** ព្រះវេស្សភូ ព្រះអង្គប្រទាននូវសេចក្ដីសុខ

**កកុសន្ធោ សត្ថវាហោ** ព្រះកកុសន្ធៈ ព្រះអង្គនាំសត្វចេញចាកផ្លូវឆ្ងាយដាច់ស្រយាល គឺកិលេស

**កោនាគមនោ រណញ្ជហោ** ព្រះកោនាគមនៈ ព្រះអង្គបំបាក់បង់នូវសត្រូវ គឺកិលេស

**កស្សបោ សិរិសម្បន្នោ** ព្រះកស្សបៈ ព្រះអង្គបរិបូរណ៍ដោយសិរី

**គោតមោ សក្យបុង្គវោ** ព្រះគោតមៈ ព្រះអង្គប្រសើរចម្បងជាងពួកសក្យរាជ

**ឯតេ ចញ្ញេ ច សម្ពុទ្ធា អនេកសតកោដិយោ** ព្រះសម្ពុទ្ធទាំងនុ៎ះផង ព្រះសម្ពុទ្ធទាំងឡាយអង្គឯទៀតផង ច្រើនជាងរយកោដិ

**សព្វេ ពុទ្ធា អសមសមា សព្វេ ពុទ្ធា មហិទ្ធិកា** ព្រះសម្ពុទ្ធទាំងឡាយ គ្រប់ព្រះអង្គនោះ សុទ្ធតែស្មើដោយព្រះពុទ្ធដូចគ្នា ឥតមានបុគ្គលណាមួយស្មើឡើយ ព្រះសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គនោះ សុទ្ធតែមានឫទ្ធិច្រើន

**សព្វេ ទសពលូបេតា វេសារជ្ជេហុបាគតា** ព្រះសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គនោះ សុទ្ធតែប្រកបដោយទសពលញ្ញាណ និងប្រកបដោយវេសារជ្ជញ្ញាណទាំងឡាយ

**សព្វេ តេ បដិជានន្តិ អាសភណ្ឋានមុត្តមំ** ព្រះសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គនោះ សុទ្ធតែត្រាស់ដឹងនូវធម៌ ជាទីតាំងដ៏ខ្ពង់ខ្ពស់ គឺព្រះសព្វញ្ញុតញ្ញាណដ៏ឧត្តម

**សីហនាទំ នទន្តេ តេ បរិសាសុ វិសារទា** ព្រះសម្ពុទ្ធទាំង

ឡាយនោះ ព្រះអង្គក្លៀវក្លា បន្លឺនូវសីហនាទ គឺព្រះសូរសំឡេងដ៏ប្រសើរ ក្នុងពពួកនៃបរិសទ្យ

**ព្រហ្មចក្កំ បវត្តេន្តិ លោកេ អប្បដិវត្តិយំ** ព្រះអង្គទ្រង់ត្រាស់សំដែងនូវព្រះធម៌ ដូចជាចក្រដ៏ប្រសើរ ដែលឥតមានអ្នកណាមួយឱ្យប្រព្រឹត្តទៅក្នុងលោកបានឡើយ

**ឧបេតា ពុទ្ធធម្មេហិ អដ្ឋារសហិ នាយកា** ព្រះអង្គប្រកបដោយពុទ្ធធម៌ទាំងឡាយ ១៨ ព្រះអង្គជានាយក ដឹកនាំសត្វចេញចាកសង្សារវដ្ដ

**ទ្វត្តឹសលក្ខណូបេតា សីត្យានុព្យញ្ជនាធរា** ព្រះអង្គប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ ព្រមទាំងទ្រទ្រង់ នូវអនុព្យញ្ជនៈ ៨០ គត់

**ព្យាមប្បភាយ សុប្បភា សព្វេ តេ មុនិកុញ្ជរា** ព្រះសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គនោះ សុទ្ធតែជាអ្នកប្រាជ្ញដ៏ប្រសើរ ទ្រង់មានរស្មីដ៏ល្អ ដោយរស្មីមានមណ្ឌលមួយព្យាម (ម្ខាង)

**ពុទ្ធា សព្វញ្ញុនោ ឯតេ សព្វេ ខីណាសវា ជិនា** ព្រះសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គនោះ សុទ្ធតែជាព្រះសព្វញ្ញូ អស់អាសវៈហើយ ឈ្នះហើយ (នូវបញ្ចពិធមារ)

**មហប្បភា មហាតេជា មហាបញ្ញា មហព្វលា** ព្រះអង្គមានរស្មីច្រើន មានតេជះច្រើន មានប្រាជ្ញាច្រើន មានកម្លាំងច្រើន

**មហាការុណិកា ធីរា សព្វេសានំ សុខាវហា** ព្រះអង្គជាអ្នកប្រាជ្ញ មានសេចក្ដីករុណាច្រើន នាំមកនូវសេចក្ដីសុខ ដើម្បីសព្វសត្វទាំងឡាយ

**ទីបា នាថា បតិដ្ឋា ច តាណា លេណា ច បាណិនំ** ព្រះអង្គជាទីពឹង ជាទីអាស្រ័យ ដូចជាកោះជាទីជ្រកកោន ជាទីពួនរបស់សត្វទាំងឡាយ

**គតី ពន្ធូ មហស្សាសា សរណា ច ហិតេសិនោ សទេវកស្ស លោកស្ស សព្វេ ឯតេ បរាយនា** ព្រះសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គនោះ ដូចជាផ្លូវ ជាផៅពង្ស ជាទីត្រេកអរច្រើន និងជាទីពឹងទីរឭក ព្រះអង្គស្វែងរកប្រយោជន៍ ជាទីប្រព្រឹត្តទៅខាងមុខ របស់សត្វលោក ព្រមទាំងទេវលោក

**តេសាហំ សិរសា បាទេ វន្ទាមិ បុរិសុត្តមេ** ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំដោយត្បូង ចំពោះព្រះបាទទាំងឡាយ នៃព្រះសម្ពុទ្ធទាំងនោះ

**វចសា មនសា ចេវ វន្ទាមេតេ តថាគតេ សយនេ អាសនេ ឋានេ គមនេ ចាបិ សព្វទា** ក្នុងឥរិយាបថដេកក្តី អង្គុយក្តី ឈរក្តី សូម្បីក្នុងឥរិយាបថដើរក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ ដោយវាចា និងចិត្ត សព្វ ៗ កាល ចំពោះព្រះតថាគតទាំងឡាយនោះ

**សទា សុខេន រក្ខន្តុ ពុទ្ធា សន្តិករា តុវំ** ព្រះសម្ពុទ្ធទាំងឡាយ ព្រះអង្គជាអ្នកធ្វើនូវសេចក្តីរម្ងាប់ សូមរក្សានូវអ្នកដោយសេចក្តីសុខសព្វ ៗ កាល ។

## សុខាយាចនគាថា

**សុខោ ពុទ្ធានមុប្បាទោ** កិរិយាកើតឡើងនៃព្រះពុទ្ធ គ្រប់ព្រះអង្គនាំមកនូវសេចក្តីសុខ **សុខា សទ្ធម្មទេសនា** កិរិយាសម្តែងនូវព្រះសទ្ធម្មគឺព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ នាំមកនូវសេចក្តីសុខ **សុខា សង្ឃស្ស សាមគ្គី** កិរិយាព្រមព្រៀងគ្នានៃព្រះសង្ឃនាំមកនូវសេចក្តីសុខ **សមគ្គានំ តបោ សុខោ** តបៈគុណនៃព្រះសង្ឃទាំងឡាយ អ្នកព្រមព្រៀងគ្នា នាំមកនូវ

សេចក្តីសុខ **ទិវា តបតិ អាទិច្ចោ** ព្រះអាទិត្យរុងរឿងបានតែក្នុងវេលាថ្ងៃ **រត្តិមា ភាតិ ចន្ទិមា** ព្រះចន្ទរុងរឿងបានតែក្នុងវេលាយប់ **សន្នទ្ធោ ខត្តិយោ តបតិ** ព្រះមហាក្សត្រលុះតែទ្រង់គ្រឿងប្រដាប់សំរាប់រាជ្យ ទើបរុងរឿងបាន **ឈាយី តបតិ ព្រាហ្មណោ** ព្រាហ្មណ៍លុះតែចម្រើននូវឈាន ទើបរុងរឿងបាន **អថ សព្វមហោរត្តឹ ពុទ្ធោ តបតិ តេជសា** ឯព្រះពុទ្ធជាម្ចាស់ ទ្រង់រុងរឿងដោយតេជះទាំងថ្ងៃទាំងយប់ **ឯតេន សច្ចវជ្ជេន** ដោយភាសិតសច្ចវាចានេះ **សុវត្ថិ ហោន្តុ សព្វទា** សូមសិរីសួស្តី ចូរមានសព្វកាល ។

**ហិរិឱត្តប្បសម្បន្នា សុក្កធម្មសមាហិតា**
**សន្តោ សប្បុរិសា លោកេ ទេវធម្មាតិ វុច្ចរេ**

សប្បុរសទាំងឡាយ មានចិត្តស្ងប់រម្ងាប់ប្រកបព្រមហើយដោយហិរិ និង ឱត្តប្បៈ ព្រមទាំងមានចិត្តចុះស៊ប់ដោយធម៌មានពណ៌ស ( គឺសុចរិតធម៌ ) អ្នកប្រាជ្ញទាំងឡាយ លោកឱ្យនាមថា អ្នកមានទេវធម៌ក្នុងលោក ។

# រតនបីប្រការដ៏ប្រសើរក្នុងលោក

**យំកិញ្ចិ រតនំ លោកេ  វិជ្ជតិ វិវិធំ បុថុ រតនំ**

**ពុទ្ធសមំ នត្ថិ តស្មា  សោត្ថី ភវន្តុ តេ ។**

រតនៈឯណាមួយក្នុងលោក មានច្រើនបែបច្រើនយ៉ាង ( រតនៈទាំងនោះ ) ពុំស្មើនឹងព្រះពុទ្ធរតនៈឡើយ ព្រោះហេតុនោះ សូមសិរីសួស្តីទាំងឡាយកើតមានដល់អ្នក ។

**យំកិញ្ចិ រតនំ លោកេ  វិជ្ជតិ វិវិធំ បុថុ រតនំ**

**ធម្មសមំ នត្ថិ តស្មា  សោត្ថី ភវន្តុ តេ ។**

រតនៈឯណាមួយក្នុងលោក មានច្រើនបែបច្រើនយ៉ាង ( រតនៈទាំងនោះ ) ពុំស្មើនឹងព្រះធម្មរតនៈឡើយ ព្រោះហេតុនោះ សូមសិរីសួស្តីទាំងឡាយកើតមានដល់អ្នក ។

**យំកិញ្ចិ រតនំ លោកេ  វិជ្ជតិ វិវិធំ បុថុ រតនំ**

**សង្ឃសមំ នត្ថិ តស្មា  សោត្ថី ភវន្តុ តេ ។**

រតនៈឯណាមួយក្នុងលោក មានច្រើនបែបច្រើនយ៉ាង ( រតនៈទាំងនោះ ) ពុំស្មើនឹងព្រះសង្ឃរតនៈឡើយ ព្រោះហេតុនោះ សូមសិរីសួស្តីទាំងឡាយកើតមានដល់អ្នក ។

## ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សម្ដែងអំពីសទ្ធា

ម្នាលភិក្ខុទាំងឡាយ កុលបុត្រក្នុងសាសនានេះ មានសទ្ធា ទើបចូលទៅរក កាលបើចូលទៅរកហើយ ទើបចូលទៅអង្គុយជិត លុះចូលទៅអង្គុយជិតហើយ ទើបផ្ទៀងនូវសោតបសាទ លុះផ្ទៀងនូវសោតបសាទហើយ ទើបស្ដាប់ធម៌ លុះស្ដាប់ធម៌ហើយ ទើបចងចាំធម៌ (នោះ) កាលបើចងចាំធម៌ (នោះ) ហើយ ទើបពិចារណារកសេចក្ដី លុះពិចារណារកសេចក្ដីនៃធម៌នោះហើយ ធម៌ទាំងឡាយ តែងគួរដល់កិរិយាលៃលកមើល កាលបើមានការលៃលកមើលហើយ ឆន្ទះក៏កើតឡើង បុគ្គលនោះលុះមានឆន្ទះកើតហើយ ទើបព្យាយាម លុះព្យាយាមហើយ រមែងស្ទង់មើល លុះស្ទង់មើលហើយ រមែងតម្កល់ទុក មានចិត្តបញ្ជូនទៅ (កាន់ព្រះនិព្វាន) ធ្វើឱ្យជាក់ច្បាស់នូវបរមសច្ច ដោយនាមកាយ ទាំងបានចាក់ធ្លុះ ឃើញច្បាស់នូវបរមសច្ចនោះដោយប្រាជ្ញា ។

ម្នាលភិក្ខុទាំងឡាយ បើសទ្ធានោះមិនមានហើយ ម្នាលភិក្ខុទាំងឡាយ ការចូលទៅរកនោះ ក៏មិនមាន ម្នាលភិក្ខុទាំង

ឡាយ ការចូលទៅអង្គុយជិតនោះក៏មិនមាន ម្នាលភិក្ខុទាំងឡាយ ការផ្ទៀងចុះនូវសោតបសាទនោះក៏មិនមាន ម្នាលភិក្ខុទាំងឡាយ ការស្តាប់ធម៌នោះក៏មិនមាន ម្នាលភិក្ខុទាំងឡាយ ការចងចាំធម៌នោះក៏មិនមាន ម្នាលភិក្ខុទាំងឡាយ ការពិចារណាសេចក្តីនោះក៏មិនមាន ម្នាលភិក្ខុទាំងឡាយ ការសំឡឹងនូវធម៌នោះក៏មិនមាន ម្នាលភិក្ខុទាំងឡាយ ឆន្ទៈនោះក៏មិនមាន ម្នាលភិក្ខុទាំងឡាយ សេចក្តីព្យាយាមនោះក៏មិនមាន ម្នាលភិក្ខុទាំងឡាយ សេចក្តីស្ទង់មើលនោះក៏មិនមាន ម្នាលភិក្ខុទាំងឡាយ សេចក្តីតម្កល់ទុកនោះក៏មិនមាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមុខតែនឹងដល់នូវវិបត្តិ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ មុខតែនឹងប្រតិបត្តិខុសពុំខាន ម្នាលភិក្ខុទាំងឡាយ មោឃបុរសអម្បាលនេះ នឹងឃ្លាតចាកធម្មវិន័យនេះ ឆ្ងាយអម្បាលម៉ានទៅ ។

បិដក លេខ ២៣ ទំព័រ ៤០២

# បុព្វភាគប្បដិបត្តិ

បុរសស្ត្រីដែលមានសទ្ធាជ្រះថ្លា ក្នុងគុណព្រះរតនត្រ័យ គឺគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ហើយមានប្រាថ្នានឹងប្ដេជ្ញាខ្លួនជាឧបាសក ឬ ជាឧបាសិកា ជាបុព្វភាគបដិបត្តិ គឺសេចក្ដីប្រតិបត្តិជាចំណែកខាងដើម ឱ្យបានពេញស័ប់ជាអ្នកកាន់ព្រះពុទ្ធសាសនា ឬជាអ្នកតម្កល់នៅក្នុងព្រះពុទ្ធសាសនានោះ, ដំបូងបង្អស់ត្រូវបញ្ចេញវចីភេទ សូមខមាទោសនឹងព្រះរតនត្រ័យ ក្នុងទីចំពោះភក្ត្រព្រះពុទ្ធរូបក៏បាន ចំពោះព្រះស្តូប ឬព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុ ព្រះសម្មាសម្ពុទ្ធក៏បាន ចំពោះមុខបុគ្គល គឺភិក្ខុ ១ រូប ក៏បាន ចំពោះមុខគណៈ គឺភិក្ខុ ២ រូប ឬ ៣ រូបក៏បាន ចំពោះសង្ឃ* គឺភិក្ខុទាំងឡាយតាំងពី ៤ រូបឡើងទៅក៏បាន លុះសូមខមាទោសរួចហើយត្រូវបញ្ចេញវចីភេទពោលប្រកាសប្ដេជ្ញា ខ្លួនឱ្យជាអ្នកបានដល់ព្រះត្រៃសរណគមន៍ ជាឧបាសក ឬ ជាឧបាសិកាក្នុងព្រះពុទ្ធសាសនាជាខាងក្រោយ រួចហើយត្រូវសមាទាននិច្ចសីលរក្សាឱ្យខ្ជាប់តទៅ, បើមានសទ្ធាជ្រះថ្លា ក៏គប្បីរក្សាឧបោសថសីល តាមកាលកំណត់ដែលត្រូវរក្សាម្ដងៗ នោះផង នឹងមានផលានិសង្ស ច្រើនដោយលំដាប់ៗ ឡើង ។

---

* ភិក្ខុឬសា.១រូប តាំងចិត្តថា សង្ឃក៏បាន ព្រោះមិនជាសង្ឃកម្ម។

ឯពាក្យសូមខមាទោសនឹងព្រះរតនត្រ័យនោះ ក្នុងទីនេះ សូមរៀបរៀងតែវិធីខមាទោសចំពោះមុខព្រះសង្ឃប៉ុណ្ណោះ

បើបុរសតែម្នាក់ ត្រូវសូធ្យថា :

**អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមុឡ្ហំ យថាអកុសលំ យោហំ ភន្តេ កាយេន វា វាចាយ វា មនសា វា ពុទ្ធស្ស វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អកាសឹ តស្ស មេ ភន្តេ សង្ឃោ អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយ**

បពិត្រព្រះសង្ឃដ៏ចម្រើន ទោសកំហុសដែលប្រព្រឹត្តកន្លងគ្របសង្កត់ហើយនូវខ្ញុំព្រះករុណា តាមដោយខ្ញុំព្រះករុណាជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រព្រះសង្ឃដ៏ចម្រើន ក្រែងខ្ញុំព្រះករុណា បានធ្វើហើយនូវសេចក្ដីល្មើស មិនគោរពដល់ព្រះពុទ្ធជាម្ចាស់ក្ដី ដល់ព្រះធម៌ក្ដី ដល់ព្រះសង្ឃក្ដី ដោយកាយក្ដី ដោយវាចាក្ដី ដោយចិត្តក្ដី បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃ អត់នូវទោសកំហុសនោះ ដល់ខ្ញុំព្រះករុណា ព្រោះអំពើនៃទោសនោះ ជាសេចក្ដីខុសពិត ដើម្បីនឹងបានសង្រួម គឺថានឹងប្រព្រឹត្តឱ្យល្អតទៅក្នុងខាងមុខនោះហោង ។

បើស្ត្រីតែម្នាក់ ត្រូវសូធ្យថា ៖

**អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមុឡ្ហំ យថាអកុសលំ យាហំ ភន្តេ កាយេន វា វាចាយ វា មនសា វា ពុទ្ធស្ស វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អកាសឹ តស្សា មេ ភន្តេ សង្ឃោ អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយ**

(ប្រែដូចគ្នានឹងបុរសម្នាក់ខាងលើ) ។

បើបុរសច្រើននាក់ ត្រូវសូធ្យថា ៖

**អច្ចយោ នោ ភន្តេ អច្ចគមា យថាពាលេ យថាមុឡ្ហេ យថាអកុសលេ យេ មយំ ភន្តេ កាយេន វា វាចាយ វា មនសា វា ពុទ្ធស្ស វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អករិម្ហា តេសំ នោ ភន្តេ សង្ឃោ អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយ**

បពិត្រព្រះសង្ឃដ៏ចម្រើន ទោសកំហុសដែលប្រព្រឹត្តកន្លង គ្របសង្កត់ហើយនូវខ្ញុំព្រះករុណាទាំងឡាយ តាមដោយខ្ញុំ

ព្រះករុណាទាំងឡាយ ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រព្រះសង្ឃដ៏ចម្រើន ក្រែងខ្ញុំព្រះករុណាទាំងឡាយ បានធ្វើហើយនូវសេចក្តីល្មើស មិនគោរពដល់ព្រះពុទ្ធជាម្ចាស់ក្តី ដល់ព្រះធម៌ក្តី ដល់ព្រះសង្ឃក្តី ដោយកាយក្តី ដោយវាចាក្តី ដោយចិត្តក្តី បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃ អត់នូវទោសកំហុសនោះ ដល់ខ្ញុំព្រះករុណាទាំងឡាយ ព្រោះអំពើនៃទោសនោះ ជាសេចក្តីខុសពិត ដើម្បីនឹងបានសង្រួម គឺថានឹងប្រព្រឹត្តឱ្យល្អតទៅក្នុងខាងមុខនោះហោង ។

បើស្ត្រីច្រើននាក់ ត្រូវសូធ្យថា :

**អច្ចយោ នោ ភន្តេ អច្ចគមា យថាពាលា យថាមុឡ្ហា យថាអកុសលា យា មយំ ភន្តេ ភារេយន ឞា ឞាចាយ ឞា មនសា ឞា ពុទ្ធស្ស ឞា ធម្មស្ស ឞា សង្ឃស្ស ឞា អគារវំ អករិម្ហា តាសំ នោ ភន្តេ សង្ឃោ អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតី សំវរាយ**

(ប្រែដូចគ្នានឹងបុរសច្រើននាក់ខាងលើ) ។

បើបុរសនិងស្ត្រីច្រើននាក់លាយគ្នា តាំងពីពីរនាក់ឡើងទៅ សូមខមាទោសព្រមគ្នានោះ ត្រូវសូធ្យថា :

**អច្ចយោ នោ ភន្តេ អច្ចគមា យថាពាលេ / យថាពាលា / យថាមុឡ្ហេ / យថាមុឡ្ហា / យថាអកុសលេ / យថាអកុសលា / យេ / យា / មយំ ភន្តេ ភារយេន វា វាចាយ វា មនសា វា ពុទ្ធស្ស វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អករិម្ហា តេសំ / តាសំ / នោ ភន្តេ សង្ឃោ អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយ**

(ប្រែដូចគ្នានឹងបុរសច្រើននាក់ខាងលើ) ។

ព្រះសង្ឃដែលនៅទីនោះ ត្រូវទទួលថា **សាធុ** (ប្រែថា) ប្រពៃហើយ ។

បុរសត្រូវថា **យថាពាលេ យថាមុឡ្ហេ យថាអកុសលេ / យេ មយំ / តេសំ នោ** ។ បើស្ត្រីត្រូវថា **យថាពាលា យថាមុឡ្ហា យថាអកុលលា / យា មយំ / តាសំ នោ** ។

បាលីក្រៅពីនេះ ថាដូចគ្នាទាំងអស់ តែលោកអ្នកលំបាកពោលបាលី នឹងពោលតែសម្រាយក៏បាន ។

លុះបានសូមខមាទោសនឹងព្រះរតនត្រ័យដូច្នេះរួចហើយ គប្បីបញ្ចេញវចីភេទប្តេជ្ញាខ្លួនជាអ្នកដល់ព្រះត្រៃសរណគមន៍ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរឭក ដើម្បីនឹងឱ្យឡើងនាមបញ្ញត្តិជា **ឧបាសក** ឬជា **ឧបាសិកា** ក្នុងព្រះពុទ្ធសាសនាតទៅ, ឯប្តេជ្ញាខ្លួននោះនឹងប្តេជ្ញា ក្នុងទីចំពោះព្រះភក្ត្រព្រះពុទ្ធរូបក៏បាន ចំពោះព្រះស្តូប ឬព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុព្រះដ៏មានបុណ្យក៏បាន ចំពោះមុខបុគ្គល ឬគណៈ ឬសង្ឃក៏បាន ។

ឯពាក្យសូត្យប្តេជ្ញាខ្លួនចំពោះព្រះរតនត្រ័យនោះ ក្នុងទីនេះ សូមរៀបរៀងតែវិធីប្តេជ្ញាខ្លួនចំពោះមុខព្រះសង្ឃប៉ុណ្ណោះ

បើបុរសតែម្នាក់ ត្រូវប្តេជ្ញាដោយពាក្យថា :

**ឯសាហំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ សង្ឃោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ**

ប្រែថា បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាសូមដល់នូវព្រះដ៏មានព្រះភាគ ដែលទ្រង់បរិនិព្វានទៅ អស់កាលយូរ

អង្វែងហើយនោះផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះសង្ឃ ជ្រាបនូវខ្ញុំព្រះករុណាថា ជាឧបាសក បានដល់ហើយនូវព្រះរតនត្រ័យជាទីពឹង ទីរឭក ស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

បើស្ត្រីតែម្នាក់ ត្រូវប្ដេជ្ញាដោយពាក្យថា :

**ឯសាហំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសិកំ មំ សង្ឃោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ។**

(ប្រែដូចបុរសម្នាក់ខាងលើ គ្រាន់តែប្ដូរជា ឧបាសិកា ) ។

បើបុរសច្រើននាក់ ត្រូវប្ដេជ្ញាដោយពាក្យថា :

**ឯតេ មយំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកេ នោ សង្ឃោ ធារេតុ អជ្ជតគ្គេ បាណុបេតេ សរណំ គតេ**

ប្រែថា បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមដល់នូវព្រះដ៏មានព្រះភាគ ដែលទ្រង់បរិនិព្វានទៅ អស់

កាលយូរអង្វែងហើយនោះផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះសង្ឃ ជ្រាបនូវខ្ញុំព្រះករុណាទាំងឡាយថា ជាឧបាសក បានដល់ហើយនូវព្រះរតនត្រ័យជាទីពឹងទីរឭក ស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

បើស្ត្រីច្រើននាក់ ត្រូវប្តេជ្ញាដោយពាក្យថា ៖

**ឯតេ មយំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសិកាយោ នោ សង្ឃោ ធារេតុ អជ្ជតគ្គេ បាណុបេតា សរណំ គតា**

(ប្រែដូចបុរសច្រើននាក់ខាងលើ គ្រាន់តែប្តូរជា ឧបាសិកា ) ។

បើបុរសស្ត្រីច្រើននាក់ ត្រូវប្តេជ្ញាដោយពាក្យថា ៖

**ឯតេ មយំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកេ / ឧបាសិកាយោ នោ សង្ឃោ ធារេតុ អជ្ជតគ្គេ បាណុបេតេ សរណំ គតេ / បាណុបេតា សរណំ គតា ។**

(ប្រែដូចបុរសច្រើននាក់ខាងលើ គ្រាន់តែប្តូរជា ឧបាសក ឧបាសិកា ) ។

រួចបុគ្គលឬគណៈ ឬសង្ឃ ត្រូវទទួលថា **សាធុ** (ប្រែថា) ប្រពៃហើយ ។

បើបុរសតែម្នាក់ ឬស្ត្រីតែម្នាក់ ហើយសូធ្យប្តេជ្ញាខ្លួន ចំពោះព្រះពុទ្ធរូប ឬព្រះស្តូប ឬព្រះចេតិយ ដែលបញ្ចុះ ព្រះសារីរិកធាតុ ព្រះដ៏មានបុណ្យនោះ ត្រូវពោលប្តេជ្ញា ដោយពាក្យថា :

**ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ / ឧបាសិកំ / មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ**

ប្រែថា បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន ខ្ញុំព្រះករុណា សូមដល់នូវព្រះដ៏មានព្រះភាគផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះដ៏មានព្រះភាគទ្រង់ជ្រាបនូវខ្ញុំព្រះករុណាថាជា ឧបាសក / ឧបាសិកា / បាន ដល់ហើយនូវព្រះរតនត្រ័យ ជាទីពឹងទីរឭកស្មើដោយជីវិត តាំងពីថ្ងៃនេះ ជាដើមរៀងទៅ ។

បើគ្នាច្រើន ក៏ត្រូវសូធ្យដូចន័យមុន ខុសគ្នាតែត្រង់

ពាក្យថា **ភគវន្តំ** ថា **ភគវា** ប៉ុណ្ណោះ, បើគ្នាច្រើន ហើយនឹងសូធ្យប្ដេជ្ញាខ្លួនព្រមគ្នា ដោយពាក្យជាឯកវចនៈ ក៏បានព្រោះសូធ្យព្រមទាំងអស់គ្នា ។

បុរស ឬស្ត្រី កាលបើបានពោលពាក្យប្ដេជ្ញាខ្លួន ជាអ្នកបានដល់ព្រះត្រៃសរណគមន៍ជាទីពឹងទីរឭក ដូច្នេះ រួចហើយ ក៏បាននាមបញ្ញត្តិថា **"ឧបាសក"** ឬ **"ឧបាសិកា"** ក្នុងខណៈនោះឯង ។

វិធីសូមខមាទោសក្ដី វិធីសូមប្ដេជ្ញាខ្លួនជាឧបាសក ជាឧបាសិកាក្ដី បើអ្នកដែលមិនចេះសូធ្យជាបាលី នឹងសូធ្យ ជាសេចក្ដីសម្រាយ តាមភាសារបស់ខ្លួននោះក៏បាន បើចេះសូធ្យទាំងបាលី ទាំងសេចក្ដីប្រែសម្រាយផង ដូចបានពោលមកហើយនោះជាការប្រពៃពិត តែកុំសូធ្យតែបាលីទទេ ដោយមិនដឹងថាជាអ្វីនោះឡើយ ព្រោះកិច្ចដែលសូធ្យខមាទោសនិងប្ដេជ្ញាខ្លួននោះចំពោះយកសទ្ធា គឺសេចក្ដីជឿជាក់ និងបញ្ញាជាសម្មាទិដ្ឋិ ដែលដឹងពិត យល់ត្រូវពិត ជាប្រមាណ ។

( ចប់បុព្វភាគបដិបត្តិតែប៉ុណ្ណេះ )

## ឧបាសកនិទ្ទេស

សម្តែងអំពីនាមថា ឧបាសក

និងធម៌របស់ឧបាសកផ្សេងៗមានសីលជាដើម

≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈

ជនដែលមាននាមបញ្ញត្តិថា “ **ឧបាសក** ” នោះ ដោយហេតុដែលបានចូលទៅជិត ដល់នូវព្រះរតនត្រ័យជាទីពឹងទីរឭក ដូចពុទ្ធភាសិតដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងចំពោះមហានាមសក្យរាជថា “ម្នាលមហានាម គ្រហស្ថឯណាមួយបានដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរឭក គ្រហស្ថនោះឯង បានឈ្មោះថា **ឧបាសក** បើស្ត្រីហៅថា **ឧបាសិកា** ” ។

ម្យ៉ាងទៀត មានបាលីថា **រតនត្តយំ ឧបាសតីតិ ឧបាសកោ** ជនឯណា ចូលទៅអង្គុយជិតព្រះរតនត្រ័យ ជននោះ ឈ្មោះថា **ឧបាសក** ។

អធិប្បាយថា ជនដែលចូលទៅអង្គុយជិតព្រះរតនត្រ័យនោះ គឺ មិនមែនជាអ្នកចូលទៅអង្គុយជិតព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជានិច្ច ដោយរូបកាយនោះទេ គឺលោកសង្គ្រោះយកនាមកាយជាប្រមាណ, សូម្បីជននោះ ស្ថិតនៅក្នុងទីឆ្ងាយប៉ុន្មាន

តែមានសន្តានចិត្តប្រព្រឹត្តជាប់នៅ ក្នុងគុណព្រះរតនត្រ័យជានិច្ច, ចិត្តនោះឱនទៅតោងយក គុណព្រះរតនត្រ័យ ជាទីពឹងទីរឭកជានិច្ចហើយ ជននោះ ឈ្មោះថា បានចូលទៅអង្គុយជិតព្រះរតនត្រ័យជានិច្ច, បើគ្រាន់តែចូលទៅអង្គុយជិតព្រះពុទ្ធដោយរូបកាយ តែសន្តានចិត្តនោះ ស្ថិតនៅក្នុងទីឆ្ងាយអំពីគុណព្រះរតនត្រ័យ មិនបង្អោនចិត្តទៅក្នុងគុណព្រះរតនត្រ័យទេ ជននោះ ឈ្មោះថា ស្ថិតនៅឆ្ងាយអំពីគុណព្រះរតនត្រ័យ មិនមែនជា " ឧបាសក, ឧបាសិកា " ឡើយ ។

## សីលនៃឧបាសក

បញ្ចវិរតិចេតនា គឺចេតនាដែលវៀរចាកវេរា ៥ ឈ្មោះថា ជា" សីលនៃឧបាសក " ដូចពុទ្ធភាសិតដែលព្រះបរមគ្រូជាម្ចាស់ទ្រង់ ត្រាស់សម្តែងចំពោះមហានាមសក្យរាជថា "ម្នាលមហានាម ឧបាសកឯណា បានវៀរចាក **បាណាតិបាត** គឺមិនសម្លាប់សត្វ ១ វៀរចាក **អទិន្នាទាន** គឺមិនលួចទ្រព្យអ្នកដទៃ ១ វៀរចាក **កាមេសុមិច្ឆាចារ** គឺមិនប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ វៀរចាក **មុសាវាទ** គឺមិននិយាយកុហក ១ វៀរចាក **សុរាមេរយៈ** គឺមិនផឹកនូវសុរា និង មេរ័យ ១ ឧបាសកនោះ ឈ្មោះថា **ឧបាសកមានសីល** " ។

## អាជីវនៃឧបាសក

កិរិយាលះបង់នូវជំនួញខុស ៥ ប្រការ ហើយប្រកបកិច្ចការចិញ្ចឹមជីវិតដោយត្រឹមត្រូវតាមធម៌ ឈ្មោះថា “ **អាជីវនៃឧបាសក** ” ដូចមានពុទ្ធប្បញ្ញត្តិ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ហាមចំពោះភិក្ខុទាំងឡាយថា :

**បញ្ចិមា ភិក្ខវេ វណិជ្ជា ឧបាសកេន អករណីយា**

ម្នាលភិក្ខុទាំងឡាយ ជំនួញខុសទាំងឡាយ ៥ ប្រការ ឧបាសកមិនគប្បីធ្វើឡើយ ។

ជំនួញខុស ៥ ប្រការនោះគឺ :

១- **សត្ថវណិជ្ជា** ជួញគ្រឿងសស្ត្រាវុធសំរាប់ប្រហារ គឺធ្វើគ្រឿងសស្ត្រាវុធនោះដោយខ្លួនឯង ឬឱ្យអ្នកដទៃគេធ្វើឱ្យ ឬបានមកដោយហេតុឯណាមួយ ហើយលក់នូវគ្រឿងសស្ត្រាវុធនោះ ។

២- **សត្តវណិជ្ជា** ជួញមនុស្ស ។

៣- **មំសវណិជ្ជា** ជួញសាច់ គឺ ចិញ្ចឹមនូវសត្វទាំងឡាយមានគោជាដើម លុះដល់សត្វទាំងឡាយនោះចម្រើនធំឡើង ក៏សម្លាប់យកសាច់លក់ ។

៤- **មជ្ជវណិជ្ជា** ជួញទឹកស្រវឹង គឺផ្សំគ្រឿងស្រវឹងឯណាមួយ ឱ្យកើតឡើងជាទឹកស្រវឹងដោយខ្លួនឯង ឬទិញគេយកមក ហើយលក់នូវទឹកស្រវឹងនោះ ។

៥- **វិសវណិជ្ជា** ជួញថ្នាំពិស គឺចាត់ចែងផ្សំថ្នាំពិស ឱ្យកើតឡើងដោយខ្លួនឯង ឬឱ្យគេផ្សំឱ្យ ឬបានមកដោយហេតុឯណាមួយ ហើយលក់នូវថ្នាំពិសនោះ ។

ឧបាសកកាលបើវៀរចាកជំនួញខុសទាំង ៥ ប្រការនេះ ហើយបានប្រតិបត្តិការចិញ្ចឹមជីវិតដោយធម៌ ឈ្មោះថា **មានអាជីវធម៌ដោយប្រពៃ** ។

❀❀❀❀❀❀❀❀

## វិបត្តិនៃឧបាសក

ធម្មជាតិដែលញ៉ាំងសីល និង អាជីវធម៌នៃឧបាសកឱ្យវិនាស ឈ្មោះថា **វិបត្តិ** ។ វិបត្តិនោះមាន ៥ យ៉ាងគឺ :

១- **អស្សទ្ធោ ហោតិ** ឧបាសកមិនជឿគុណព្រះរតនត្រ័យ

២- **ទុស្សីលោ ហោតិ** ឧបាសកទ្រុស្តសីល ។

៣- **កោតុហលមង្គលិកោ ហោតិ** ឧបាសកប្រកបដោយ

មង្គលភ្ញាក់ផ្អើល ។

៤- **មង្គលំ បច្ចេតិ នោ កម្មំ** ឧបាសកប្រកាន់ជឿថា មង្គលមានឫក្សពារវេលាជាដើមឱ្យផល មិនប្រកាន់ជឿថា កម្មជាកុសល និង អកុសលឱ្យផលឡើយ ។

៥- **ឥតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ តត្ថ ច បុព្វការំ ករោតិ** ឧបាសកស្វែងរកតែទក្ខិណេយ្យបុគ្គល គឺ បដិគ្គាហកៈអ្នកទទួលទានខាងក្រៅព្រះពុទ្ធសាសនា ហើយធ្វើ នូវទាន ដល់ទក្ខិណេយ្យបុគ្គលខាងក្រៅព្រះពុទ្ធសាសនានោះ ។

ឧបាសកឯណាប្រកបដោយវិបត្តិ ៥ យ៉ាងនេះ ត្រង់ វិបត្តិណាមួយហើយ, ឧបាសកនោះ ឈ្មោះថា **"ឧបាសកចណ្ឌាល"** គឺឧបាសកដូចជាមនុស្សចណ្ឌាលផង ឈ្មោះថា **"ឧបាសកមលៈ"** គឺ ឧបាសកមានធម៌ជាមន្ទិលសៅហ្មងផង ឈ្មោះថា **"ឧបាសកបដិកិដ្ឋៈ"** គឺ ឧបាសកដែលអ្នកប្រាជ្ញទាំង ឡាយ លោកតិះដៀលផង ។

## សម្បត្តិនៃឧបាសក

ធម្មជាតិដែលញ៉ាំងសីល និង អាជីវធម៌នៃឧបាសក ឱ្យបរិបូណ៌ ឱ្យបរិសុទ្ធប្រពៃ ឈ្មោះថា " **សម្បត្តិ** " ។ សម្បត្តិនោះមាន ៥ យ៉ាងគឺ :

១- **សទ្ធោ ហោតិ** ឧបាសកមានសេចក្ដីជឿជាក់ច្បាស់ក្នុងគុណព្រះរតនត្រ័យ ។

២- **សីលវា ហោតិ** ឧបាសកមានសីល ។

៣- **ន កោតុហលមង្គលិកោ ហោតិ** ឧបាសកមិនប្រកបដោយមង្គលភ្ញាក់ផ្អើល ។

៤- **កម្មំ បច្ចេតិ នោ មង្គលំ** ឧបាសកប្រកាន់ជឿថាកម្មជាកុសល និង អកុសលឱ្យផល មិនប្រកាន់ជឿថា មង្គលមានឫក្សពារវេលាជាដើមឱ្យផលឡើយ ។

៥- **ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុព្វការំ ករោតិ** ឧបាសកមិនស្វែងរកទក្ខិណេយ្យបុគ្គល គឺបដិគ្គាហកៈអ្នកទទួលទានខាងក្រៅព្រះពុទ្ធសាសនាឡើយ ហើយធ្វើទាន តែក្នុងទក្ខិណេយ្យបុគ្គលក្នុងព្រះពុទ្ធសាសនានេះ ។

ឧបាសកឯណា ប្រកបដោយសម្បត្តិ ៥ យ៉ាងនេះហើយ ឧបាសកនោះ ឈ្មោះថា **ឧបាសករតនៈ** គឺឧបាសកដូចជារតនៈ វត្ថុមានកែវជាដើមផង ឈ្មោះថា **ឧបាសកបទុមៈ** គឺឧបាសកដូចជាផ្កាឈូកមានពណ៌ក្រហមផង ឈ្មោះថា **ឧបាសកបុណ្ឌរីកៈ** គឺឧបាសកដូចជាផ្កាឈូកមានពណ៌សផង ។

## គុណនៃឧបាសក

ធម៌សំរាប់ឧបាសក ឧបាសិកាប្រតិបត្តិគ្រប់រូប ដើម្បីនឹងឱ្យកើត ឱ្យចម្រើននូវសម្បត្តិទាំងពួង ឈ្មោះថា **គុណ** ។ គុណនេះ ជារបស់ឧបាសក ឧបាសិកា ហៅថា "**ឧបាសកគុណ**" មាន ១០ យ៉ាងគឺ :

**១. សង្ឃេន សទ្ធឹ សមានសុខទុក្ខោ ហោតិ** ឧបាសកអ្នករួមសេចក្ដីសុខទុក្ខ មួយអន្លើដោយភិក្ខុសង្ឃ គឺថា បើភិក្ខុសង្ឃមានសេចក្ដីសុខ ក៏ត្រេកអរ បើភិក្ខុសង្ឃមានសេចក្ដីទុក្ខព្រួយ ក៏ព្រួយជាមួយផង ។

**២- កាយិកវាចសិកញ្ច សុរក្ខិតំ ហោតិ** ឧបាសកមានកាយកម្ម និងវចីកម្មរក្សាហើយដោយប្រពៃ ។

៣- **ធម្មោ អធិបតេយ្យោ ហោតិ** ឧបាសកមានធម៌ជាអធិបតី គឺថាបើប្រព្រឹត្តធ្វើអ្វីៗ រមែងកាន់យកធម៌ជាធំ ជាទីតាំងជាទីអាងមាំមិនឱ្យខុស មិនឱ្យឃ្លៀងឃ្លាតអំពីធម៌ឡើយ ។

៤- **យថាថាមេន សំវិភាគរតោ ច ហោតិ** ឧបាសកជាអ្នកត្រេកអរក្នុងការបរិច្ចាគទាន តាមសមគួរដល់កម្លាំងនៃខ្លួន គឺធ្វើទានតាមសមគួរដល់ទ្រព្យតិចនិងច្រើន បើមានតិចក៏ធ្វើតិច បើមានច្រើនក៏ធ្វើច្រើន មិនមានមច្ឆរិយធម៌គ្របសង្កត់សន្តានចិត្តឡើយ ។

៥- **ជិនសាសនំ ឋានិតុញ្ច វាយមតិ** ឧបាសកឧស្សាហ៍ព្យាយាម ដើម្បីនឹងឱ្យដឹងច្បាស់នូវសាសនៈ គឺពាក្យប្រៀនប្រដៅ ពាក្យបណ្តាំនៃព្រះជិនស្រី ។

៦- **សម្មាទិដ្ឋិកោ ច ហោតិ** ឧបាសកជាសម្មាទិដ្ឋិ គឺមានប្រាជ្ញាឃើញត្រូវតាមសេចក្តីពិត ។

៧. **អបគតោ កោតុហលមង្គលិកោ ច ហោតិ** ឧបាសកប្រាសចាកមង្គលភ្ញាក់ផ្អើល ហើយជាអ្នកមិនប្រកាន់ជឿថាមង្គលមានឫក្សពារ វេលាជាដើមឱ្យផលឡើយ ប្រកាន់ជឿ

តែកម្មជាកុសល និងអកុសលថា ឱ្យផល ។

**៨- ជីវិតហេតុបិ អញ្ញំ សត្ថារំ ន ឧទ្ទិសតិ** ឧបាសក បើ ទុកជាមានហេតុគួរដល់នូវសេចក្តីវិនាសជីវិតក្តី ក៏មិនលះបង់ព្រះរតនត្រ័យ ហើយត្រឡប់ទៅកាន់យកមនុស្សដទៃ ជាគ្រូអាចារ្យជាទីពឹងរបស់ខ្លួន ថាប្រសើរជាងព្រះរតនត្រ័យនោះឡើយ ។

**៩- សមគ្គារាមោ ច ហោតិ** ឧបាសកមានសេចក្តីត្រេកអរក្នុងសាមគ្គីធម៌ គឺសេចក្តីព្រមព្រៀងគ្នា ។

**១០- សាសនេ ចរតិ** ឧបាសកប្រព្រឹត្តល្អក្នុងព្រះពុទ្ធសាសនា គឺប្រព្រឹត្តតាមតែធម៌វិន័យជាពុទ្ធសាសនា ។

ឧបាសកគុណទាំង ១០ យ៉ាងនេះ ឧបាសក ឧបាសិកា គប្បីប្រព្រឹត្តតាមកុំឱ្យឃ្លៀងឃ្លាតឡើយ ព្រោះជាធម៌អាចនឹងធ្វើចិត្តឧបាសក ឧបាសិកា អ្នកប្រព្រឹត្តឱ្យសុចរិតផូរផង់ក្នុងព្រះពុទ្ធសាសនា ហើយឱ្យបានជាបច្ច័យនៃនិព្វានសម្បត្តិផង ។

ចប់ឧបាសកនិទ្ទេស ដោយសង្ខេបប៉ុណ្ណេះ

## វិធីសមាទាននិច្ចសីល

ពុទ្ធសាសនិកជន ដែលបានដល់ព្រះត្រៃសរណគមន៍ បានឡើងនាមបញ្ញត្តិជាឧបាសក ឬឧបាសិកាហើយ កាលបើនឹងសមាទាននូវនិច្ចសីល គឺសីល ៥ ជាបច្ចេកសមាទានអំពីបុគ្គលដទៃ គឺភិក្ខុ ឬសាមណេរនោះ គប្បីសូធ្យនមស្ការថ្វាយបង្គំរព្ញកដល់គុណព្រះរតនត្រ័យ ដោយសង្ខេបជាមុនរួចហើយត្រូវសូមនូវនិច្ចសីល ព្រមទាំងព្រះត្រៃសរណគមន៍ចំពោះនឹងភិក្ខុ ឬសាមណេរដែលខ្លួននឹងសមាទាននោះថា :

**ឱកាស / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ / យាចាមិ / យាចាម ។ ទុតិយម្បិ / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ / យាចាមិ / យាចាម ។ តតិយម្បិ / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ / យាចាមិ / យាចាម ។**

ប្រែថា សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ / សូមនូវសីលទាំងឡាយ ៥

មួយអន្ទើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ / សូមនូវសីលទាំងឡាយ ៥ មួយអន្ទើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា, ជាគម្រប់ពីរដងផង ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ / សូមនូវសីលទាំងឡាយ ៥ មួយអន្ទើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នាជាគម្រប់បីដងផង ។

ឬនឹងសូមថា **ឱកាស / អហំ / ភន្តេ / វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ / យាចាមិ / យាចាម / អនុគ្គហំ កត្វា សីលំ ទេថ / មេ / នោ / ភន្តេ ។ ទុតិយម្បិ / អហំ / ភន្តេ / វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ / យាចាមិ / យាចាម / អនុគ្គហំ កត្វា សីលំ ទេថ / មេ / នោ / ភន្តេ ។ តតិយម្បិ / អហំ / មយំ /**

**ភន្តេ ទិសុំ ទិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ / យាចាមិ / យាចាម / អនុគ្គហំ កត្វា សីលំ ទេថ / មេ / នោ / ភន្តេ ។**

ប្រែថា សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ / សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្ដីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ / សូមនូវនិច្ចសីលប្រកបព្រមដោយ អង្គ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា ជាគម្រប់ពីរដងផង ជាគម្រប់បីដងផង, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្ដីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ ។

( សូមដូច្នេះក៏បាន តាមសេចក្ដីពេញចិត្តរបស់អ្នកសូម )

បើអ្នកសមាទានតែម្នាក់ ត្រូវថា **អហំ** ថា **យាចាមិ** ត្រង់ប្រែត្រូវថា “ខ្ញុំព្រះករុណា” សូមថា **មេ** ត្រង់ប្រែ ត្រូវថា “ដល់ខ្ញុំព្រះករុណា” បើគ្នាច្រើនតាំងពីពីរនាក់ឡើងទៅ នឹងសូមតែម្នាក់ថា **មយំ** ថា **យាចាម** ក៏បាន ត្រង់ប្រែ ត្រូវថា “ ខ្ញុំព្រះករុណាទាំងឡាយ ” សូមថា **នោ** ត្រង់ប្រែត្រូវថា “ដល់ខ្ញុំព្រះករុណាទាំងឡាយ” តែថា បើគ្នាច្រើន ហើយសូធ្យសូមព្រមគ្នានោះ នឹងសូធ្យសូមថា **អហំ** ថា **យាចាមិ** ថា **មេ** ក៏បាន ព្រោះសូធ្យសូមទាំងអស់គ្នា, លុះសូមដូច្នេះ រួចហើយលោកអ្នកឱ្យសីល លោកសូធ្យ **នមោ** ៣ ចប់ ហើយលោកឱ្យព្រះត្រៃសរណគមន៍ និងនិច្ចសីល, អ្នកសមាទានត្រូវទទួលថាតាមលោក ដោយបញ្ចេញវចីភេទឱ្យឮច្បាស់លាស់, កុំទទួលខ្សឹបៗ ។

លោកបង្រៀនសិក្ខាបទសូធ្យថា :

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

( សូត្រ ៣ ដង )

ប្រែថា វីកិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះ

អរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

**ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹងទីរឭក ។

**ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹងទីរឭក ។

**សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹងទីរឭក ។

**ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។

**ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។

**ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។

**តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ជាគម្រប់បីដងផង ។

**តតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ជាគម្រប់បីដងផង ។

**តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ជាគម្រប់បីដងផង ។

ហើយលោកថា **តិសរណគ្គហណំ បរិបុណ្ណំ** (ប្រែថា) កិរិយាកាន់យកនូវព្រះត្រៃសរណគមន៍បរិបូណ៌តែប៉ុណ្ណោះ ។ ត្រូវទទួលថា **អាម ភន្តេ** (ប្រែថា) ករុណាលោកម្ចាស់ ។ ហើយលោក ឱ្យនិច្ចសីល ជាបច្ចេកសមាទានថា ៖

**បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

**អទិន្នាទានា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយ ឬ ដោយវាចា ។

**កាមេសុ មិច្ឆាចារា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុ

វៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

**មុសាវាទា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាពោលនូវពាក្យកុហក ។

**សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនា ជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺ សុរា និង មេរ័យ ។

រួចហើយលោកអ្នកឱ្យសីល លោកពោលដាស់តឿនក្រើនរំឭកថា ៖

**ឥមានិ បញ្ច សិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ** ប្រែថា អ្នក / អ្នកទាំងឡាយ គប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៥ នេះ ឱ្យប្រពៃ ត្រូវរក្សាឱ្យល្អអស់កាលជានិច្ចដោយសេចក្ដីមិនប្រមាទ គឺថា កុំបីធ្វេសប្រហែសឡើយ ។

បើអ្នកសមាទានតែម្នាក់ ត្រូវថា “ អ្នក ” បើគ្នាច្រើនត្រូវថា “ អ្នកទាំងឡាយ ” ។

អ្នកសមាទានត្រូវទទួលថា **អាម ភន្តេ** ( ប្រែដូច មុន )

ហើយ លោកសម្តែងអានិសង្សសីលឱ្យស្តាប់តទៅ ទៀតថា ៖

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា**

**សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។**

(ប្រែថា) សត្វទាំងឡាយទៅកាន់ស្ថានសួគ៌បាន ក៏ព្រោះសីល, សត្វទាំងឡាយបានបរិបូណ៌ដោយភោគៈ ក៏ព្រោះសីល, សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខ ពោលគឺ ព្រះនិព្វាន ក៏ព្រោះសីល, ព្រោះហេតុនោះ បុគ្គលជាសប្បុរស គប្បីជំរះនូវសីលឱ្យបរិសុទ្ធកុំឱ្យសៅហ្មង ។

អ្នកសមាទានត្រូវទទួលថា **សាធុ** ប្រែថា ប្រពៃហើយ ។ វិធីសមាទាននិច្ចសីលជាបច្ចេកសមាទាន ចប់តែប៉ុណ្ណេះ ។

## វិធីសមាទានឧបោសថសីល

ឧបាសក ឧបាសិកា ជាអ្នករក្សានូវឧបោសថសីល កាលបើដល់ថ្ងៃជិតនឹងរក្សានូវឧបោសថសីល គឺថ្ងៃមុន ១ ថ្ងៃ ដែលកំណត់ថា ព្រឹកឡើងនឹងរក្សានូវឧបោសថសីលនោះ គប្បីចាត់ចែងការងារដែលគួរនឹងចាត់ចែង មានវិធីចាត់ចែងនូវអាហារជាដើម ដែលជាការងារ គឺខ្លួននឹងត្រូវធ្វើ ឬនឹងត្រូវ

ប្រើឱ្យគេធ្វើក្នុងថ្ងៃស្អែក គឺក្នុងថ្ងៃឧបោសថកាលឱ្យហើយ ក្នុងថ្ងៃនោះជាមុន តែកុំចាត់ចែងការងារដែលមិនប្រកបដោយធម៌ ដែលជាការងារ គឺខ្លួនជាឧបាសក ឧបាសិកា មិនគួរនឹងចាត់ចែងនោះឡើយ, លុះដល់ព្រឹកឡើងជាថ្ងៃឧបោសថ កាលត្រូវរក្សានូវឧបោសថសីល គប្បីភ្ញាក់ឡើងអំពីព្រលឹម ហើយខ្ពុរមាត់ជំរះធ្មេញឱ្យស្អាតរួចហើយ បើបានសមាទាននូវឧបោសថសីលក្នុងវេលានោះ ក៏ជាការប្រពៃបើឃើញថា នឹងសមាទានពីព្រលឹមនោះមិនទាន់ទេ ក៏គប្បីកំណត់នូវឧបោសថកាល គឺកាលជាទីរក្សានូវឧបោសថសីល ក្នុង ១ ថ្ងៃ ១ យប់នោះ ដោយបញ្ចេញវាចាអធិដ្ឋានថា :

**អជ្ជ ឧបោសថោ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ ឧបាសិកោ / ឧបាសិកា / តមិស្សាមិ**

ប្រែថា ថ្ងៃនេះ ជាថ្ងៃត្រូវរក្សានូវឧបោសថសីល, ខ្លួនអញនឹងជាអ្នករក្សានូវឧបោសថសីលអស់ថ្ងៃនេះ និងយប់នេះ ។

បើឧបាសក ត្រូវថា **ឧបាសិកោ**, បើឧបាសិកា ត្រូវថា **ឧបាសិកា** ។

បើមិនចេះបាលី និងអធិដ្ឋានតាមភាសារបស់ខ្លួនៗ ក៏

គួរដោយពិត, លុះអធិដ្ឋានកំណត់កាលដូច្នេះ រួចហើយត្រូវតាំងវិរតិចេតនាវៀរចាកសីលភេទ គឺហេតុដែលជាទីទំលាយនូវសីលនោះៗ ឱ្យគ្រប់សិក្ខាបទទាំង ៨, កាលបើបានអធិដ្ឋានដូច្នេះរួចហើយ តអំពីពេលនោះមក ក៏គប្បីសមាទាននូវឧបោសថសីលអំពីបុគ្គលដទៃ មានភិក្ខុជាដើមតាមកាលដ៏គួរចុះ បើទុកជាដល់ពេលព្រះអាទិត្យរះខ្ពស់ឡើង ប្រមាណពេញពន្លឺខ្លាំង ទើបបានសមាទានក្តី ក៏ឈ្មោះថា បានសមាទានដោយប្រពៃ ឈ្មោះថា បានរក្សានូវឧបោសថសីល ពេញកាលកំណត់ ១ ថ្ងៃ ១ យប់ ដោយបរិបូណ៌ ព្រោះអ្នកសមាទានបានធ្វើនូវឧបោសថកាលមិនឱ្យខ្វះខាត ទាំងវិរតិចេតនាសោតក៏កើតខ្លាំងក្លាបរិបូណ៌ក្នុងសន្តាន នឹងបានផលានិសង្សច្រើន ។

កាលបើឧបាសក ឧបាសិកា នឹងសមាទាននូវឧបោសថសីលប្រកបព្រមដោយអង្គ ៨ ជាបច្ចេកសមាទានអំពីបុគ្គលដទៃ គឺភិក្ខុឬសាមណេរនោះ គប្បីស្វធ្យនមស្ការថ្វាយបង្គំរឭកដល់គុណព្រះរតនត្រ័យដោយសង្ខេប ជាមុនរួចហើយ ត្រូវសូមនូវឧបោសថសីល ព្រមទាំងព្រះត្រៃសរណគមន៍ ចំពោះភិក្ខុ ឬសាមណេរ ដែលខ្លួននឹងសមាទាននោះថា :

**ឱកាស / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋ សីលានិ / យាចាមិ / យាចាម ។ ទុតិយម្បិ / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋ សីលានិ / យាចាមិ / យាចាម ។ តតិយម្បិ / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋ សីលានិ / យាចាមិ / យាចាម ។**

ប្រែដូចក្នុងវិធីសូមនិច្ចសីលខាងដើម ប្លែកគ្នាតែត្រង់ពាក្យថា **អដ្ឋ សីលានិ** ប្រែថា នូវសីលទាំងឡាយ ៨ ។

ឬនឹងសូមថា **ឱកាស / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ / យាចាមិ / យាចាម / អនុគ្គហំ កត្វា សីលំ ទេថ / មេ / នោ / ភន្តេ ។ ទុតិយម្បិ / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ / យាចាម / អនុគ្គហំ កត្វា សីលំ ទេថ /**

**មេ / នោ / ភន្តេ ។ តតិយម្បិ / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ / យាចាមិ / យាចាម / អនុគ្គហំ កត្វា សីលំ ទេថ / មេ / នោ / ភន្តេ ។**

ប្រែថា សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ / សូមនូវឧបោសថសីលប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា បពិត្រព្រះករុណា ដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ , បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ / សូមនូវឧបោសថសីលប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា ជាគម្រប់ពីរដងផង ជាគម្រប់បីដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ ។

សូមដូច្នេះក៏បាន តាមសេចក្តីពេញចិត្តរបស់អ្នកសូម ។ សេចក្តីអធិប្បាយអំពីអ្នកសូមតែម្នាក់ និង ច្រើននាក់នោះ ដូចគ្នានឹងវិធីសូមនិច្ចសីលខាងដើម ។

រួចហើយលោកអ្នកឱ្យសីល លោកតាំង **នមោ** ៣ ចប់ ហើយឱ្យព្រះត្រៃសរណគមន៍ អ្នកសមាទានត្រូវទទួលថាតាមលោកដូចវិធីសមាទាននិច្ចសីលខាងដើម, រួចហើយលោកឱ្យនូវឧបោសថសីលជាបច្ចេកសមាទានថា :

**បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ** ប្រែដូចនិច្ចសីល ។

**អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ** ប្រែដូចនិច្ចសីល ។

**អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តនូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម ។

**មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ** ប្រែដូចនិច្ចសីល ។

**សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** ប្រែដូចនិច្ចសីល ។

**វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស ។

**នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធវិលេបនធារណមណ្ឌន-វិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយារាំ និងច្រៀង និងប្រគំនិងមើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌ និងកិរិយាទ្រទ្រង់ និងប្រដាប់ និងតាក់តែងស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និង គ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ។

**ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកទីសេនាសនៈ ដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ។

រួចហើយអ្នកសមាទាន សូធ្យកំណត់ឧបោសថកាលថា:

**ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ ។**

ប្រែថា ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីល ដ៏ប្រកបព្រមដោយអង្គ ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់បញ្ញត្តទុកហើយនេះ ដើម្បីនឹងរក្សាឱ្យបរិបូណ៌ប្រពៃអស់កាលកំណត់ថ្ងៃនេះ និងយប់នេះ សូមកុសលចូលជាឧបនិស្ស័យធ្វើឱ្យច្បាស់នូវព្រះនិព្វាន ឰដ៏អនាគតទៅ ឯមុខនោះហោង ។

បាលីនេះ គ្រាន់តែជាពាក្យសំរាប់ពោលកំណត់កាលឱ្យដឹងថា ឧបោសថសីលទាំង ៨ សិក្ខាបទនេះ អ្នកសមាទានត្រូវរក្សាតែត្រឹម ១ ថ្ងៃ ១ យប់នោះប៉ុណ្ណោះ, ហេតុនោះបើអ្នកសមាទានបានចេះដឹងច្បាស់ប្រាកដ ក្នុងឧបោសថកាលហើយ មិនបាច់សូធ្យក៏បាន, តែបើទុកជាចេះដឹងច្បាស់ប្រាកដហើយ នឹងសូធ្យបាលីនេះ ព្រមទាំងសេចក្តីប្រែផងនោះ ក៏ជាការប្រពៃណាស់ ជាហេតុនាំឱ្យរឹតតែចេះស្ទាត់ ប្រាកដទាំងអស់គ្នាឡើង ។

រួចហើយ លោកអ្នកឱ្យសីល លោកពោលដាស់ តឿនក្រើនរំឭកថា

**ឥមានិ អដ្ឋ សិក្ខាបទានិ ឧបោសថសីលវសេន**

**ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ កត្វា**

**អប្បមាទេន សម្មារក្ខិតព្វំ ។**

ប្រែថា អ្នកទាំងឡាយគប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៨ នេះ ឱ្យប្រពៃ ត្រូវរក្សាឱ្យល្អដោយអំណាចនៃឧបោសថ សីលអស់កាលកំណត់ត្រឹម ១ ថ្ងៃ ១ យប់នេះ ដោយសេចក្តីមិនប្រមាទ គឺថា កុំបីធ្វេសប្រហែសឡើយ ។

អ្នកសមាទាន ត្រូវទទួលថា **អាម ភន្តេ** ( ប្រែដូចមុន ) ។ ហើយលោកសំដែងអានិសង្សសីលឱ្យស្តាប់ តទៅទៀតថា :

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា**

**សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។**

( ប្រែដូចមុន ) អ្នកសមាទានត្រូវទទួលថា **សាធុ** ( ប្រែដូចមុន ) វិធីសមាទានឧបោសថសីលជាបច្ចេកសមាទាន ចប់តែប៉ុណ្ណេះ ។

## សមាទានសីល ១០

អ្នកសមាទានសីល ១០ មុននឹងសូមសីលត្រូវនមស្ការ រំឭកគុណព្រះរតនត្រ័យសិន ហើយសូធ្យសូមជាភាសាបាលីថា៖

**ឱកាស អហំ ភន្តេ, តិសរណេន សហ ទស សីលានិ យាចាមិ, អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ**

សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវសីលទាំងឡាយ ១០ ព្រមទាំងព្រះត្រៃសរណគមន៍ផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា ។

**ទុតិយម្បិ អហំ ភន្តេ ។បេ។ សីលំ ទេថ មេ ភន្តេ**

"បពិត្រព្រះករុណាដ៏ចម្រើន" ខ្ញុំព្រះករុណាសូមនូវសីលទាំងឡាយ ១០ ព្រមទាំងព្រះត្រៃសរណគមន៍ផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា ។ អស់វារៈជាគម្រប់ពីរដងផង ។

**តតិយម្បិ អហំ ភន្តេ ។បេ។ សីលំ ទេថ មេ ភន្តេ**

( បពិត្រព្រះករុណាដ៏ចម្រើន ។ល។ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា ) ។ អស់វារៈជាគម្រប់បីដងផង ។

បើគ្នាច្រើនថា **មយំ ភន្តេ,** ថា **យាចាម (មយំ** ប្រែថា "យើងខ្ញុំព្រះករុណា" ) ។ ត្រង់ **មេ ភន្តេ** ត្រូវថា **នោ ភន្តេ** ( **នោ** ប្រែថា "ដល់យើងខ្ញុំព្រះករុណាទាំងឡាយ" ) ។

កាលបើឧបាសក ឧបាសិកា សូមសីលព្រមទាំងព្រះត្រៃសរណគមន៍រួចហើយ លោកអ្នកឱ្យសីលគួរពោលពាក្យថាៈ

**យមហំ វទាមិ តំ វទេហិ** "អាត្មាពោលនូវពាក្យណា ចូរអ្នកពោលនូវពាក្យនោះ" ។ បើឧបាសក ឧបាសិកាច្រើនគ្នា តាំងពីពីរនាក់ឡើងទៅ លោកអ្នកឱ្យសីលត្រូវថា :

**យមហំ វទាមិ តំ វទេថ** "អាត្មាពោលនូវពាក្យណា ចូរអ្នកទាំងឡាយពោលនូវពាក្យនោះ" ។

អ្នកទទួលសីលត្រូវតបថា **អាម ភន្តេ** "ករុណាលោកម្ចាស់" ។ រួចលោកអ្នកឱ្យសីលសូធ្យថា **នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** ។ (៣ដង)

រួចលោកឱ្យព្រះត្រៃសរណគមន៍តទៅទៀត ។

**ពុទ្ធំ សរណំ គច្ឆាមិ ។ ធម្មំ សរណំ គច្ឆាមិ ។ សង្ឃំ សរណំ គច្ឆាមិ ។ ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ។ ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ ។**

**ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ ។ តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ។ តតិយម្បិ ធម្មំ សរណំ គច្ឆាមិ ។ តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ ។**

រួចព្រះសង្ឃ លោកបញ្ជាក់ថា : **តិសរណគ្គហណំ បរិបុណ្ណំ** “ការទទួលព្រះត្រៃសរណគមន៍ចប់បរិបូណ៌ហើយ”

ទទួលថា **អាម ភន្តេ** “ ករុណាលោកម្ចាស់ ” រួចលោកឱ្យសីល ១០ តទៅទៀត ។

**១-បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

**២-អទិន្នាទានា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយ ឬដោយវាចា ។

**៣-អព្រហ្មចរិយា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តនូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម ។

**៤-មុសាវាទា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

**៥-សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺ សុរា និង មេរ័យ ។

**៦-វិកាលភោជនា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស ។

**៧-នច្ចគីតវាទិតវិសូកទស្សនា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយារាំ និង ច្រៀង និង ប្រគំ និងមើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌ ។

**៨-មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាទ្រទ្រង់ និងប្រដាប់ និងតាក់

តែងស្អិតស្អាងរាងកាយដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ។

**៩-ឧច្ចាសយនមហាសយនា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និង ទីសេនាសនៈដ៏ប្រសើរ ។

**១០-ជាតរូបរជតប្បដិគ្គហណា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាទទួលកាន់យកនូវមាស និង ប្រាក់ដោយខ្លួនឯង ឬប្រើអ្នកដទៃឱ្យទទួលកាន់យក ហើយត្រេកអរចំពោះមាស និង ប្រាក់នោះ ។

លុះទទួលសីល ១០ ចប់ហើយ លោកអ្នកឱ្យសីល គួរប្រាប់បញ្ជាក់ថា :

**ឥមានិ ទស សិក្ខាបទានិ អប្បមាទេន សម្បាទេតព្វំ**

"អ្នកត្រូវរក្សាដោយប្រពៃនូវសិក្ខាបទទាំងឡាយ ១០ នេះ កុំបីធ្វេសប្រហែសឡើយ " ។

អ្នកសមាទានត្រូវទទួលថា : **អាម ភន្តេ** "ករុណាលោកម្ចាស់" លំដាប់មកទៀត លោកអ្នកឱ្យសីលសំដែង

អានិសង្សសីល ដោយសង្ខេប ឬ ដោយពិស្តារឱ្យអ្នកសមាទានស្តាប់តាមកាលដ៏គួរ តាមតែសំដែងអានិសង្សសីលត្រង់ណាក៏បាន តាមសមត្ថភាពរបស់លោក អ្នកឱ្យសីល ។

អានិសង្សសីលសង្ខេប

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា**

**សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ**

សត្វទាំងឡាយទៅកាន់សុគតិភព ក៏ព្រោះសីល, សត្វទាំងឡាយ បានបរិបូណ៌ដោយភោគៈ ក៏ព្រោះសីល, សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខ គឺព្រះនិព្វាន ក៏ព្រោះសីល, ព្រោះហេតុនោះ បុគ្គលជាសប្បុរស គប្បីជម្រះនូវសីលឱ្យបរិសុទ្ធ កុំឱ្យសៅហ្មង ។

**កិកីវ អណ្ឌំ ចមរីវ វាលធឹ បិយំវ បុត្តំ**

**នយនំវ ឯកកំ តថេវ សីលំ អនុរក្ខមានកា**

**សុបេសលា ហោថ សទា សគារវា**

“សត្វត្រដេវរ៉ិច រក្សានូវស៊ុតវា យ៉ាងណាមិញ, សត្វចាមរីរក្សានូវកន្ទុយរបស់វា យ៉ាងណាមិញ, មាតារក្សានូវកូនប្រុសតែមួយ យ៉ាងណាមិញ, ជនមានភ្នែកតែម្ខាង រក្សានូវភ្នែកយ៉ាងណាមិញ, អ្នកទាំងឡាយ កំពុងរក្សាសីល ជាអ្នកមាន

សីលជាទីស្រឡាញ់ក្រៃលែង ចូរជាអ្នកប្រកបដោយសេចក្ដីគោរព សីលឱ្យបានសព្វកាល ក៏យ៉ាងនោះដែរ” ។

**សីលំ យោគិស្ស លង្ការោ សីលំ យោគិស្ស មណ្ឌនំ**

**សីលេហិ លង្កតោ យោគី មណ្ឌនេ អគ្គតំ គតោ ។**

សីលជាគ្រឿងអលង្ការរបស់យោគី ( អ្នករក្សាសីល ) សីលជាគ្រឿងប្រដាប់របស់យោគី ( អ្នករក្សាសីល ) យោគី ( អ្នករក្សាសីល ) ប្រដាប់តាក់តែងដោយសេរីទាំងឡាយ បានដល់នូវភាវៈខ្ពង់ខ្ពស់ក្នុងការប្រដាប់ ( រាងកាយ ) ។

## អធិប្បាយអានិសង្សសីលសង្ខេប

សីលនេះលោករាប់ថា ជាអរិយទ្រព្យ ជាទ្រព្យប្រសើរវិសេស ថ្លៃថ្លាជាងទ្រព្យមានវិញ្ញាណ ឥតវិញ្ញាណរបស់បុរសស្ត្រីក្នុងលោកនេះ ។ ពុទ្ធសាសនិកជន អ្នកមានវិចារណ-ញ្ញាណ គង់នឹងអាចរិះរេឃើញ យល់បានដោយងាយៗ ។

**ន បុប្ផគន្ធោ បដិវាតមេតិ ចន្ទនំ តគរមល្លិកា វា សតញ្ច**

**គន្ធោ បដិវាតមេតី សព្វា ទិសា សប្បុរិសោ បវាយតិ ។**

ក្លិនផ្កាបក់ផ្សាយច្រាសខ្យល់ពុំបានទេ ក្លិនខ្លឹមចន្ទន៍ក្តី ក្លិនក្រស្នាក្តី ក្លិនផ្កាម្លិះរួតក្តី បក់ផ្សាយច្រាសខ្យល់ពុំបានទេ មានតែក្លិននៃពួកសប្បុរស ( អ្នកមានសីល ) ទើបបក់ផ្សាយច្រាសខ្យល់បាន សប្បុរស ( អ្នកមានសីល ) បក់ផ្សាយក្លិនសព្វទិសានុទិស ទាំងបណ្តោយខ្យល់ ទាំងច្រាសខ្យល់ ។

**ចន្ទនំ តគរំ វាបិ ឧប្បលំ អថ វស្សិកី**

**ឯតេសំ គន្ធជាតានំ សីលគន្ធោ អនុត្តរោ ។**

ខ្លឹមចន្ទន៍ក្តី ក្រស្នាក្តី ផ្កាឧប្បលក្តី ផ្កាម្លិះលាក្តី ( សុទ្ធតែមានក្លិនក្រអូប ) ប៉ុន្តែក្លិនសីល ក្រអូបក្រៃលែង ជាងគន្ធជាតទាំងនុ៎ះ ( ឥតមានគន្ធជាតអ្វី ក្រអូបដូចក្លិនសីលឡើយ ) ។

**ន សន្តិ បុត្តា តាណាយ ន បិតា នបិ ពន្ធវា**

**អន្តកេនាធិបន្នស្ស នត្ថិ ញាតីសុ តាណតា**

**ឯតមត្ថវសំ ញត្វា បណ្ឌិតោ សីលសំវុតោ**

**និព្វានគមនំ មគ្គំ ខិប្បមេវ វិសោធយេ ។**

បុគ្គលដែលមរណសង្គ្រាម គឺសេចក្តីស្លាប់ជិះជាន់ហើយ កូនទាំងឡាយនឹងមកជួយខាខាំងរាំងរាពុំបាន មាតា និងបិតា

ទាំងឡាយនឹងមកជួយខាខាំងរាំងរាពុំបាន ផៅពង្សទាំងឡាយនឹងមកជួយខាខាំងរាំងរាពុំបាន គ្រឿងខាខាំងរាំងរាក្នុងញាតិទាំងឡាយ មិនមានសោះឡើយ ( ព្រោះហេតុនោះ ) បុគ្គលដែលមានប្រាជ្ញា កាលបើបានដឹងនូវអំណាចនៃប្រយោជន៍ គឺសីលនុ៎ះហើយ ក៏គួរតែសង្រួមប្រយ័ត្នក្នុងសីល ខំជំរះនូវផ្លូវសំរាប់ដើរទៅកាន់ព្រះនិព្វានឱ្យឆាប់រួសរាន់ កុំបង្អែបង្អង់ឡើយ ។

## របៀបអ្នករក្សាសីល ១០

ឧបាសក ឧបាសិកា អ្នករក្សាសីល ១០ ត្រូវកោរសក់ បើមានពុកមាត់ពុកចង្ការ ក៏ត្រូវកោរផងដែរ ត្រូវកាត់ក្រចកដៃ-ជើង ឱ្យស្មើនឹងសាច់ ត្រូវស្លៀកពាក់ស ឬ ពានាសំពត់សផងក៏បាន តាមគួរដល់ការលៃលកឱ្យសមរម្យ តាមសភាពបុរសនិងស្ត្រី ។ សីលកើតមានឡើង ដោយសារវិរតិចេតនាពុំមែនដោយសារកោរសក់ ស្លៀកពាក់សទេ ក៏ពិតមែនហើយ ប៉ុន្តែការកោរសក់ ស្លៀកពាក់សនេះ ជាបវេណីមួយសំរាប់គ្រហស្ថ អ្នកកាន់សីល ១០ ក្នុងព្រះពុទ្ធសាសនា ជាគ្រឿងសំគាល់ ឱ្យឃើញប្លែកពីគ្រហស្ថទាំងឡាយទាំងពួង ទាំងជា

ភស្តុតាងដល់ផ្លូវចិត្ត របស់គ្រហស្ថអ្នកកាន់សីល ១០ នោះផងទៀត ប៉ុន្តែកុំយល់ថាដូចគ្នា នឹងអ្នកដែលស្លៀកពាក់សតាមធម្មតា ឬអ្នកដែលកោរសក់ កោរពុកមាត់ ពុកចង្ការតាមធម្មតា ឥតមានសមាទានកាន់សីលសោះឡើយ ។ អ្នកកាន់សីល និងអ្នកមិនកាន់សីល មានសមាសភាព មានសភាពផ្សេងគ្នា ផ្ទុយគ្នា ដោយផ្លូវចិត្ត ដោយចរិយា និងគុណសម្បត្តិសូម្បីអ្នកកាន់សីលផងគ្នា ក៏គង់តែផ្សេងទីទៃពីគ្នា ដោយសីលធម៌ដែរ គឺភិក្ខុមានសីលខ្ពស់ជាងសាមណេរ, សាមណេរ មានសីលខ្ពស់ជាងគ្រហស្ថអ្នកកាន់សីល ១០, គ្រហស្ថអ្នកកាន់សីល ១០ មានថ្នាក់ខ្ពស់ជាងអ្នកកាន់សីល ៨, អ្នកកាន់សីល ៨ មានថ្នាក់ខ្ពស់ជាងអ្នកកាន់សីល ៥ ។

អ្នកកាន់សីលទាំងនេះ សុទ្ធតែគួរគោរពគ្នាតាមលំដាប់ថ្នាក់សីល ទាំងតាមលំដាប់ថ្នាក់អាយុវស្សាចាស់ក្មេង ហើយនិងគុណសម្បត្តិផងទៀត ទើបសមគួរតាមលំអានគន្លងគារវធម៌ក្នុងព្រះពុទ្ធសាសនា និងបោរាណកធម៌ ក្នុងកាលព្រេងនាយ សូម្បីសត្វតិរច្ឆានធំតូច ដូចយ៉ាងសត្វទទា ស្វា ដំរី ដែលចេះគោរពគ្នា តាមលំដាប់ថ្នាក់អាយុចាស់ក្មេង អាចបានសុគតិភព ជាទិដ្ឋានុគតិឱ្យមនុស្សយកតំរាប់បានដែរ ។

## **វិធីភាវនា មាន ៣ យ៉ាង**

១- ឱ្យភាវនាថា : **ឥតិបិ សោ ភគវា, អរហំ សម្មាសម្ពុទ្ធោ ។បេ។ ពុទ្ធោ ភគវាតិ** ហើយភាវនាពីដើមមកទៀតទោះ ១ រយចប់ ១ ពាន់ចប់ តាមកម្លាំងសទ្ធា ។

២- ភាវនាថា : **សោ ភគវា ឥតិបិ អរហំ សោ ភគវា ឥតិបិ សម្មាសម្ពុទ្ធោ, សោ ភគវា ឥតិបិ វិជ្ជាចរណសម្បន្នោ ។ល។ សោ ភគវា ឥតិបិ ភគវា** ហើយត្រឡប់ពីដើមទៀតទោះ ១ រយ ចប់ ១ ពាន់ចប់ក៏បាន ។

៣- នឹងភាវនា ១ បទថា : **អរហំៗ** ឬថា **សម្មាសម្ពុទ្ធោៗ ។បេ។ ពុទ្ធោៗ** ឬថា **ភគវាៗ** ដូច្នេះក៏បានភាវនា ១ បទៗ ទោះបាន ១ រយចប់ក្តី ១ ពាន់ចប់ ក៏បានតាមពេញចិត្តរបស់ខ្លួន ត្រូវនឹករំពឹងដោយដឹងសេចក្តីផង ដូចមានបែបក្នុងត្រៃប្រណាមខាងដើមនោះ ស្រាប់ហើយ ។

## **បីតិ ៥ យ៉ាង**

**១-ខុទ្ទកា បីតិ** សេចក្តីត្រេកអរព្រឺរោមព្រឺស្បែក ។

**២-ខណិកា បីតិ** សេចក្តីត្រេកអរប្រាកដដូចជាផ្លេកបន្ទោរ ។

**៣-ឱក្កន្តិកា បីតិ** សេចក្តីត្រេកអរមានអាការប្រាកដ ដូចជារលកទឹកបោកផ្ទប់មកត្រូវ។

**៤-ឧព្វេង្គា បីតិ** សេចក្តីត្រេកអរខ្លាំង អាចញ៉ាំងកាយឱ្យអណ្តែតឡើង ។

**៥-ផរណា បីតិ** សេចក្តីត្រេកអរធ្វើឱ្យត្រជាក់ជ្រួតជ្រាបទូទៅក្នុងកាយ ។

## អង្គនៃនិច្ចសីល ឧបោសថសីល និង ទសសីល

### អង្គនៃនិច្ចសីល

បាណាតិបាត មានអង្គ ៥ :

១- **បាណោ** សត្វមានជីវិត ។

២- **បាណសញ្ញិតា** សេចក្តីដឹងថាសត្វមានជីវិត ។

៣- **វធកចិត្តំ** គិតនឹងសម្លាប់ ។

៤- **ឧបក្កមោ** ព្យាយាមនឹងសម្លាប់ ។

៥- **តេនមរណំ** សត្វស្លាប់ដោយព្យាយាមនោះ ។

អទិន្នាទាន មានអង្គ ៥ :

១- **បរបរិគ្គហិតំ** ទ្រព្យដែលមានម្ចាស់របស់គេហួងហែងរក្សា ។

២- **បរបរិគ្គហិតសញ្ញិតា** សេចក្តីដឹងថាទ្រព្យមានម្ចាស់របស់គេហួងហែងរក្សា ។

៣- **ថេយ្យចិត្តំ** គិតនឹងលួច ។

៤- **ឧបក្កមោ** ព្យាយាមនឹងលួច ។

៥- **តេន ហរណំ** លួចបានមកដោយព្យាយាមនោះ ។

កាមេសុមិច្ឆាចារ មានអង្គ ៤

១- **អគមនីយដ្ឋានំ** ស្ត្រីដែលមិនគួរនឹងគប់រក គឺស្ត្រីដែលមានគេហួងហែងរក្សា ។

២- **តស្មឹ សេវនចិត្តំ** គិតនឹងសេពនូវមេថុនធម្មនឹងស្ត្រីនោះ ។

៣- **ឧបក្កមោ** ព្យាយាមនឹងសេពនូវមេថុនធម្មនោះ ។

៤- **មគ្គេនមគ្គប្បដិបាទនំ** ញុំាងមគ្គនិងមគ្គឱ្យដល់គ្នា ។

### មុសាវាទ មានអង្គ ៤

១- **អតថំ វត្ថុ** វត្ថុមិនពិត។

២- **វិសំវាទនចិត្តំ** គិតនឹងពោលឱ្យខុស ។

៣- **តជ្ជោ វាយាមោ** ព្យាយាមនឹងពោលឱ្យខុស ។

៤- **បរស្ស តទត្ថវិជាននំ** ញុំាងអ្នកដទៃឱ្យដឹងច្បាស់ នូវសេចក្ដីនោះ ។

### សុរាមេរយ មានអង្គ ៤

១- **មទនីយវត្ថុ** វត្ថុជាទីតាំងនៃសេចក្ដីស្រវឹង គឺ សុរា និង មេរ័យ ។

២- **បាតុកម្យតាចិត្តំ** គិតបំរុងនឹងផឹក ។

៣- **តជ្ជោ វាយាមោ** ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ ។

៤- **តស្ស បាននំ** បានផឹកនូវទឹកស្រវឹងនោះឱ្យកន្លងបំពង់កចូលទៅ ។

## អង្គនៃឧបោសថសីល

អង្គនៃបាណាតិបាត និងអទិន្នាទាន ដូចនិច្ចសីល ខាងដើម ។

អព្រហ្មចរិយ មានអង្គ ៤

១- **ភេទនវត្ថុ** វត្ថុជាទីទំលាយនៃសីល គឺទ្វារទាំង ៣០ ចំពោះ ត្រង់ទ្វារណាមួយ។

២- **សេវនចិត្តំ** គិតនឹងសេព

៣- **តជ្ជោ វាយាមោ** ព្យាយាមនឹងសេពនូវមេថុនធម្មនោះ

៤- **មគ្គេន មគ្គប្បដិបាទនំ** ញុំាងមគ្គនិងមគ្គឱ្យដល់គ្នា ។

( អង្គនៃមុសាវាទ និង សុរាមេរ័យដូចនិច្ចសីលខាងដើម ) ។

វិកាលភោជនៈ មានអង្គ ៣

១- **វិកាលោ** កាលខុស គឺព្រះអាទិត្យជ្រេទៅហើយ ដរាបទល់នឹងអរុណរះ ។

២- **យាវកាលិកំ** របស់ដែលគួរបរិភោគបានក្នុងកាល គឺតាំងពីអរុណរះឡើងដរាបដល់ថ្ងៃត្រង់ ។

៣- **អជ្ឈោហរណំ** បានលេបចូលទៅក្នុងបំពង់ក ។

នច្ចគីតៈ ព្រមទាំងមាលា រួមគ្នាបានជាសិក្ខាបទមួយ មានអង្គ ៦

១- **នច្ចគីតាទិ** ការល្បែងមានរាំនិងច្រៀងជាដើម ។

២- **កត្តុកម្យតាចិត្តំ** គិតបំរុងនឹងធ្វើ ។

៣- **សុតឧស្សនត្ថាយគមនំ** ទៅដើម្បីនឹងស្តាប់ឬមើល ហើយបានស្តាប់ឬមើល ។

៤- **មាលាទិ** វត្ថុសំរាប់ប្រដាប់កាយមានផ្កាកម្រងជាដើម ។

៥- **ធារណច្ឆន្ទតា** សេចក្តីប្រាថ្នានឹងប្រដាប់តាក់តែង ។

៦- **តស្ស ធារណំ** បានប្រដាប់តាក់តែងនូវវត្ថុសំរាប់ប្រដាប់កាយ មានផ្កាកម្រងជាដើមនោះ ។

ឧច្ចាសយនៈ មានអង្គ ៣

១- **ឧច្ចាសយនមហាសយនំ** ទីដេកទីអង្គុយដ៏ខ្ពស់ ដ៏ប្រសើរហួសប្រមាណ ។

២- **បរិភោគចិត្តំ** គិតនឹងដេកឬអង្គុយ ។

៣- **បរិភោគករណំ** បានដេក ឬអង្គុយ ។

## អង្គនៃទសសីល

អង្គទាំង ៩ ខាងដើម ចាប់ពីបាណាតិបាតរហូតដល់ឧច្ចាសយនៈ មហាសយនាដូចសិក្ខាបទខាងដើម

ជាតរូប មានអង្គ ៣

**១-ជាតរូបរជតំ** មាសឬប្រាក់ដែលជាអកប្បិយភណ្ឌ

**២-អត្តុទ្ទិសតា** ចំពោះជារបស់ខ្លួន ។

**៣-បដិគ្គណ្ហាទិ** បានទទួលកាន់យកដោយខ្លួនឯង ឬប្រើគេឱ្យទទួលកាន់យកទុកដាក់ឱ្យ ហើយត្រេកអរចំពោះមាស ឬប្រាក់នោះ ដោយឧបាយឯណានីមួយ ។

កាលបើឧបាសក ប្រព្រឹត្តឱ្យកន្លងនូវសិក្ខាបទណាៗ លុះតែព្រមដោយអង្គក្នុងសិក្ខាបទនោះៗ ទើបបានឈ្មោះថា **កន្លង** បើមិនទាន់ព្រមដោយអង្គនោះ ក៏មិនបាន ឈ្មោះថាកន្លងនូវសិក្ខាបទនោះៗឡើយ ។

អង្គនិច្ចសីល ឧបោសថសីល និងទសសីល ចប់តែប៉ុណ្ណេះ

## អកុសលកម្មបថ ១០ យ៉ាង

I កាយកម្ម ៣ យ៉ាង

១- **បាណាតិបាតោ** កិរិយាសម្លាប់សត្វដោយកាយរបស់ខ្លួន ឬ ប្រើគេឱ្យសម្លាប់ដោយវាចា ។

២- **អទិន្នាទានំ** កិរិយាលួចលាក់ ឆក់ដណ្ដើមទ្រព្យ គេដោយកាយរបស់ខ្លួន ឬប្រើគេឱ្យលួចលាក់ឆក់ដណ្ដើមដោយវាចា ។

៣- **កាមេសុ មិច្ឆាចារោ** កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ គឺធ្វើនូវមេថុនសេវនៈនឹងស្ត្រី ដែលមានគេហួងហែងរក្សា ។

II វចីកម្ម ៤ យ៉ាង

១- **មុសាវាទោ** កិរិយាពោលនូវពាក្យកុហក ។

២- **បិសុណាវាចា** កិរិយាពោលនូវពាក្យញុះញង់ស៊កសៀតបំបែកបំបាក់អ្នកដទៃ។

៣- **ផរុសវាចា** កិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោក ជេរប្រទេចអ្នកដទៃជាដើម ។

៤- **សម្ផប្បលាបោ** កិរិយាពោលនូវពាក្យរោយរាយ ឥតប្រយោជន៍ ។

III មនោកម្ម ៣ យ៉ាង

**១- អភិជ្ឈា** ចិត្តសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបំរុងនឹងឱ្យបានមកជាទ្រព្យរបស់ខ្លួន ។

**២- ព្យាបាទ** ចិត្តចងគំនុំគុំកួន គិតប៉ងនឹងឱ្យអ្នកដទៃដល់នូវសេចក្ដីវិនាស ។

**៣- មិច្ឆាទិដ្ឋិ** គំនិតយល់ខុស ហើយប្រកាន់ឡើងថា ជាត្រូវ ។

## អង្គនៃអកុសលកម្មបថ

អង្គនៃបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ និងមុសាវាទ ដូចបានពោលមកក្នុងនិច្ចសីលខាងដើមហើយ ។

បិសុណាវាចា មានអង្គ ៤

**១- ភិន្ទិតព្វោ បរោ** អ្នកដទៃដែលមានរូបគឺខ្លួន គប្បីញុះញង់បំបែក ។

**២- ភេទនបុរេក្ខារតា** គិតនឹងញុះញង់បំបែកអ្នកដទៃនោះ ។

**៣- តជ្ជោ វាយាមោ** ព្យាយាមនឹងញុះញង់បំបែកបំបាក់អ្នកដទៃនោះ ។

៤- **គស្ស គនត្ថទីបានំ** ញ៉ាំងអ្នកនោះឱ្យដឹងច្បាស់នូវដំណើរដែលខ្លួនញុះញង់បំបែកបំបាក់នោះ ។

ផរុសវាចា មានអង្គ ៣

១- **អក្កោសិតព្វោ បរោ** អ្នកដទៃដែលមានរូបគឺ ខ្លួនគប្បីជេរប្រទេច ។

២-**កុប្បិតចិត្តំ** ចិត្តខឹងរន្ធត់ ។

៣-**អក្កោសនា** បានជេរប្រទេចគេ ។

សម្ផប្បលាបៈ មានអង្គ ២

១- **ភារតយុទ្ធសិតាហរណាទិនិរត្ថកថា** ពាក្យឥតប្រយោជន៍មានរឿងចំបាំងនៃមហាភារតៈ និងរឿងរាពណ៍ លួចនាំនាងសិតាយកទៅជាដើម ។

២- **តថារូបីកថាកថនំ** បានពោលនូវពាក្យឥតប្រយោជន៍មានសភាពដូច្នេះ ។

អភិជ្ឈា មានអង្គ ២

១- **បរភណ្ឌំ** ទ្រព្យជារបស់អ្នកដទៃ ។

២- **អត្តនោ បរិណាមនំ** គិតចង់បង្អោនទ្រព្យរបស់ អ្នកដទៃនោះឱ្យបានមកជាទ្រព្យរបស់ខ្លួន ដោយកលឧបាយផ្សេងៗ ។

ព្យាបាទ មានអង្គ ២

**១- បរសត្តោ** អ្នកដទៃក្រៅពីខ្លួន

**២-តស្ស តំ តំ វិនាសចិន្តា** គិតគុំកួនប្រុងនឹងឱ្យអ្នក នោះ ដល់នូវសេចក្តីវិនាសដោយហេតុនោះៗ ។

មិច្ឆាទិដ្ឋិ មានអង្គ ២

**១-វត្ថុនោ ច គហិតាការវិបរិតតា** ចិត្តប្រែប្រួល ដោយ អាការខុសអំពីព្រះរតនត្រ័យជាដើម ។

**២- យថា ច នំ គណ្ហាតិ តថាភាវេន តស្សូបដ្ឋានំ** គំនិត ដែលយល់ខុសនោះ ឃើញខុសយ៉ាងណា ក៏ប្រកាន់សេចក្តី ខុសនោះ ថា ជាត្រូវវិញ ។

អកុសលកម្មបថទាំង ១០ ប្រការ ដូចបានពោលមក ហើយនេះ ទោះត្រង់បទណាក្តី បើលុះតែព្រមដោយអង្គនោះៗ ទើបត្រូវទោសដល់អ្នកដែលប្រព្រឹត្តខុស អ្នកនោះនឹងបាននូវ សេចក្តីទុក្ខ សេចក្តីវិនាសក្នុងលោកនេះ និងបរលោកនាយ, បើទុកជាមិនទាន់ឱ្យផលឃើញច្បាស់ ក្នុងលោកនេះ លុះ ដល់ទៅក្នុងបរលោកនាយ ក៏គង់នឹងឱ្យផលដល់អ្នកនោះ ពុំ ខានឡើយ, បើមិនទាន់ព្រមដោយអង្គនោះៗ គឺថា បើនៅខ្វះ

អង្គណាមួយនោះ ក៏មិនទាន់បានឈ្មោះថា មានទោសក្នុងអកុសលកម្មបថដល់អ្នកដែលប្រព្រឹត្តខុសនោះឡើយ ។

អកុសលកម្មបថ ១០ ប្រការព្រមទាំងអង្គ
ចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

## កុសលកម្មបថ ១០ យ៉ាង

### I កាយកម្មមាន ៣ យ៉ាង

**១- បាណាតិបាតា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

**២- អទិន្នាទានា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យ ដោយកាយ ឬដោយវាចា ។

**៣- កាមេសុ មិច្ឆាចារា វេរមណី** ចេតនាជាហេតុ វៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

### II វចីកម្មមាន ៤ យ៉ាង

**១- មុសាវាទា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

**២- បិសុណាយ វាចាយ វេរមណី** ចេតនាជាហេតុ

វៀរចាកកិរិយាពោលនូវពាក្យញុះញង់ ស៊កសៀត បំបែកបំបាក់អ្នកដទៃ ។

៣- **ផរុសាយ វាចាយ វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះ បោះបោក ជេរប្រទេចអ្នកដទៃជាដើម ។

៤- **សម្ផប្បលាបា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។

## III មនោកម្មមាន ៣ យ៉ាង

១- **អនភិជ្ឈា** មិនមានចិត្តគិតសំឡឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបំរុងនឹងឱ្យបានមកជាទ្រព្យរបស់ខ្លួនឡើយ ។

២- **អព្យាបាទោ** មិនមានចិត្តចងគំនុំគុំកួន គិតប៉ងនឹងឱ្យអ្នកដទៃដល់នូវសេចក្តីវិនាសឡើយ ។

៣- **សម្មាទិដ្ឋិ** គំនិតយល់ឃើញត្រូវពិត ហើយប្រកាន់ឡើងថា ជាត្រូវមែន ។

អ្នកណាបានប្រព្រឹត្តត្រូវតាមកុសលកម្មបថទាំង ១០ ប្រការ ដូចបានពោលមកហើយនេះ អ្នកនោះនឹងមានសេចក្តី

សុខ សេចក្ដីចម្រើនក្នុងលោកទាំងពីរ គឺក្នុងមនុស្សលោកនេះ និង បរលោកនាយជាប្រាកដ ។

កុសលកម្មបថ ១០ ប្រការចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

## ធម៌ ៤០ យ៉ាង នាំសត្វទៅកាន់នរក

បិដក ៥១ ទំព័រ ២១២

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សំដែងអំពីបុគ្គលប្រកបដោយធម៌ ៤០ យ៉ាង

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤០ យ៉ាង នឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។

ធម៌ ៤០ យ៉ាងតើអ្វីខ្លះ ? គឺជាអ្នកសម្លាប់សត្វ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការសម្លាប់សត្វ ១ ពេញចិត្តក្នុងការសម្លាប់សត្វ ១ ពោលសរសើរគុណនៃការសម្លាប់សត្វ ១ កាន់យកទ្រព្យដែលគេមិនឱ្យ ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការកាន់យកទ្រព្យ ដែលគេមិនឱ្យ ១ ពេញចិត្តក្នុងការកាន់យកទ្រព្យដែលគេមិនឱ្យ ១ ពោលសរសើរគុណនៃការកាន់យកទ្រព្យដែលគេមិនឱ្យ ១ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ

ដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ពេញចិត្តក្នុងការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ពោលសរសើរគុណនៃការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ពោលពាក្យកុហកដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការពោលពាក្យកុហក ១ ពេញចិត្តក្នុងការពោលពាក្យកុហក ១ ពោលសរសើរគុណនៃការពោលពាក្យកុហក ១ ពោលពាក្យញុះញង់ដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការពោលពាក្យញុះញង់ ១ ពេញចិត្តក្នុងការពោលពាក្យញុះញង់ ១ ពោលសរសើរគុណនៃការពោលពាក្យញុះញង់ ១ ពោលពាក្យអាក្រក់ដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការពោលពាក្យអាក្រក់ ១ ពេញចិត្តក្នុងការពោលពាក្យអាក្រក់ ១ ពោលសរសើរគុណនៃការពោលពាក្យអាក្រក់ ១ ពោលពាក្យឥតប្រយោជន៍ដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការពោលពាក្យឥតប្រយោជន៍ ១ ពេញចិត្តក្នុងការពោលពាក្យឥតប្រយោជន៍ ១ ពោលសរសើរគុណនៃការពោលពាក្យឥតប្រយោជន៍ ១ ជាអ្នកមានអភិជ្ឈាដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងអភិជ្ឈា ១ ពេញចិត្តក្នុងអភិជ្ឈា ១ ពោលសរសើរគុណនៃអភិជ្ឈា ១ មានចិត្តព្យាបាទដោយខ្លួនឯង ១

បបួលអ្នកដទៃក្នុងការព្យាបាទ ១ ពេញចិត្តក្នុងការព្យាបាទ ១ ពោលសរសើរគុណនៃការព្យាបាទ ១ យល់ខុសដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការយល់ខុស ១ ពេញចិត្តក្នុងការយល់ខុស ១ ពោលសរសើរគុណនៃការយល់ខុស ១ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤០ យ៉ាងនេះឯង នឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។

## ធម៌ ៤០ យ៉ាង នាំសត្វទៅកាន់ស្ថានសួគ៌

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤០ យ៉ាងនេះ នឹងទៅកើតឯស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។

ធម៌ ៤០ យ៉ាងតើអ្វីខ្លះ ? គឺជាអ្នកវៀរចាកបាណាតិបាតដោយខ្លួនឯង ១ បបួលអ្នកដទៃ ក្នុងការវៀរចាកបាណាតិបាត ១ ពេញចិត្តក្នុងការវៀរចាកបាណាតិបាត ១ ពោលសរសើរគុណនៃការវៀរចាកបាណាតិបាត ១ វៀរចាកអទិន្នាទានដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការវៀរចាកអទិន្នាទាន ១ ពេញចិត្តក្នុងការវៀរចាកអទិន្នាទាន ១ ពោលសរសើរគុណនៃការវៀរចាកអទិន្នាទាន ១ វៀរចាកកាមេសុមិច្ឆាចារដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការវៀរចាកកាមេសុមិច្ឆាចារ ១

ពេញចិត្តក្នុងការវៀរចាកកាមេសុមិច្ឆាចារ ១ ពោលសរសើរគុណនៃការវៀរចាកកាមេសុមិច្ឆាចារ ១ វៀរចាកមុសាវាទដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការវៀរចាកមុសាវាទ ១ ពេញចិត្តក្នុងការវៀរចាកមុសាវាទ ១ ពោលសរសើរគុណនៃការវៀរចាកមុសាវាទ ១ វៀរចាកបិសុណវាចាដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការវៀរចាកបិសុណវាចា ១ ពេញចិត្តក្នុងការវៀរចាកបិសុណវាចា ១ ពោលសរសើរគុណនៃការវៀរចាកបិសុណវាចា ១ វៀរចាកផរុសវាចាដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការវៀរចាកផរុសវាចា ១ ពេញចិត្តក្នុងការវៀរចាកផរុសវាចា ១ ពោលសរសើរគុណនៃការវៀរចាកផរុសវាចា ១ វៀរចាកសម្ផប្បលាបៈដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការវៀរចាកសម្ផប្បលាបៈ ១ ពេញចិត្តក្នុងការវៀរចាកសម្ផប្បលាបៈ ១ ពោលសរសើរគុណនៃការវៀរចាកសម្ផប្បលាបៈ ១ ជាអ្នកមិនមានអភិជ្ឈាដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការមិនមានអភិជ្ឈា ១ ពេញចិត្តក្នុងការមិនមានអភិជ្ឈា ១ ពោលសរសើរគុណនៃការមិនមានអភិជ្ឈា ១ មិនមានព្យាបាទដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការមិនមានព្យាបាទ ១ ពេញចិត្តក្នុងការមិនព្យាបាទ ១ ពោលសរសើរ

គុណនៃការមិនព្យាបាទ ១ ជាអ្នកយល់ត្រូវដោយខ្លួនឯង ១ បបួលអ្នកដទៃក្នុងការយល់ត្រូវ ១ ពេញចិត្តក្នុងការយល់ត្រូវ ១ ពោលសរសើរគុណនៃការយល់ត្រូវ ១ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤០ យ៉ាងនេះឯង នឹងទៅកើតឯស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។

## ទោសនៃបុគ្គលទ្រុស្តសីលនិងអានិសង្សនៃបុគ្គលមានសីល

ក្នុងបិដកលេខ ៧ ទំព័រលេខ ៣០៣ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងជាមួយនឹងគហបតីទាំងឡាយថា ៖

ម្នាលគហបតីទាំងឡាយ ទោសទាំង ៥ ប្រការនេះ ជាទោសនៃបុគ្គលទ្រុស្តសីល[៦] ឬវិបត្តិចាកសីល ។ ទោសទាំង ៥ ប្រការនោះ តើដូចម្តេចខ្លះ ។ ម្នាលគហបតីទាំងឡាយ បុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីលក្នុងលោកនេះ តែងបាននូវសេចក្តីវិនាសនៃសម្បត្តិដ៏ច្រើន ហេតុមកពីសេចក្តីប្រមាទ ។ នេះ ជាទោសទី ១ នៃបុគ្គលទ្រុស្តសីល ឬ វិបត្តិចាកសីល ។

៦ ក្នុងតតិយសារត្ថទីបនីដីកា តតិយសមន្ត អធិប្បាយពីរយ៉ាង គឺបុគ្គលមិនបានសមាទានសីល ឬ សមាទានសីលហើយ ធ្វើសីលឱ្យដាច់ទៅវិញ ។

ម្នាលគហបតីទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីលហើយ តែងមានកិត្តិសព្ទអាក្រក់ឮខ្ចរខ្ចាយទៅ។ នេះជាទោសទី ២ នៃបុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល ។ ម្នាលគហបតីទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីលហើយ (បើ) ចូលទៅកាន់បរិសទ្យណា ។ ទោះបីជាខត្តិយបរិសទ្យក្តី ជាព្រាហ្មណបរិសទ្យក្តី ជាគហបតីបរិសទ្យក្តី ជាសមណបរិសទ្យក្តី ក៏គ្មានក្លៀវក្លាមាន តែមុខឱនចុះ ហើយដើរចូលទៅ ។ នេះជាទោសទី ៣ នៃបុគ្គលទ្រុស្តសីល ឬ វិបត្តិចាកសីល ។ ម្នាលគហបតីទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីលហើយ វេលាទៀបស្លាប់តែងវង្វេងស្មារតី ។ នេះជាទោសទី ៤ នៃបុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល ។ ម្នាលគហបតីទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គល ទ្រុស្តសីល ឬ វិបត្តិចាកសីលហើយ លុះរំលាងខន្ធបន្ទាប់អំពីមរណៈ រមែងទៅកាន់អបាយ[៧] (តិរច្ឆាន) ទុគ្គតិ[៨] (ប្រេត) វិនិបាត[៩] ( អសុរកាយ ) និរយ (នរក) ។ នេះជា

៧ ប្រទេសប្រាសចាកសេចក្តីសុខ ។ ៨ ទីគឺបណ្ឌិតគប្បីខ្ពើម ។ ៩ ចូរមើលវិន័យបិដក មហាវិភង្គភាគទី ១ ទំព័រ ១៤

ទោសទី ៥ នៃបុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល ។ ម្នាលគហបតី ទាំងឡាយទោសទាំង ៥ ប្រការនេះឯង ជាទោសនៃបុគ្គល ទ្រុស្ត សីល ឬវិបត្តិចាកសីល ។

ម្នាលគហបតីទាំងឡាយ អានិសង្សទាំង ៥ ប្រការនេះ ជាអានិសង្សនៃបុគ្គលមានសីល ឬបរិបូណ៌ដោយសីល ។ អានិសង្សទាំង ៥ ប្រការនេះ តើដូចម្តេចខ្លះ ។ ម្នាលគហបតីទាំងឡាយ បុគ្គលមានសីល ឬបរិបូណ៌ដោយសីល ក្នុងលោកនេះ តែងបាននូវគំនរនៃសម្បត្តិដ៏ច្រើន ហេតុមកពីសេចក្តីមិនប្រមាទ ។ នេះជាអានិសង្សទី ១ នៃបុគ្គលមានសីល ឬបរិបូណ៌ដោយសីល ។ ម្នាលគហបតីទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលមានសីល ឬ បរិបូណ៌ដោយសីលហើយ តែងមានកិត្តិសព្ទដ៏ពីរោះឮ ខ្ចរខ្ចាយទៅ ។ នេះជាអានិសង្សទី ២ នៃបុគ្គលមានសីល ឬ បរិបូណ៌ដោយសីល ។ ម្នាលគហបតីទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលមានសីល ឬ បរិបូណ៌ដោយសីលហើយ (បើ)ចូលទៅកាន់បរិសទ្យណា ។ ទោះបីជាខត្តិយបរិសទ្យក្តី ជាព្រាហ្មណបរិសទ្យក្តី ជាគហបតីបរិសទ្យក្តី ជាសមណបរិសទ្យក្តី ក៏ក្លៀវក្លា មិនឱនមុខចុះ គឺថាមិនក្រអឹមក្រអៀម ហើយដើរចូលទៅ ។

នេះជាអានិសង្សទី ៣ នៃបុគ្គលមានសីល ឬ បរិបូណ៌ដោយសីល ។ ម្នាលគហបតីទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលមានសីល ឬ បរិបូណ៌ដោយសីលហើយ លុះវេលាទៀបស្លាប់ ក៏មិនវង្វេងស្មារតីឡើយ ។ នេះជាអានិសង្សទី ៤ នៃបុគ្គលមានសីល ឬ បរិបូណ៌ដោយសីល ។ ម្នាលគហបតីទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលមានសីល ឬ បរិបូណ៌ដោយសីលហើយ លុះរំលាងខន្ធ បន្ទាប់អំពីមរណៈ រមែងទៅកាន់មនុស្សលោក ឬទេវលោក ។ នេះជាអានិសង្សទី ៥ នៃបុគ្គលមានសីល ឬ បរិបូណ៌ដោយសីល ។ ម្នាលគហបតីទាំងឡាយ អានិសង្សទាំង ៥ ប្រការនេះឯង ជាអានិសង្ស នៃបុគ្គលមានសីល ឬ បរិបូណ៌ដោយសីល ។

## បដិបទាប្រព្រឹត្តទៅនៃបុគ្គលទ្រុស្តសីល និង បុគ្គលមានសីល

ក្នុងបិដកលេខ ៤៨ ទំព័រ ១៨០ ព្រះសម្មាសម្ពុទ្ធ ជាម្ចាស់ទ្រង់ត្រាស់សំដែងថា :

ម្នាលភិក្ខុទាំងឡាយ បាណាតិបាត ដែលបុគ្គលសេពថ្មឹកហើយ ចម្រើនហើយ ធ្វើឱ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅដើម្បីបិត្តិវិស័យ ។

ផលនៃបាណាតិបាត ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅដើម្បីមានអាយុខ្លី ដល់កើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ អទិន្នាទានដែលបុគ្គលថ្នឹកហើយ ចម្រើនហើយ ធ្វើឱ្យច្រើនហើយ ប្រព្រឹត្តទៅដើម្បីនរក ប្រព្រឹត្តទៅដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅដើម្បីបិត្តិវិស័យ ។ ផលនៃអទិន្នាទានដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅដើម្បីវិនាសនៃភោគៈ ដល់កើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ កាមេសុមិច្ឆាចារ ដែលបុគ្គលថ្នឹកហើយ ចម្រើនហើយ ធ្វើឱ្យច្រើនហើយ ប្រព្រឹត្តទៅដើម្បីនរក ប្រព្រឹត្តទៅដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅដើម្បីបិត្តិវិស័យ ។ ផលនៃកាមេសុមិច្ឆាចារដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅដើម្បីសត្រូវនិងពៀរដល់កើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ មុសាវាទដែលបុគ្គលថ្នឹកហើយ ចម្រើនហើយ ធ្វើឱ្យច្រើនហើយ ប្រព្រឹត្តទៅដើម្បីនរក ប្រព្រឹត្តទៅដើម្បីកំណើត តិរច្ឆានប្រព្រឹត្តទៅដើម្បីបិត្តិវិស័យ ។ ផលនៃមុសាវាទដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅដើម្បីគេពោលបង្កាច់ដោយពាក្យមិនពិតដល់កើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ បិសុណាវាចាដែលបុគ្គលថ្នឹកហើយ ចម្រើនហើយ ធ្វើឱ្យច្រើនហើយ

ប្រព្រឹត្តទៅដើម្បីនរក ប្រព្រឹត្តទៅដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅដើម្បីបិត្តិវិស័យ ។ ផលនៃបិសុណាវាចា ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅដើម្បីបែកបាក់ចាកមិត្ត ដល់កើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ ផរុសវាចាដែលបុគ្គលថ្នឹកហើយ ចម្រើនហើយ ធ្វើឱ្យច្រើនហើយ ប្រព្រឹត្តទៅដើម្បីនរក ប្រព្រឹត្តទៅដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅដើម្បីបិត្តិវិស័យ ។ ផលនៃផរុសវាចា ដែលស្រាល ជាងផលទាំងអស់ រមែងប្រព្រឹត្តទៅដើម្បីសម្លេងមិនជាទីគាប់ចិត្ត ដល់កើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយសម្ផប្បលាបៈ ដែលបុគ្គលថ្នឹកហើយ ចម្រើនហើយ ធ្វើឱ្យច្រើនហើយ ប្រព្រឹត្តទៅដើម្បីនរក ប្រព្រឹត្តទៅដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅដើម្បីបិត្តិវិស័យ ។ ផលនៃសម្ផប្បលាបៈ ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅដើម្បីពាក្យដែលមិនគួរកាន់យក ដល់កើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ ការផឹកនូវសុរា និង មេរ័យ ដែលបុគ្គលថ្នឹកហើយចម្រើនហើយ ធ្វើឱ្យច្រើនហើយ ប្រព្រឹត្តទៅដើម្បីនរក ប្រព្រឹត្តទៅដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅដើម្បីបិត្តិវិស័យ ។ ផលនៃការផឹកនូវសុរា និង មេរ័យ ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅដើម្បីភាព

ជាមនុស្សឆ្កួត ដល់កើតជាមនុស្ស ។

ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃបុណ្យ អានិសង្សនៃកុសល ជាអាហារនៃសេចក្តីសុខ ជាធម៌ឱ្យនូវអារម្មណ៍ដ៏ល្អលើស ជាផលនៃសេចក្តីសុខ ប្រព្រឹត្តទៅដើម្បីសួគ៌ ៨ យ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីត្រេកអរ ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ។ អានិសង្សនៃបុណ្យ អានិសង្សនៃកុសល ៨ យ៉ាងដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ ជាអ្នកដល់នូវព្រះពុទ្ធជាទីពឹង ម្នាលភិក្ខុទាំងឡាយនេះ ជាអានិសង្សនៃបុណ្យ អានិសង្សនៃកុសល ជាអាហារនៃសេចក្តីសុខ ជាធម៌ឱ្យនូវអារម្មណ៍ដ៏ល្អលើស ជាផលនៃសេចក្តីសុខ ប្រព្រឹត្តទៅដើម្បីសួគ៌ទី ១ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីត្រេកអរ ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីពេញចិត្ត ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវ័កជាអ្នកដល់នូវព្រះធម៌ជាទីពឹង ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្ស នៃបុណ្យទី ២ ។បេ។ រមែងប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវ័ក ជាអ្នកដល់នូវព្រះសង្ឃជាទីពឹង នេះជាអានិសង្សនៃបុណ្យ អានិសង្សនៃកុសល ជា

អាហារនៃសេចក្តីសុខ ជាធម៌ឱ្យនូវអារម្មណ៍ដ៏ល្អលើស ជាផលនៃសេចក្តីសុខ ប្រព្រឹត្តទៅដើម្បីសួគ៌ទី ៣ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីត្រេកអរ ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីពេញចិត្ត ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ ទានទាំង ៥ យ៉ាងនេះ ចាត់ជាមហាទាន ដែលអ្នកប្រាជ្ញដឹងថា ជារបស់ប្រសើរ ដឹងថា ជារបស់ប្រព្រឹត្តទៅអស់រាត្រីយូរ ដឹងថា ជាវង្ស ( នៃកល្យាណជន ) ជារបស់មានមកក្នុងកាលមុន ជារបស់មិនរោយរាយ ជារបស់មិនធ្លាប់រោយរាយហើយ រមែងមិនខ្វាត់ខ្វាយ ( ក្នុងកាលឥឡូវនេះ ) នឹងមិនខ្វាត់ខ្វាយ ( ក្នុងអនាគត ) ពួកសមណព្រាហ្មណ៍ ជាវិញ្ញូជន ក៏មិនដែលតិះដៀលឡើយ ។ ទាន ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ លះបង់បាណាតិបាត វៀរចាកបាណាតិបាត ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក ជាអ្នកវៀរចាកបាណាតិបាត ឈ្មោះថា ឱ្យនូវអភ័យ ឱ្យនូវអំពើមិនមានពៀរ ឱ្យនូវអំពើមិនមានទុក្ខដល់សត្វទាំងឡាយ មានប្រមាណមិនបាន លុះឱ្យនូវអភ័យ ឱ្យនូវអំពើមិនមានពៀរ ឱ្យនូវអំពើមិនមានទុក្ខដល់សត្វទាំងឡាយមានប្រមាណមិនបានហើយ រមែងជាអ្នកមានចំណែកនៃសេចក្តី

មិនមានភ័យ មិនមានពៀរ មិនមានទុក្ខ មានប្រមាណមិនបានវិញ ។ ម្នាលភិក្ខុទាំងឡាយនេះ ជាទានទី ១ ចាត់ជាមហាទានដែលអ្នកប្រាជ្ញ ដឹងថា ជារបស់ប្រសើរ ដឹងថា ជារបស់ប្រព្រឹត្តទៅអស់រាត្រីយូរ ដឹងថា ជាវង្ស ( នៃកល្យាណជន ) ជារបស់មានមកក្នុងកាលមុន ជារបស់មិនរោយរាយ មិនធ្លាប់រោយរាយហើយ រមែងមិនខ្វាត់ខ្វាយ នឹងមិនខ្វាត់ខ្វាយ ពួកសមណព្រាហ្មណ៍ ជាវិញ្ញូជន ក៏មិនដែលតិះដៀលឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សនៃបុណ្យ អានិសង្សនៃកុសល ជាអាហារនៃសេចក្តីសុខ ជាធម៌ឱ្យនូវអារម្មណ៍ដ៏ល្អលើស ជាផលនៃសេចក្តីសុខ ប្រព្រឹត្តទៅដើម្បីសួគ៌ទី ៤ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីត្រេកអរ ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន ។ល។ លះបង់កាមេសុមិច្ឆាចារ វៀរចាកកាមេសុមិច្ឆាចារ ។ល។ លះបង់មុសាវាទ វៀរចាកមុសាវាទ ។ល។ លះបង់សុរាមេរយមជ្ជ-ប្បមាទដ្ឋាន វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ឈ្មោះថាឱ្យនូវអភ័យ ឱ្យនូវអំពើមិនមានពៀរ ឱ្យនូវអំពើមិនមានទុក្ខដល់សត្វទាំងឡាយ មានប្រមាណមិនបាន លុះឱ្យនូវអភ័យឱ្យ

នូវអំពើមិនមានពៀរ ឱ្យនូវអំពើមិនមានទុក្ខ ដល់សត្វទាំងឡាយ មានប្រមាណមិនបានហើយ រមែងជាអ្នកមានចំណែកនៃសេចក្តី មិនមានភ័យ មិនមានពៀរ មិនមានទុក្ខ មានប្រមាណមិន បានវិញ ម្នាលភិក្ខុទាំងឡាយនេះជាទានទី ៥ ចាត់ជាមហា ទានដែលអ្នកប្រាជ្ញដឹងថា ជារបស់ប្រសើរ ដឹងថា ជារបស់ ប្រព្រឹត្តទៅអស់រាត្រីយូរ ដឹងថា ជាវង្ស ( នៃកល្យាណជន ) ជា របស់មានមកក្នុងកាលមុន មិនរោយរាយ មិនធ្លាប់រោយ រាយហើយ រមែងមិនខ្វាត់ខ្វាយ នឹងមិនខ្វាត់ខ្វាយ ពួកសមណ ព្រាហ្មណ៍ ជាវិញ្ញូជន ក៏មិនដែលតិះដៀលឡើយ ម្នាលភិក្ខុ ទាំងឡាយ នេះជាអានិសង្សនៃបុណ្យ អានិសង្សនៃកុសល ជា អាហារនៃសេចក្តីសុខ ជាធម៌ឱ្យនូវអារម្មណ៍ដ៏ល្អលើស ជាផល នៃសេចក្តីសុខ ប្រព្រឹត្តទៅដើម្បីស្ួគ៌ទី ៨ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រេកអរ ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សនៃ បុណ្យ អានិសង្សនៃកុសល ជាអាហារនៃសេចក្តីសុខ ជាធម៌ឱ្យ នូវអារម្មណ៍ដ៏ល្អលើស ជាផលនៃសេចក្តីសុខ ប្រព្រឹត្តទៅ ដើម្បីស្ួគ៌ទី ៨ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រេកអរ ដើម្បី សេចក្តីរីករាយ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ។

## អានិសង្សសីល ៥

បញ្ចសីលសមាទានិយត្ថេរាបទាន ក្នុងបិដកលេខ ៧២ ទំព័រ ១៧៣ ។

គ្រានោះ ខ្ញុំកើតជាបុរសអ្នកស៊ីឈ្នួល ក្នុងក្រុងចន្ទវតី ខ្ញុំរវល់តែនឹងការងាររបស់ជនដទៃ មិនបានទូវបព្វជ្ជា ។ ខ្ញុំគិតថា បុគ្គលទាំងឡាយ ដែលត្រូវងងឹតធំបិទបាំងហើយ រមែងឆេះដោយភ្លើង ៣ យ៉ាង អញគប្បីគេចចេញ ដោយឧបាយណាហ្ន៎ ។ អញជាមនុស្សកំព្រា ធ្វើនូវការឈ្នួលទាំងទេយ្យធម៌របស់អញក៏មិនមាន បើដូច្នោះគួរតែអញរក្សាសីល ៥ ឱ្យពេញលេញ ។ មានព្រះថេរៈមួយ អង្គឈ្មោះ **និសភៈ** ជាសាវ័ករបស់ព្រះមុនី ព្រះនាម អនោមទស្សី ខ្ញុំក៏ចូលទៅរកព្រះថេរៈអង្គនោះ ហើយទទួលនូវសិក្ខាបទទាំង ៥ ក្នុងសម័យនោះ អាយុ (របស់សត្វ) មានប្រមាណមួយសែនឆ្នាំ ខ្ញុំរក្សាសីល ៥ ឱ្យបរិបូណ៌ អស់កាលប៉ុណ្ណោះដែរ ។ លុះមរណកាលមកដល់ព្រមហើយ ទេវតាទាំងឡាយលួងលោមខ្ញុំថា នែអ្នកនិទ៌ុក្ខ រថដែលទឹមដោយសេះ ១ ពាន់នេះ មកប្រាកដដល់អ្នកហើយ ។ កាលបើចិត្តជាខាងក្រោយ កំពុងប្រព្រឹត្តទៅ

ខ្ញុំបានរំលឹកនូវសីលរបស់ខ្ញុំ ខ្ញុំបានទៅកាន់ឋានតាវត្តិង្ស ដោយសារអំពើដែលខ្ញុំធ្វើល្អហើយនោះ ។ ខ្ញុំបានជាធំជាងទេវតា សោយទេវរាជ្យ មានពួកស្រីអប្សរចោមរោម សោយសេចក្តីសុខដ៏ជាទិព្វអស់ ៣០ ដង ។ ខ្ញុំបានជាស្តេចចក្រពត្តិ អស់ ៧៥ ដង បានសោយប្រទេសរាជ្យដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យជាតិ ។ ខ្ញុំច្យុតចាកទេវលោក ត្រូវកុសលមូលដាស់តឿន ក៏មកកើតក្នុងត្រកូលមហាសាលដ៏ស្តុកស្តម្ភ ក្នុងក្រុងសាវត្ថី ។ កាលសាសនារបស់ព្រះជិនស្រី កំពុងរុងរឿង មាតានិងបិតារបស់ខ្ញុំបាន ទទួលនូវសិក្ខាបទទាំង ៥ ក្នុងកាលជិតចូលវស្សា ។ ខ្ញុំបានទទួលសីលជាមួយ (និងមាតា) ហើយបានរលឹកឃើញនូវសីលរបស់ខ្ញុំ ខ្ញុំអង្គុយលើអាសនៈ ១ ហើយបានដល់នូវអរហត្ត ។ ខ្ញុំមានអាយុ ៥ ឆ្នាំអំពីកំណើត បានដល់នូវអរហត្ត ព្រះពុទ្ធមានចក្ខុ ទ្រង់ជ្រាបនូវគុណ (របស់ខ្ញុំ) ហើយទ្រង់ឱ្យឧបសម្បទាជាភិក្ខុដល់ខ្ញុំ ។ ខ្ញុំរក្សានូវសិក្ខាបទទាំង ៥ ពេញលេញ ខ្ញុំមិនដែលទៅកាន់កំណើត អសុរកាយ អស់កប្ប នឹងប្រមាណមិនបានអំពីភទ្ទកប្បនេះ ។ ខ្ញុំនោះបានទទួលនូវយស ព្រោះហេតុនៃសីលទាំងនោះ ខ្ញុំកាលសំដែង

នូវកោដិនៃកប្ប គប្បីសំដែងជាឯកទេស (មួយចំណែកៗ) ។ ខ្ញុំរក្សាសីល ទាំង ៥ ហើយបាននូវត្រៃហេតុ គឺខ្ញុំជាអ្នកមានអាយុវែង ១ មានទ្រព្យច្រើន ១ មានប្រាជ្ញាមោះមុត ១ ។ មួយទៀត ខ្ញុំសំដែងនូវភាពនៃខ្លួនជាបុរសដ៏ក្រៃលែងជាងជនទាំងពួង អន្ទោលទៅក្នុងភពតូច និងភពធំ ហើយតែងបាននូវឋានៈទាំងនុ៎ះ ។ សាវ័កទាំងឡាយ របស់ព្រះជិនស្រីកាលប្រព្រឹត្ត ក្នុងសីលនឹងប្រមាណមិនបាន បើលោកនៅត្រេកអរក្នុងភព តើនឹងបានផលដូចម្តេចទៅ ។ សីល ៥ ដែលខ្ញុំជាអ្នកស៊ីឈ្នួលគេ មានព្យាយាមប្រព្រឹត្តល្អហើយ ខ្ញុំបានរួចចាកចំណងទាំងពួង ក្នុងថ្ងៃនេះដោយសារសីលនោះ ។ ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំរក្សាសីល ៥ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសីល ៥ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបញ្ចសីលសមាទានិយត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ឧបោសថសូត្រ

ស្រង់ចេញពីព្រហ្មចរិយកថា ព្រះមហាឧបាលិវង្ស ម៉ឹង សែស ។

ឯឧបោសថនោះ មាននៅក្នុងឧបោសថសូត្រ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សំដែង ដែលមានមកក្នុងគម្ពីរ អង្គុត្តរនិកាយតិកនិបាត លេខ ៤១ ទំព័រ ២៥៩ មានសេចក្តីក្នុងសូត្រនោះថា

សម័យមួយព្រះដ៏មានបុណ្យ ទ្រង់គង់នៅនាមិគារមាតុ-ប្រាសាទក្នុងវត្តបុព្វារាម ទៀបនគរសាវត្ថី ។ គ្រានោះ នាងវិសាខាមិគារមាតា ចូលទៅគាល់ព្រះដ៏មានបុណ្យ លុះចូលទៅដល់ហើយក្រាបថ្វាយបង្គំ រួចអង្គុយនៅក្នុងទីដ៏សមគួរ លុះនាងអង្គុយនៅក្នុងទីសមគួរហើយ ព្រះដ៏មានបុណ្យ ទ្រង់ត្រាស់សួរថា ម្នាលនាងវិសាខា ចុះនាងមកអំពីណាក្នុងវេលាព្រឹកព្រហាមម្ល៉េះមានកិច្ចអ្វី ។ នាងក្រាបទូលថា ខ្ញុំព្រះអង្គមករក្សាឧបោសថក្នុងថ្ងៃនេះ ។ ព្រះអង្គទ្រង់សំដែងថា ម្នាលនាងវិសាខា ឯឧបោសថនោះ មាន ៣ ប្រការគឺ គោបាលកុបោសថៈ ១ និគ្គណ្ឋុបោសថៈ ១ អរិយុបោសថៈ ១ ។ ឯគោបាលកុបោសថៈ

នោះ គឺ ឧបោសថរបស់បុគ្គល ជាអ្នករក្សាដែលមានគំនិត ចិត្តដូចជាអ្នកឃ្វាលគោ ម្នាលនាងវិសាខា បុរសអ្នកឃ្វាលគោ តែវេលាល្ងាចប្រគល់គោឱ្យម្ចាស់គេវិញ ហើយរមែងពិចារណា ថា ថ្ងៃនេះ គោវាត្រាច់ទៅក្នុងប្រទេសឯនោះៗ បានផឹកទឹក ក្នុងប្រទេសឯនោះៗ ថ្ងៃស្អែកនេះ គោវានឹងត្រាច់ទៅក្នុងប្រទេស ឯនោះៗ វានឹងផឹកទឹកក្នុងប្រទេសឯនោះៗ យ៉ាងណាមិញ ។ បុគ្គលពួកមួយក្នុងសាសនានេះរក្សាឧបោសថ ហើយពិចារណា ថា ថ្ងៃនេះ អាត្មាអញស៊ីខាទនីយៈនេះៗ បរិភោគភោជនីយៈ នេះៗ ស្អែកនេះទៀត អាត្មាអញនឹងស៊ីខាទនីយៈនេះៗ បរិភោគ ភោជនីយៈនេះៗឯង ។ បុគ្គលមានចិត្តប្រកបដោយសេចក្តី លោភៈ រក្សាឧបោសថយ៉ាងនោះឯង គោបាលកុបោសថៈ នោះយ៉ាងនេះ ។ ម្នាលនាងវិសាខា ឯគោបាលកុបោសថៈ ដែលបុគ្គលរក្សាយ៉ាងនេះ ហើយមិនមានផលច្រើន មិនមាន អានិសង្សច្រើនឡើយ ។ ឯនិគណ្ឋុបោសថៈនោះ គឺ ឧបោសថ របស់ពួកនិគ្រន្ថតិរ្ថិយ ម្នាលនាងវិសាខា មានពួកនិគ្រន្ថជា ពួកអ្នកបួស តែពួកនិគ្រន្ថនោះ រមែងប្រដៅសាវ័កថា ម្នាល បុរសដ៏ចម្រើន អ្នកចូរមកពួកសត្វឯណា ដែលនៅក្នុងទិស

ខាងកើតហួសកំណត់ ១០០ យោជន៍ ទៅពួកសត្វនោះ អ្នកឯងកុំសម្លាប់វា ។ ពួកសត្វឯណា ដែលនៅក្នុងទិសខាងលិចហួសកំណត់ ១០០ យោជន៍ទៅ ពួកសត្វនោះ អ្នកឯងកុំសម្លាប់វា ពួកសត្វឯណាដែលនៅក្នុងទិសខាងជើង ហួសកំណត់ ១០០ យោជន៍ទៅ ពួកសត្វនោះ អ្នកឯងកុំសម្លាប់វា ។ ពួកសត្វឯណាដែលនៅក្នុងទិសខាងត្បូងហួសកំណត់ ១០០ យោជន៍ទៅ ពួកសត្វនោះ អ្នកឯងកុំសម្លាប់វា ។ ពួកនិគ្រន្ថនោះ ប្រដៅបបួលគេដោយសេចក្តីអាណិតអាសូរដល់សត្វខ្លះ មិនអាណិតអាសូរដល់សត្វខ្លះ ដូច្នេះ ។ ពួកនិគ្រន្ថនោះ រមែងប្រដៅសាវ័កក្នុងថ្ងៃឧបោសថថា ម្នាលបុរសដ៏ចម្រើន អ្នកឯងចូរមក អ្នកឯងចូរយកសំពត់ស្លៀកដណ្តប់ទាំងអស់ ចេញអំពីខ្លួនហើយនិយាយថា អាត្មាអញគ្មានកង្វល់អំពល់ នឹងរបស់អ្វីមួយឡើយការកង្វល់អំពល់នឹងគ្រឿងប្រដាប់ណានិមួយ មិនមានដល់អាត្មាអញឡើយ ។ មាតាបិតារបស់បុគ្គលនោះ គង់ដឹងថានេះជាកូនរបស់យើង ចំណែកបុគ្គលនោះក៏គង់ដឹងថា នេះជាមាតាបិតារបស់យើង ។ កូនប្រពន្ធរបស់បុគ្គលនោះ គង់ដឹងថា នេះជាភស្តារបស់យើង ចំណែកបុគ្គលនោះគង់ដឹងថា

នេះជាកូនប្រពន្ធរបស់យើង ។ ខ្ញុំនិងបុរសជាកម្មកររបស់បុគ្គលនោះ គង់ដឹងថា នេះជាម្ចាស់របស់យើងចំណែកបុគ្គលនោះក៏គង់ដឹងថា នេះជាខ្ញុំនិងបុរសជាកម្មកររបស់យើង ។ និគណ្ឋុបោសថៈ (ឧបោសថរបស់និគ្រន្ថ) យ៉ាងនេះឯង ។ ម្នាលនាងវិសាខា និគណ្ឋុបោសថៈ ដែលបុគ្គលរក្សាយ៉ាងនេះ មិនមានផលច្រើន មិនមានអានិសង្សច្រើនឡើយ ។ ឯ អរិយុបោសថៈនោះ គឺឧបោសថរបស់ព្រះអរិយសាវ័ក ។ ម្នាលនាងវិសាខា វិធីធ្វើចិត្តដែលសៅហ្មងឱ្យផូរផង់ស្អាតល្អ ដោយឧបាយ រមែងមាន គឺព្រះអរិយសាវ័កក្នុងសាសនានេះ ជាអ្នករក្សាឧបោសថ រមែងរឭកព្រះតថាគតថា ព្រះដ៏មានព្រះភាគនោះ ព្រះអង្គឆ្ងាយចាកកិលេសហើយ ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ដោយខ្លួនឯងដោយត្រូវពិត ឥតមានខុស ព្រះអង្គបរិបូរណ៍ដោយវិជ្ជា និងចរណៈ ព្រះអង្គពោលនូវពាក្យពីរោះ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរ ដោយគុណមានសីលជាដើម ព្រះអង្គជានាយសារថី ទូន្មាននូវបុរសដែលគួរទូន្មាន ព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវសច្ចៈទាំង ៤ ហើយញុំាងអ្នកដទៃឱ្យត្រាស់ដឹងផង

ព្រះអង្គមានគុណធម៌ ដែលអ្នកប្រាជ្ញគប្បីសេព កាលបើព្រះអរិយសាវ័ក រឭកនឹកព្រះតថាគតដូច្នេះ ហើយចិត្តក៏ជ្រះថ្លាឡើង បាមោជ្ជៈ គឺសេចក្តីរីករាយក៏កើតឡើង នីវរណធម៌ឯណាដែលជាគ្រឿងសៅហ្មងនៃចិត្ត នីវរណធម៌នោះ ក៏សាបសូន្យទៅ ប្រៀបដូចការកក់ជំរះក្បាល ដែលសៅហ្មងឱ្យជ្រះស្អាតដោយឧបាយបាន ក៏អាស្រ័យនឹងកាកផ្លែកន្ទួតព្រៃ អាស្រ័យនឹងដីស្អិត អាស្រ័យនឹងទឹក អាស្រ័យនឹងព្យាយាមរបស់បុរសដែលខំប្រឹងដុសលាង ម្នាលនាងវិសាខា ព្រះអរិយសាវ័កនោះ បានឈ្មោះថា រក្សាព្រហ្មុបោសថៈ បានឈ្មោះថា នៅជាមួយនឹងព្រះព្រហ្ម គឺព្រះពុទ្ធ ចិត្តរបស់អរិយសាវ័កនោះ ប្រារព្ធនូវព្រះព្រហ្ម គឺព្រះពុទ្ធ ហើយក៏ជ្រះថ្លាឡើង បាមោជ្ជៈ គឺសេចក្តីរីករាយក៏កើតឡើង នីវរណធម៌ឯណា ដែលជាគ្រឿងសៅហ្មងដល់ចិត្ត នីវរណធម៌នោះ ក៏សាបសូន្យទៅ ។

ម្នាលនាងវិសាខា មានវិធីធ្វើចិត្តដែលសៅហ្មង ឱ្យផូរផង់ ឱ្យស្អាតល្អដោយឧបាយ ១ បែបទៀត គឺអរិយសាវ័កក្នុងសាសនានេះ ជាអ្នករក្សាឧបោសថ រមែងរឭកនឹកព្រះធម៌ថា ព្រះបរិយត្តិធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងទុក

ល្អហើយ ព្រះនវលោកុត្តរធម៌ជាធម៌ គឺព្រះអរិយបុគ្គល គប្បីឃើញដោយខ្លួនឯង ជាធម៌ឱ្យផលមិនបង្អង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី គឺហៅអ្នកដទៃឱ្យចូរមកមើលបាន ជាធម៌គួរនឹងនាំយកមកទុកក្នុងចិត្តនៃខ្លួន ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយ គប្បីដឹងជាក់ច្បាស់ កាលបើព្រះអរិយសាវ័កនោះនឹករឭកនូវព្រះធម៌ដូច្នេះហើយ ចិត្តក៏ជ្រះថ្លាឡើង បាមោជ្ជៈ គឺ សេចក្តីរីករាយក៏កើតមានឡើង នីវរណធម៌ណា ដែលជាគ្រឿងសៅហ្មងដល់ចិត្ត នីវរណធម៌នោះ ក៏សាបសូន្យទៅប្រៀបដូចជាជំរះកាយដែលសៅហ្មង ឱ្យជ្រះស្អាតដោយឧបាយបាន ក៏អាស្រ័យខ្សែអម្បោះ សោត្តិ[(១០)] អាស្រ័យគ្រឿងលំអិតសំរាប់ងូត អាស្រ័យទឹក អាស្រ័យសេចក្តីព្យាយាមរបស់បុរសដែល ខំប្រឹងដុសលាង ម្នាលនាងវិសាខា ព្រះអរិយសាវ័កនេះបានឈ្មោះថា រក្សានូវធម្មុបោសថៈ បានឈ្មោះថា នៅជាមួយនឹងធម៌ ចិត្តរបស់អរិយសាវ័កនោះ ប្រារព្ធនូវធម៌ហើយ ក៏ជ្រះថ្លា

---

[១០] អដ្ឋកថាថា ខ្សែនោះ គេយកជាតិល័ខមកលាយនឹងលំអិតថ្មឈ្មោះកុរុវិន្ទកៈ ហើយសូន្យឱ្យជាដុំចោះត្រង់កណ្តាល ដោតខ្សែអម្បោះសម្រាប់កាន់ចុងខ្សែទាំងសងខាងដុសខ្នងក្នុងវេលាងូតទឹក។ (មានក្នុងខុទ្ទកៈវត្ថុខន្ធកគម្ពីរចុល្លវគ្គ)។

ឡើងបាមោជ្ជៈ គឺសេចក្តីរីករាយក៏កើតឡើង នីវរណធម៌ឯណា ដែលជាគ្រឿងសៅហ្មងដល់ចិត្ត នីវរណធម៌នោះ ក៏សាបសូន្យទៅ ។

ម្នាលនាងវិសាខា មានវិធីធ្វើចិត្តដែលសៅហ្មង ឱ្យផូរផង់ស្អាតល្អដោយឧបាយ ១ បែបទៀត គឺព្រះអរិយសាវ័កក្នុងសាសនា នេះជាអ្នករក្សាឧបោសថ រមែងរឭកនូវព្រះសង្ឃថា ពពួកនៃសាវ័ករបស់ព្រះដ៏មានព្រះភាគ ប្រតិបត្តិហើយដោយញាយធម៌ គឺព្រះនិព្វាន ពពួកនៃសាវ័ករបស់ព្រះដ៏មានព្រះភាគ ប្រតិបត្តិហើយដោយសមគួរ ឯពពួកនៃសាវ័កនេះ បើរាប់ជាគូនៃបុរសនេះមាន ៤ គូ បើរាប់ជាបុរសបុគ្គលរៀងទៅបាន ៨ ពពួកនៃសាវ័ករបស់ព្រះដ៏មានព្រះភាគនេះ គួរទទួលនូវគ្រឿងសក្ការៈ ដែលគេនាំមកអំពីចម្ងាយហើយបូជា គួរទទួលនូវគ្រឿងសក្ការៈ ដែលគេតាក់តែងដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរគេធ្វើនូវអញ្ជលិកម្ម ជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក កាលបើព្រះអរិយសាវ័កនោះ នឹករឭកព្រះសង្ឃដូច្នេះ ហើយចិត្តក៏ជ្រះថ្លាឡើង បាមោជ្ជៈ គឺសេចក្តីរីករាយក៏កើតឡើង នីវរណធម៌ឯណា ដែលជាគ្រឿងសៅហ្មងដល់ចិត្ត នីវរណធម៌នោះ ក៏សាបសូន្យទៅ ប្រៀប

ដូចការបោកលាងសំពត់ដែលសៅហ្មង ឱ្យជ្រះស្អាតដោយឧបាយបាន ក៏អាស្រ័យនឹងចំហាយអប់កំដៅដែលគេស្ងោរ អាស្រ័យទឹកក្បុង អាស្រ័យទឹកនោមគោ អាស្រ័យទឹក អាស្រ័យព្យាយាមរបស់បុគ្គលដែលខំប្រឹងដុសលាង ម្នាលនាងវិសាខា ព្រះអរិយសាវ័កនេះ បានឈ្មោះថា រក្សានូវសង្ឃុបោសថៈ បានឈ្មោះថា នៅជាមួយនឹងសង្ឃ ចិត្តរបស់ព្រះអរិយសាវ័កនោះប្រារព្ធនូវសង្ឃ ហើយក៏ជ្រះថ្លាឡើង បាមោជ្ជៈ គឺសេចក្តីរីករាយក៏កើតមានឡើង នីវរណធម៌ឯណា ដែលជាគ្រឿងសៅហ្មងដល់ចិត្ត នីវរណធម៌នោះក៏សាបសូន្យទៅ ។

ម្នាលនាងវិសាខា មានវិធីធ្វើចិត្តដែលសៅហ្មង ឱ្យផូរផង់ស្អាតល្អដោយឧបាយ ១ បែបទៀត គឺព្រះអរិយសាវ័កក្នុងសាសនានេះ ជាអ្នករក្សាឧបោសថ រមែងរឭកនូវសីលរបស់ខ្លួន ជាសីលមិនដាច់ មិនធ្លុះធ្លាយ ជាសីលល្អមិននៅជាខ្ញុំតណ្ហា ជាសីលដែលអ្នកប្រាជ្ញសរសើរ ហើយជាសីលមិនបានជ្រោកជ្រាកដោយតណ្ហា និងទិដ្ឋិ ជាសីលអាចញ៉ាំងសមាធិឱ្យប្រព្រឹត្តទៅបាន កាលបើព្រះអរិយសាវ័កនោះ នឹករឭកនូវសីលដូច្នេះហើយ ចិត្តក៏ជ្រះថ្លាឡើង បាមោជ្ជៈ គឺសេចក្តីរីករាយក៏កើតឡើងនីវរណធម៌ឯណា ដែលជាគ្រឿងសៅហ្មង

ដល់ចិត្ត នីវរណធម៌នោះក៏សាបសូន្យទៅ ប្រៀបដូចជាការដុសខាត់កញ្ចក់ដែលសៅហ្មង ឱ្យជ្រះស្អាតល្អដោយឧបាយបានក៏អាស្រ័យប្រេង អាស្រ័យផេះ អាស្រ័យច្រាសដែលធ្វើដោយរោមកន្ទុយសត្វ អាស្រ័យសេចក្ដីព្យាយាមរបស់បុរសដែលខំប្រឹងដុសខាត់ ម្នាលនាងវិសាខា អរិយសាវ័កនេះ បានឈ្មោះថា រក្សានូវសីល ឧបោសថ បានឈ្មោះថា នៅជាមួយនឹងសីល ចិត្តរបស់ព្រះអរិយសាវ័កនោះ ប្រារព្ធនូវសីលហើយក៏ជ្រះថ្លាឡើង បាមោជ្ជៈ គឺ សេចក្ដីរីករាយក៏កើតមានឡើង នីវរណធម៌ឯណា ដែលជាគ្រឿងសៅហ្មងដល់ចិត្ត នីវរណធម៌នោះ ក៏សាបសូន្យទៅ ។

ម្នាលនាងវិសាខា មានវិធីធ្វើចិត្តដែលសៅហ្មង ឱ្យផូរផង់ ស្អាតល្អដោយឧបាយ ១ បែបទៀត គឺព្រះអរិយសាវ័កក្នុងសាសនានេះ ជាអ្នករក្សាឧបោសថ រមែងរឭកនូវទេវតាទាំងឡាយថា ទេវតាដែលស្ថិត នៅក្នុងស្ថានចាតុម្មហារាជិកាក៏មាន ទេវតាដែលស្ថិតនៅក្នុងស្ថានតាវត្តិង្ស ក៏មាន ទេវតាដែលស្ថិតនៅក្នុងស្ថានយាមា ក៏មាន ទេវតាដែលស្ថិតនៅក្នុងស្ថានតុសិត ក៏មាន ទេវតាដែលស្ថិតនៅក្នុងស្ថាននិម្មានរតីក៏មាន ទេវតាដែលស្ថិតនៅក្នុងស្ថានបរនិម្មិតវសវត្តី ក៏មាន

ទេវតាដែលជាពួកព្រហ្ម ក៏មាន ទេវតាដែលនៅខាងលើនេះទៀត ក៏មាន ទេវតាទាំងនោះ ប្រកបដោយសទ្ធាយ៉ាងណា ហើយច្យុតអំពីមនុស្សលោកនេះទៅ បានទៅក្នុងស្ថាននោះៗ សទ្ធារបស់អាត្មាអញ ក៏មានយ៉ាងនោះដែរ ទេវតាទាំងនោះ ប្រកបដោយសីលយ៉ាងណា ហើយច្យុតអំពីមនុស្សលោកនេះទៅបានទៅក្នុងស្ថាននោះៗ សីលរបស់អាត្មាអញ ក៏មានយ៉ាងនោះដែរ ទេវតាទាំងនោះ ប្រកបដោយសុតៈ គឺការចេះដឹងធម៌របស់សប្បុរសយ៉ាងណា ហើយច្យុតអំពីមនុស្សលោកនេះទៅ បានទៅក្នុងស្ថាននោះៗ សុតៈ គឺការចេះដឹងធម៌របស់អាត្មាអញ ក៏មាន យ៉ាងនោះដែរ ទេវតាទាំងនោះ ប្រកបដោយចាគៈ គឺការបរិច្ចាគទាន យ៉ាងណា ហើយច្យុតអំពីមនុស្សលោកនេះទៅ បានទៅក្នុងស្ថាននោះៗ ចាគៈ គឺការបរិច្ចាគទានរបស់អាត្មាអញ ក៏មានយ៉ាងនោះដែរ ទេវតាទាំងនោះ ប្រកបដោយបញ្ញាយ៉ាងណា ហើយច្យុតអំពីមនុស្សលោកនេះទៅបានទៅក្នុងស្ថាននោះៗ បញ្ញារបស់អាត្មាអញ ក៏មានយ៉ាងនោះដែរ កាលបើព្រះអរិយសាវ័កនោះ រឭកឃើញនូវសទ្ធា សីល សុតៈ ចាគៈ និងបញ្ញារបស់ខ្លួន និងទេវតាទាំងនោះដូច្នោះ

ហើយចិត្តក៏ជ្រះថ្លាឡើង បាមោជ្ជៈ គឺសេចក្តីរីករាយ ក៏កើតឡើង នីវរណធម៌ដែលជាគ្រឿងសៅហ្មងដល់ចិត្ត នីវរណធម៌នោះ ក៏សាបសូន្យទៅ ប្រៀបដូចជាការឱ្យដីមាស ដែលសៅហ្មងឱ្យមានសម្បុរផូរផង់ភ្លឺថ្លាល្អដោយឧបាយបាន ក៏អាស្រ័យជើងក្រាន អាស្រ័យអំបិល អាស្រ័យជ័ររង់ អាស្រ័យបំពង់សម្រាប់ផ្លុំ និងដង្កាប់សំរាប់ចាប់ប្រែត្រឡប់ អាស្រ័យសេចក្តីព្យាយាមរបស់បុរស ដែលខំប្រឹងធ្វើកិច្ចនោះៗ ម្នាលនាងវិសាខា ព្រះអរិយសាវ័កនេះ បានឈ្មោះថា រក្សានូវទេវតាឧបោសថៈ បានឈ្មោះថា នៅជាមួយនឹងទេវតា ចិត្តរបស់អរិយសាវ័កនោះ ប្រារព្ធនូវទេវតា ហើយក៏ជ្រះថ្លាឡើង បាមោជ្ជៈ គឺសេចក្តីរីករាយ ក៏កើតឡើង នីវរណធម៌ឯណា ដែលជាគ្រឿងសៅហ្មងដល់ចិត្ត នីវរណធម៌នោះ ក៏សាបសូន្យទៅ ម្នាលនាងវិសាខា ឯវិធីធ្វើចិត្ត ដែលសៅហ្មងឱ្យផូរផង់ស្អាតល្អ ដោយឧបាយយ៉ាងនេះ ។ ម្នាលនាងវិសាខា មួយវិញទៀត ព្រះអរិយសាវ័កនោះ រមែងពិចារណាអង្គនៃឧបោសថដូច្នេះថា

ព្រះអរហន្តទាំងឡាយ លោកលះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត ដរាបដល់អស់ជីវិត ដាក់

ចុះនូវដំបង ដាក់ចុះនូវកាំបិត មានសេចក្ដីខ្មាសបាប ដល់នូវសេចក្ដីអាណិតអាសូរ មានសេចក្ដីអនុគ្រោះ ដោយប្រយោជន៍ ដល់សត្វមានជីវិតទាំងពួង ថ្ងៃនេះ អាត្មាអញ ក៏លះបង់បាណាតិបាត វៀរស្រឡះចាក បាណាតិបាត អស់យប់នេះ និងថ្ងៃនេះ ដាក់ចុះនូវ ដំបង ដាក់ចុះនូវកាំបិត មានសេចក្ដីខ្មាសបាបដល់នូវ សេចក្ដីអាណិតអាសូរ មានសេចក្ដីអនុគ្រោះ ដោយ ប្រយោជន៍ដល់សត្វ មានជីវិតទាំងពួង ធ្វើតាមព្រះ អរហន្តទាំងឡាយ ដោយអង្គនេះ, មួយវិញទៀត ឧបោសថ អាត្មាអញនឹងរក្សាតទៅ ។

ព្រះអរហន្តទាំងឡាយ លោកលះបង់អទិន្នាទាន វៀរស្រឡះចាកអទិន្នាទានដរាបដល់អស់ជីវិត កាន់យកតែ របស់ដែលគេឱ្យ ប្រាថ្នាតែរបស់ដែលគេឱ្យ មានអត្តភាព មិនមែនជាអ្នកលួច មានសភាពស្មោះត្រង់ ថ្ងៃនេះអាត្មាអញ លះបង់អទិន្នាទាន វៀរស្រឡះចាកអទិន្នាទាន អស់យប់នេះ និងថ្ងៃនេះ កាន់យកតែរបស់ដែលគេឱ្យ ប្រាថ្នាតែរបស់ដែល គេឱ្យ មានអត្តភាពមិនមែនជាអ្នកលួច មានសភាពស្មោះត្រង់

ធ្វើតាមព្រះអរហន្តទាំងឡាយ ដោយអង្គនេះ, មួយវិញទៀត ឧបោសថ អាត្មាអញនឹងរក្សាតទៅ ។

ព្រះអរហន្តទាំងឡាយ លោកលះបង់នូវការប្រព្រឹត្តធម៌ មិនប្រសើរ ដរាបដល់អស់ជីវិត ប្រព្រឹត្តតែធម៌ប្រសើរ ចៀសវាងវៀរចាកមេថុន ជាធម៌របស់អ្នកស្រុក ថ្ងៃនេះ អាត្មាអញលះបង់ការប្រព្រឹត្តធម៌ មិនប្រសើរអស់យប់នេះ និងថ្ងៃនេះ ប្រព្រឹត្តតែធម៌ប្រសើរ ចៀសវាង វៀរចាកមេថុន ជាធម៌របស់អ្នកស្រុក ធ្វើតាមព្រះអរហន្តទាំងឡាយ ដោយអង្គនេះ, មួយវិញទៀត ឧបោសថអាត្មាអញនឹងរក្សាតទៅ ។

ព្រះអរហន្តលោកលះបង់មុសាវាទ វៀរស្រឡះចាកមុសាវាទ ដរាបដល់អស់ជីវិត លោកនិយាយតែពាក្យពិត តបនូវពាក្យពិត មានពាក្យនឹងនួនមិនរេរុស មានពាក្យគួរជឿ មិនពោលពាក្យបំភាន់សត្វលោក ថ្ងៃនេះអាត្មាអញក៏លះបង់មុសាវាទ វៀរស្រឡះមុសាវាទអស់យប់នេះ និងថ្ងៃនេះ ហើយពោលតែពាក្យពិត តបនូវពាក្យពិត មានពាក្យនឹងនួន មិនរេរុស មានពាក្យគួរជឿ មិនពោលពាក្យបំភាន់សត្វលោក ធ្វើតាមព្រះអរហន្តទាំងឡាយ ដោយអង្គនេះ, មួយវិញទៀត ឧបោសថ

អាត្មាអញនឹងរក្សាតទៅ ។

ព្រះអរហន្តទាំងឡាយ លោកលះបង់ទីតាំងនៃសេចក្តីប្រមាទ ព្រោះផឹកទឹកស្រវឹង គឺសុរានិងមេរ័យ វៀរស្រឡះចាកទីតាំងនៃសេចក្តីប្រមាទ ព្រោះផឹកទឹកស្រវឹង គឺសុរា និង មេរ័យ ដរាបដល់អស់ជីវិត ថ្ងៃនេះ អាត្មាអញលះបង់ទីតាំងនៃសេចក្តីប្រមាទ ព្រោះផឹកទឹកស្រវឹង គឺសុរា និង មេរ័យ វៀរស្រឡះចាកទីតាំងនៃសេចក្តីប្រមាទ ព្រោះផឹកទឹកស្រវឹង គឺសុរានិងមេរ័យ អស់យប់នេះ និងថ្ងៃនេះ ធ្វើតាមព្រះអរហន្តទាំងឡាយ ដោយអង្គនេះ មួយវិញទៀត ឧបោសថ អាត្មាអញនឹងរក្សាតទៅ ។

ព្រះអរហន្តទាំងឡាយ លោកបរិភោគបាយតែម្តង វៀរបរិភោគក្នុងរាត្រី វៀរស្រឡះចាកភោជនក្នុងកាលខុស ដរាបដល់អស់ជីវិត ថ្ងៃនេះអាត្មាអញជាអ្នកបរិភោគបាយតែម្តង វៀរបរិភោគក្នុងរាត្រី វៀរស្រឡះចាកភោជនក្នុងកាលខុស អស់យប់នេះ និងថ្ងៃនេះ ធ្វើតាមព្រះអរហន្តទាំងឡាយ ដោយអង្គនេះ, មួយវិញទៀត ឧបោសថ អាត្មាអញនឹងរក្សាតទៅ ។

ព្រះអរហន្តទាំងឡាយ លោកវៀរស្រឡះចាកការ

មើលនូវរបាំ និងស្តាប់នូវចំរៀងនិងភ្លេងប្រគំដែលជាសត្រូវដល់សាសនា ចាកទីតាំងនៃការទ្រទ្រង់ប្រដាប់ស្អិតស្អាងកាយ ដោយកម្រងផ្កាគ្រឿងក្រអូប និង គ្រឿងលាបផ្សេងៗ ដរាបដល់អស់ជីវិតថ្ងៃនេះ អាត្មាអញវៀរស្រឡះ ចាកការមើលនូវរបាំ និងស្តាប់នូវចំរៀង និងភ្លេងប្រគំដែលជាសត្រូវដល់សាសនា ចាកទីតាំងនៃការទ្រទ្រង់ប្រដាប់ស្អិត ស្អាងកាយដោយកម្រងផ្កាគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ អស់យប់នេះ និង ថ្ងៃនេះ ធ្វើតាមព្រះអរហន្តទាំងឡាយ ដោយអង្គនេះ, មួយវិញទៀត ឧបោសថ អាត្មាអញនឹងរក្សាតទៅ ។

ព្រះអរហន្តទាំងឡាយ លោកលះបង់ទីដេកទីអង្គុយខ្ពស់ និងទីដេកទីអង្គុយដ៏ប្រសើរ វៀរស្រឡះចាកទីដេក និងទីអង្គុយដ៏ប្រសើរ ដរាបដល់អស់ជីវិត សម្រេចនូវទីដេកដ៏ទាប គឺដេកលើគ្រែក្តី លើកំរាលស្មៅក្តី ដែលជាកប្បិយៈថ្ងៃនេះ អាត្មាអញលះបង់ទីដេកនិងទីអង្គុយខ្ពស់ និងទីដេកទីអង្គុយដ៏ប្រសើរ វៀរស្រឡះចាកទីដេកទីអង្គុយខ្ពស់ និង ទីដេកទីអង្គុយដ៏ប្រសើរ អស់យប់នេះ និងថ្ងៃនេះ សម្រេចនូវទីដេកដ៏ទាប គឺដេកលើគ្រែក្តី លើកំរាលស្មៅក្តី ដែលជាកប្បិយៈ

ធ្វើតាមព្រះអរហន្តទាំងឡាយ ដោយអង្គនេះ, មួយវិញទៀត ឧបោសថ អាត្មាអញនឹងរក្សាតទៅ ។ ម្នាលនាងវិសាខា អរិយុបោសថៈយ៉ាងនេះឯង ។

ម្នាលនាងវិសាខា អរិយុបោសថៈ ដែលបុគ្គលបានរក្សាយ៉ាងនេះ ហើយរមែងមានផលច្រើន មានអានិសង្សច្រើន ចុះផលច្រើន អានិសង្សច្រើននោះ តើច្រើនប៉ុន្មានទៅ ? ម្នាលនាងវិសាខា ប្រៀបដូចបុគ្គលឯណា បានសោយរាជ្យជាស្តេចធំ លើបណ្តាជនដែលនៅក្នុងមហាជនបទទាំង ១៦ នេះជាជនបទមានកែវ ៧ ប្រការជាច្រើន ឯជនបទទាំង ១៦ នោះ គឺ អង្គជនបទ ១ មគធជនបទ ១ កាសីជនបទ ១ កោសលជនបទ ១ វជ្ជីជនបទ ១ មល្លជនបទ ១ ចេតីជនបទ ១ វង្សជនបទ ១ កុរុជនបទ ១ បញ្ចាលជនបទ ១ បច្ឆជនបទ ១ សុរសេនជនបទ ១ អស្សកជនបទ ១ អវន្តីជនបទ ១ គន្ធារជនបទ ១ កម្ពោជជនបទ ១ ។ ឯរាជសម្បត្តិរបស់បុគ្គលនោះ មិនដល់មួយចំរៀកឧបោសថ ដែលប្រកបដោយអង្គ ៨ ដែលគេច្រៀកជា ១៦ ចំរៀក អស់វារៈ ១៦ ផង ។ ព្រោះហេតុអ្វីបានជាដូច្នោះ ម្នាលនាងវិសាខា ព្រោះថា យក

រាជសម្បត្តិរបស់មនុស្សដែលស្ដួចស្ដើង ទៅប្រៀបផ្ទៀបគ្នានឹងសេចក្ដីសុខទិព្វ ម្នាលនាងវិសាខា ៥០ ឆ្នាំមនុស្សបាន ១ យប់ ១ ថ្ងៃ ទេវតា ក្នុងស្ថានចាតុម្មហារាជិកា, ៣០ រាត្រីនោះ ត្រូវជា ១ ខែ ១២ ខែ នោះ ត្រូវជា ១ ឆ្នាំ អាយុទេវតាក្នុងស្ថានចាតុម្មហារាជិកា កំណត់ ៥០០ ឆ្នាំ ទិព្វ (ត្រូវជា ៩ លានឆ្នាំមនុស្ស) បុគ្គលពួកមួយក្នុងលោកនេះ ជាស្ត្រីក្ដី ជាបុរសក្ដី បានរក្សាឧបោសថប្រកបដោយអង្គ ៨ លុះមានរាងកាយបែកធ្លាយទៅហើយ ខាងមុខអំពីសេចក្ដីស្លាប់ជួនកាល ក៏បានទៅកើតជាមួយនឹងទេវតាក្នុងស្ថានចាតុម្មហារាជិកា ម្នាលនាងវិសាខា ពាក្យដែលតថាគតថា យករាជសម្បត្តិរបស់មនុស្ស ដែលស្ដួចស្ដើងទៅប្រៀបផ្ទៀបគ្នានឹងសេចក្ដីសុខទិព្វនោះ ព្រោះអាស្រ័យហេតុនោះឯង ។ ម្នាលនាងវិសាខា ១ រយឆ្នាំមនុស្ស ត្រូវជា ១ យប់ ១ ថ្ងៃ ទេវតាក្នុងស្ថានតាវត្តិង្ស ៣០ រាត្រីនោះត្រូវជា ១ ខែ ១២ ខែនោះត្រូវជា ១ ឆ្នាំ អាយុ ទេវតាក្នុងស្ថានតាវត្តិង្ស កំណត់ ១ ពាន់ ឆ្នាំទិព្វ (ត្រូវជា ៣ កោដិ ៦ លាន ឆ្នាំ មនុស្ស) បុគ្គលពួកមួយ ក្នុងលោកនេះ ជាស្ត្រីក្ដី បុរសក្ដី បានរក្សា

ឧបោសថប្រកបដោយអង្គ ៨ លុះមានរាងកាយបែកធ្លាយទៅហើយ ខាងមុខអំពីសេចក្ដីស្លាប់ ជួនកាលក៏បានទៅកើតជាមួយនឹងទេវតាក្នុងស្ថានតាវត្តិង្ស ម្នាលនាងវិសាខា ពាក្យដែល តថាគតថាយករាជសម្បត្តិ របស់មនុស្សដែលស្ដួចស្ដើង ទៅប្រៀបផ្ទៀបនឹងសេចក្ដីសុខទិព្វនោះ ព្រោះអាស្រ័យហេតុនេះឯង ។

ម្នាលនាងវិសាខា ២ រយឆ្នាំមនុស្សត្រូវជា ១ យប់ ១ ថ្ងៃ ទេវតាក្នុងស្ថានយាមា ៣០ រាត្រីនោះត្រូវជា ១ ខែ ១២ ខែនោះត្រូវជា ១ ឆ្នាំ អាយុទេវតាក្នុងស្ថាន យាមា កំណត់ ២ ពាន់ឆ្នាំទិព្វ (ត្រូវជា ១៤ កោដិ ៤ លានឆ្នាំមនុស្ស) បុគ្គលពួកមួយ ក្នុងលោកនេះ ជាស្ត្រីក្ដី បុរសក្ដី បានរក្សាឧបោសថប្រកបដោយអង្គ ៨ លុះមាន រាងកាយបែកធ្លាយទៅហើយ ខាងមុខអំពីសេចក្ដីស្លាប់ ជួនកាលក៏បានទៅកើតជាមួយនឹងទេវតាក្នុងស្ថានយាមា ម្នាលនាងវិសាខា ពាក្យដែលតថាគតថា យករាជសម្បត្តិរបស់មនុស្សដែលស្ដួចស្ដើង ទៅប្រៀបផ្ទៀបនឹងសេចក្ដីសុខ ទិព្វនោះ ព្រោះអាស្រ័យហេតុនេះឯង ។

ម្នាលនាងវិសាខា ៤ រយឆ្នាំមនុស្ស ត្រូវជា ១ យប់ ១

ថ្ងៃ ទេវតាក្នុងស្ថានតុសិត ៣០ រាត្រីនោះ ត្រូវជា ១ ខែ ១២ ខែនោះត្រូវជា ១ ឆ្នាំ អាយុទេវតា ក្នុងស្ថានតុសិត កំណត់ ៤ ពាន់ឆ្នាំទិព្វ (ត្រូវជា ៥៧ កោដិ ៦ លានឆ្នាំមនុស្ស ) បុគ្គលពួកមួយក្នុងលោកនេះ ជាស្ត្រីក្តី បុរសក្តី បានរក្សាឧបោសថប្រកបដោយអង្គ ៨ លុះមានរាងកាយបែកធ្លាយទៅហើយជួនកាល ក៏បានទៅ កើតជាមួយទេវតាក្នុងស្ថានតុសិត ម្នាលនាងវិសាខា ពាក្យដែលតថាគតថា យករាជសម្បត្តិរបស់មនុស្ស ដែលស្តួចស្តើងទៅប្រៀបផ្ទៀបនឹងសេចក្តីសុខទិព្វនោះព្រោះអាស្រ័យហេតុនេះឯង ។

ម្នាលនាងវិសាខា ៨ រយឆ្នាំមនុស្សត្រូវជា ១ យប់ ១ ថ្ងៃ ទេវតាក្នុងស្ថាននិម្មានរតី ៣០ រាត្រីនោះត្រូវជា ១ ខែ ១២ ខែនោះត្រូវជា ១ ឆ្នាំ អាយុទេវតាក្នុងស្ថាន និម្មានរតី កំណត់ ៨ ពាន់ឆ្នាំទិព្វ (ត្រូវជា ២៣០ កោដិ ៤ លានឆ្នាំមនុស្ស) បុគ្គលពួកមួយក្នុងលោកនេះ ជាស្ត្រីក្តី បុរសក្តី បានរក្សាឧបោសថប្រកបដោយអង្គ ៨ លុះមានរាងកាយបែកធ្លាយទៅ ហើយខាងមុខអំពីសេចក្តីស្លាប់ ជួនកាល ក៏បានទៅកើតជាមួយនឹងទេវតាក្នុងស្ថាននិម្មានរតី ម្នាលនាងវិសាខា ពាក្យដែលតថាគតថា យករាជសម្បត្តិរបស់មនុស្សដែល

ស្តួចស្តើង ទៅប្រៀបផ្ទឹមនឹងសេចក្តីសុខទិព្វនោះ ព្រោះអាស្រ័យហេតុនេះឯង ។

ម្នាលនាងវិសាខា ១ ពាន់ ៦ រយឆ្នាំមនុស្ស ត្រូវ ជា ១ យប់ ១ ថ្ងៃទេវតាក្នុងស្ថានបរនិម្មិតវសវត្តី ៣០ រាត្រីនោះ ត្រូវជា ១ ខែ ១២ ខែ នោះត្រូវជា ១ ឆ្នាំ អាយុទេវតា ក្នុងស្ថានបរនិម្មិតវសវត្តីកំណត់ ១ ហ្មឺន ៦ ពាន់ឆ្នាំទិព្វ (ត្រូវជា ៩២១ កោដិ ៦ លានឆ្នាំមនុស្ស) បុគ្គលពួកមួយក្នុងលោកនេះ ជាស្ត្រីក្តី បុរសក្តី បានរក្សាឧបោសថប្រកបដោយអង្គ ៨ លុះមានរាងកាយបែកធ្លាយទៅហើយ ខាងមុខអំពីសេចក្តីស្លាប់ជួនកាល ក៏បានទៅ កើតជាមួយនឹងទេវតាក្នុងស្ថានបរនិម្មិត-វសវត្តី ម្នាលនាងវិសាខាពាក្យដែលតថាគតថា យករាជសម្បត្តិរបស់មនុស្ស ដែលស្តួចស្តើង ទៅប្រៀបផ្ទឹមនឹងសេចក្តីសុខទិព្វនោះ ព្រោះអាស្រ័យហេតុនេះឯង ។

**បាណំ ន ហញ្ញេ ន ចាទិន្នមាទិយេ មុសា ន ភាសេ**
**ន ច មជ្ជបោ សិយា អព្រហ្មចារា វិរមេយ្យ មេថុនា**
**រត្តឹ ន ភុញ្ជេយ្យ វិកាលភោជនំ មាលំ ន ធារេ ន ច**
**គន្ធមាចរេ មញ្ចេ ឆមាយំ វ សយេថ សន្ថតេ ឯតញ្ហិ**
**អដ្ឋង្គិកមាហុបោសថំ ពុទ្ធេន ទុក្ខន្តគុនា បកាសិតំ ។**

បុគ្គលមិនគប្បីសម្លាប់សត្វ មិនគប្បីកាន់យកនូវទ្រព្យដែលគេមិនបានឱ្យ មិនគប្បីពោលពាក្យកុហក មិនគប្បីផឹកទឹកស្រវឹង គប្បីវៀរចាកមេថុនដែលជាការប្រព្រឹត្តមិនប្រសើរ មិនគប្បីបរិភោគក្នុងរាត្រី មិនគប្បីបរិភោគភោជនក្នុងកាលខុសក្នុងវេលាថ្ងៃ មិនគប្បីទ្រទ្រង់កម្រងផ្កា មិនគប្បីប្រើប្រាស់គ្រឿងក្រអូប គប្បីដេកលើគ្រែជាកប្បិយៈ មានជើងកំពស់ ១ គក់ក្តី លើផែនដីដែលគេបរិកម្មដោយកំបោរជាដើមក្តី លើកំរាលស្មៅ ស្លឹកឈើ និងចំបើងជាដើមក្តី អ្នកប្រាជ្ញទាំងឡាយបានពោលនូវអំពើនេះថា ជាឧបោសថប្រកបដោយអង្គ ៨ ដែលព្រះពុទ្ធជាម្ចាស់ ព្រះអង្គដល់នូវព្រះនិព្វានជាទីបំផុតនៃទុក្ខ ទ្រង់ប្រកាសហើយ ។

**ចន្ទោ ច សូរោ ច ឧភោ សុទស្សនា ឱភាសយន្តា**
**អនុយន្តិ យាវតា គះមោនុឆា តេ បន អន្តលិក្ខគា**
**នភេ បភាសន្តិ ឩសា ទិរោចនា ឯតស្មិ យំ ទិជ្ជតិ**
**អន្តរេ ធនំ មុត្តា មណិ វេឡុរិយញ្ច ភទ្ទកំ**
**សិង្គិសុវណ្ណំ អថវាបិ កាញ្ចនំ យំ ជាតរូបំ ហដកន្តិ**
**វុច្ចតិ អដ្ឋង្គុបេតស្ស ឧបោសថស្ស កលម្បិ តេ**
**នានុភវន្តិ សោឡសឹ ចន្ទប្បភា តារគណា ច សព្វេ ។**

ព្រះចន្ទនិងព្រះអាទិត្យទាំងពីរ ជាសភាវៈល្អមើល មានរស្មីភ្លឺស្វាង ដើរទៅតាមកំណត់ព្រះចន្ទ និងព្រះអាទិត្យនោះតែងបន្ទោបង់នូវងងឹត ដើរទៅក្នុងអាកាស បញ្ចេញរស្មីឮងឺអាកាសរុងរឿងសព្វទិស ទ្រព្យឯណាមាននៅក្នុងចន្លោះនោះគឺប្រទេសដែលមានរស្មីព្រះចន្ទព្រះអាទិត្យចាំងទៅដល់ គឺកែវមុត្តាក្តី កែវមណីក្តី កែវពៃទូរ្យក្តី មាសសិង្គីក្តី មាសកញ្ចនៈក្តី មាសជាតរូបក្តី មាសហដកៈក្តី ដែលបុគ្គលបានហើយ ទ្រព្យទាំងនោះមិនដល់ ១ ចំរៀក ឧបោសថប្រកបដោយអង្គ ៨ ដែលគេច្រៀកជា ១៦ ចំរៀក អស់វារៈ ១៦ ដង ប្រៀបដូចពពួកផ្កាយទាំងអស់ មិនដល់ ១ ចំរៀករស្មីព្រះចន្ទឡើយ ។

**តស្មា ហិ នារី ច នរោ ច សីលវា អដ្ឋង្គុបេតំ**
**ឧបវស្សុបោសថំ បុញ្ញានិ កត្វាន សុខុទ្រយានិ**
**អនិន្ទិតា សគ្គមុបេន្តិ ឋានន្តិ ។**

ហេតុដូច្នោះ ជនទាំងស្រីទាំងប្រុសដែលមានសីលបានរក្សាឧបោសថប្រកបដោយអង្គ ៨ ហើយធ្វើបុណ្យ ដែលមានផលជាសុខ ឥតមានគេនិន្ទាឡើយ រមែងចូលទៅកាន់ស្ថានសួគ៌ជាប្រាកដ ។

ចប់ឧបោសថសូត្រតែប៉ុណ្ណោះ

## ឯកុបោសថិកាថេរិយាបទាន

ក្នុងបិដកលេខ ៧៦ ទំព័រ ២៥

សេចក្តីដំណាលថា មានព្រះមហាក្សត្រមួយព្រះអង្គ ទ្រង់ព្រះនាមពន្ធុមៈ សោយរាជ្យក្នុងនគរពន្ធុមតី ព្រះអង្គរក្សាឧបោសថក្នុងថ្ងៃពេញបូណ៌មី ។ សម័យនោះខ្ញុំជាកុម្ភទាសីនៅក្នុងទីនោះ ខ្ញុំបានឃើញសេនាព្រមទាំងព្រះរាជា ហើយក៏គិតយ៉ាងនេះថា សូម្បីស្តេចក៏ទ្រង់លះបង់រាជសម្បត្តិ ហើយរក្សាឧបោសថកម្មនោះ ពិតជាប្រកបដោយផល បានជាពួកជនរីករាយហើយ ។ ខ្ញុំពិចារណានូវទុគ្គតិផង នូវសេចក្តីក្រីក្រផង ដោយឧបាយនៃប្រាជ្ញា ក៏ញុំាងចិត្តឱ្យរីករាយ ហើយរក្សាឧបោសថ ។ លុះខ្ញុំរក្សា ឧបោសថក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធ ខ្ញុំក៏បានទៅកើតក្នុងឋានតាវត្តិង្សដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះ ។ វិមានរបស់ខ្ញុំ ដែលកុសលធ្វើល្អហើយក្នុងទីនោះ មានកំពស់ ទៅខាងលើមួយយោជន៍ ប្រដាប់ដោយផ្ទះកំពូលដ៏ប្រសើរ មានអាសនៈធំ ស្អិតស្អាងល្អហើយ ។ ស្រីអប្សរមួយសែន តែងបម្រើខ្ញុំសព្វៗកាល ខ្ញុំរុងរឿងកន្លងលើសទេវតាទាំងឡាយដទៃសព្វៗកាល ។ ខ្ញុំបានជាមហេសីនៃ

ទេវរាជ ៦៤ ដង បានជាមហេសីនៃស្តេចចក្រពត្តិ ៣៦ ដង ។ ខ្ញុំមានពណ៌ដូចជាមាស តែងអន្ទោលទៅក្នុងភពទាំងឡាយ ខ្ញុំជាស្ត្រីប្រសើរក្នុងទីទាំងពួង នេះជាផលនៃឧបោសថ ។ ខ្ញុំតែងបាននូវវត្ថុទាំងពួងនេះ គឺ យានដំរី យានសេះ យានរថ ទាំងអស់ នេះជាផលនៃឧបោសថ ។ ខ្ញុំបាននូវវត្ថុទាំងពួង ជាវិការៈនៃមាស ជាវិការៈនៃប្រាក់ ជាវិការៈនៃកែវផលិក ជាវិការៈនៃកែវមានពណ៌ក្រហម ។ ខ្ញុំបាននូវវត្ថុទាំងពួង គឺសំពត់កោសេយ្យពស្ត្រ និងសំពត់កម្ពលផង សំពត់សំបកឈើ និងសំពត់អំបោះផង សំពត់មានថ្លៃដ៏ច្រើនផង ។ ខ្ញុំបាននូវវត្ថុទាំងពួងនេះ គឺ បាយទឹក ខាទនីយៈ សំពត់ និងសេនាសនៈ នេះជាផលនៃឧបោសថ ។ ខ្ញុំបាននូវវត្ថុទាំងពួងនេះ គឺ គ្រឿងក្រអូបដ៏ប្រសើរ និងកម្រងផ្កា លំអិតសម្រាប់លាប នេះជាផលនៃឧបោសថ ។ ខ្ញុំបាននូវវត្ថុទាំងនេះ គឺផ្ទះមានកំពូល ប្រាសាទមណ្ឌប ប្រាសាទមានដំបូលរលីង និងគុហា នេះជាផលនៃឧបោសថ ។ ខ្ញុំមានអាយុ ៧ ឆ្នាំ អំពីកំណើតបានចូលទៅកាន់ផ្នួស មិនទាន់បានកន្លះខែ ក៏បានសម្រេចព្រះអរហត្ត ខ្ញុំមានអាសវៈទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មីមិនមានទៀត

ឡើយ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបាន ធ្វើកុសលកម្មក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជា ផលនៃឧបោសថ ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញ ហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមាន អាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវ ទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើ ហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបាន ធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បាន ប្រតិបត្តិហើយ ។

បានឮថា ព្រះឯកុបោសថិកាភិក្ខុនី មានអាយុ បាន សម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ឯកុបោសថិកាថេរីយាបទាន

# សិង្គាលកសូត្រ

ក្នុងបិដកលេខ ១៩ ទំព័រ ៦៧

ខ្ញុំបានស្តាប់មកយ៉ាងនេះ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង កូនគហបតី ឈ្មោះ **សិង្គាលកៈ**[១១] ក្រោកឡើងអំពីព្រឹក មានសំពត់ស្លៀកដណ្តប់ទទឹក និងសក់ទទឹក ចេញពីក្រុងរាជគ្រឹះ ប្រណម្យអញ្ជលី ថ្វាយបង្គំទិសទាំងឡាយច្រើន គឺទិសខាងកើត ខាងត្បូង ខាងលិច ខាងជើង ខាងក្រោម និងទិសខាងលើ ។

លំដាប់នោះឯង ព្រះមានព្រះភាគ ស្លៀចទ្រង់ស្បង់ និងបាត្រ ចីវរ ក្នុងបុព្វណ្ហសម័យ ហើយស្តេចចូលទៅ កាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញសិង្គាលកគហបតីបុត្ត ក្រោកឡើងអំពីព្រឹក មានសំពត់ស្លៀកដណ្តប់ទទឹក និងសក់ទទឹក ចេញពីក្រុងរាជគ្រឹះ កំពុងផ្គង

---

[១១] ហៅថា សិគាលកៈ ក៏មាន ដូចគ្នានឹងពាក្យថា មហឹសៈ នឹងមហិសៈ សិរីសបៈ នឹងសិរិសបៈជាដើម ឃើញថាហៅបានដូចគ្នាទាំងពីរយ៉ាង ។

អញ្ជលី ថ្វាយបង្គំទិសទាំងឡាយច្រើន គឺ ទិសខាងកើត ខាងត្បូង ខាងលិច ខាងជើង ខាងក្រោម និង ទិសខាងលើ លុះទ្រង់ឃើញហើយ ទើបទ្រង់ត្រាស់សួរ សិង្គាលកគហបតីបុត្តដូច្នេះ ថា នែគហបតីបុត្ត ហេតុអ្វី ទើបអ្នកក្រោកអំពីព្រឹក មានសំពត់ស្លៀកជណ្តប់ទទឹក និងសក់ទទឹកចេញពីក្រុងរាជគ្រឹះ ផ្គងអញ្ជលី ថ្វាយបង្គំទិសទាំងឡាយច្រើន គឺទិសខាងកើត ។បេ។ ទិសខាងលើ ។ សិង្គាលកគហបតីបុត្តក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលបិតារបស់ខ្ញុំជិតនឹងធ្វើមរណភាព បានផ្តាំនឹងខ្ញុំព្រះអង្គ យ៉ាងនេះថា ហៃបា អ្នកត្រូវតែថ្វាយបង្គំទិសទាំងឡាយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ ធ្វើសក្ការៈ គោរព រាប់អាន បូជានូវពាក្យរបស់បិតា បានជាក្រោកឡើងអំពីព្រឹក មានសំពត់ស្លៀកជណ្តប់ទទឹក និងសក់ទទឹកចេញពីក្រុងរាជគ្រឹះ ផ្គងអញ្ជលី ថ្វាយបង្គំទិសទាំងឡាយច្រើន គឺទិសខាងកើត ។បេ។ ទិសខាងលើ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា នែគហបតីបុត្ត ក្នុងវិន័យរបស់ព្រះអរិយៈ គេមិនត្រូវថ្វាយបង្គំទិសទាំង ៦ យ៉ាងដូច្នេះទេ ។ សិង្គាលកគហបតីបុត្ត ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន

ចំណែកក្នុងអរិយវិន័យ គេគប្បីថ្វាយបង្គំទិសទាំង ៦ ដូចម្ដេច បពិត្រព្រះអង្គដ៏ចម្រើន បើក្នុងវិន័យរបស់ព្រះអរិយៈ គេគប្បីថ្វាយបង្គំចំពោះទិសទាំង ៦ យ៉ាងណា សូមព្រះមានព្រះភាគទ្រង់សម្ដែងធម៌ដល់ខ្ញុំព្រះអង្គ ដូច្នោះចុះ ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា នៃគហបតីបុត្ត បើដូច្នោះ អ្នកចូរស្ដាប់ចុះ ចូរកំណត់ទុកក្នុងចិត្តឱ្យប្រពៃចុះ តថាគតនឹងសម្ដែងប្រាប់ ។ សិង្គាលកគហបតីបុត្ត ក៏ទទួលស្ដាប់ព្រះពុទ្ធដីកាព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងហ្នឹងហើយ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតីបុត្ត អរិយសាវ័ក លះបង់នូវកម្មក្កិលេស (អំពើដ៏សៅហ្មង) ៤ ប្រការផង មិនធ្វើនូវបាបកម្ម (អំពើអាក្រក់) ព្រោះហេតុ ៤ យ៉ាងផង មិនសេពនូវអបាយមុខ (គឺប្រធាននៃសេចក្ដីវិនាស) នៃភោគៈ ៦ យ៉ាងផង អរិយសាវ័កនោះ លោកវៀរចាកបាបធម៌ទាំង ១៤ យ៉ាងនេះ ឈ្មោះថា ជាអ្នកបិទបាំងទិសទាំង ៦ ប្រតិបត្តិដើម្បីជំនះ ក្នុងលោកទាំងពីរ គឺលោកនេះ ក៏អរិយសាវ័កនោះ បានប្រារព្ធ គឺថាបានពេញចិត្តហើយ

លោកខាងមុខក៏ពេញ ចិត្តទៀត ។ លុះអរិយសាវ័កនោះ ទំលាយរាងកាយទៅ រមែងកើតក្នុងមនុស្សសុគតិសួគ៌ទេវលោក ។ កម្មក្កិលេស ៤ ប្រការ ដែលអរិយសាវ័កនោះលះបង់ហើយ តើដូចម្តេច ។ ម្នាលគហបតីបុត្ត ការធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្ទង **បាណាតិបាត** សម្លាប់សត្វ ជាកម្មក្កិលេស ១, **អទិន្នាទាន** ការកាន់យកទ្រព្យ ដែលម្ចាស់គេមិនឱ្យ ជាកម្មក្កិលេស ១, **កាមេសុ មិច្ឆាចារ** ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជាកម្មក្កិលេស ១ **មុសាវាទោ** ការនិយាយពាក្យកុហក ជាកម្មក្កិលេស ១ កម្មក្កិលេស ៤ ប្រការ នេះដែលអរិយសាវ័កនោះបានលះបង់ហើយ ។ ព្រះមានព្រះភាគបានសម្តែងពាក្យនេះហើយ ព្រះសុគតជាសាស្តា លុះទ្រង់សម្តែងពាក្យនេះ ហើយទើបសម្តែងគាថាពន្ធ័នេះតទៅទៀតថា

**បាណាតិបាតោ អទិន្នាទានំ មុសាវាទោ បវុច្ចតិ**
**បរទារគមនញ្ចេវ ន បសំសន្តិ បណ្ឌិតា**

ការសម្លាប់សត្វ ១ លួចទ្រព្យគេ ១ និយាយកុហក ១ សេពភរិយាបុគ្គលដទៃ ១ ហៅថា (កម្មក្កិលេស) បណ្ឌិត

ទាំងឡាយមិនសរសើរឡើយ ។

អរិយសាវ័កមិនធ្វើនូវបាបកម្ម ព្រោះហេតុ ៤ យ៉ាង ដូចម្ដេចខ្លះ បុថុជ្ជនលុះអគតិព្រោះស្រឡាញ់ ក៏ធ្វើបាបកម្ម លុះអគតិព្រោះស្អប់ ក៏ធ្វើបាបកម្ម លុះអគតិព្រោះល្ងង់ ក៏ធ្វើបាបកម្ម លុះអគតិព្រោះខ្លាច ក៏ធ្វើបាបកម្ម ។ ម្នាលគហបតីបុត្រ អរិយសាវ័កមិនលុះ**ឆន្ទាគតិ** អគតិព្រោះស្រឡាញ់ មិនលុះ**ទោសាគតិ** អគតិព្រោះស្អប់ មិនលុះ**មោហាគតិ** អគតិព្រោះល្ងង់ មិនលុះ**ភយាគតិ** អគតិព្រោះខ្លាច ព្រោះហេតុទាំង ៤ ណា ។ អរិយសាវ័កនោះ ឈ្មោះថា មិនធ្វើបាបកម្ម ព្រោះហេតុ ៤ យ៉ាងនេះ ។ ព្រះមានព្រះភាគបានសម្ដែងពាក្យនេះ ហើយព្រះសុគតជាសាស្ដា លុះទ្រង់សម្ដែងពាក្យនេះហើយ ទើបសម្ដែងគាថា ពន្ធ័នេះតទៅទៀតថា :-

**ឆន្ទា ទោសា ភយា មោហា យោ ធម្មំ អតិវត្តតិ**
**និហីយតិ តស្ស យសោ កាឡបក្ខេវ ចន្ទិមា ។**

**ឆន្ទា ទោសា ភយា មោហា យោ ធម្មំ នាតិវត្តតិ**
**អាបូរតិ តស្ស យសោ សុក្កបក្ខេវ ចន្ទិមា ។**

អ្នកណាប្រព្រឹត្តកន្លងធម៌ ព្រោះសេចក្តីស្រឡាញ់ ព្រោះសេចក្តីស្អប់ ព្រោះសេចក្តីខ្លាច ព្រោះសេចក្តីវង្វេង យសរបស់អ្នកនោះ រមែងសាបសូន្យទៅដូចព្រះចន្ទខាងរនោច ។ អ្នកណាមិនប្រព្រឹត្តកន្លងធម៌ ព្រោះសេចក្តីស្រឡាញ់ ព្រោះសេចក្តីស្អប់ ព្រោះសេចក្តីខ្លាច ព្រោះសេចក្តីវង្វេង យសរបស់អ្នកនោះ រមែងពេញបរិបូណ៌ ដូចព្រះចន្ទខាងខ្នើត ។

អរិយសាវ័ក មិនសេពនូវធម៌ជាប្រធាននៃសេចក្តីវិនាសភោគៈ ៦ យ៉ាង ដូចម្តេចខ្លះ ។

ម្នាលគហបតីបុត្ត **សុរាមេរយមជ្ជប្បមាទដ្ឋានានុយោគោ** កិរិយាប្រកបរឿយៗនូវការផឹកទឹកស្រវឹង គឺសុរានិងមេរ័យដែលជាហេតុ ជាទីតាំងនៃសេចក្តីប្រមាទ ជាប្រធាននៃសេចក្តីវិនាសភោគៈ ១ ។ **វិកាលវិសិខាចរិយានុយោគោ** ការប្រកបរឿយៗនូវការត្រាច់ទៅតាមច្រកល្ហកខុសកាល ជាប្រធាននៃសេចក្តីវិនាសភោគៈ ១ ។ **សមជ្ជាភិចរណំ** ការដើរមើលមហោស្រពជាប្រធាននៃសេចក្តីវិនាសភោគៈ១ ។ **ជូតប្បមាទដ្ឋានានុយោគោ** ការប្រកបរឿយៗ នូវហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺលេង

ល្បែងភ្នាល់ជាប្រធាននៃសេចក្តីវិនាសភោគៈ ១ ។ **បាបមិត្តា-នុយោគោ** ការសេពគប់នូវបាបមិត្ត ជាប្រធាននៃសេចក្តីវិនាសភោគៈ ១ ។ **អាលស្សានុយោគោ** ការប្រកបរឿយៗ នូវសេចក្តីខ្ជិល ជាប្រធាននៃសេចក្តីវិនាសភោគៈ ១ ។

ម្នាលគហបតីបុត្ត ទោសក្នុងកិរិយាប្រកបរឿយៗនូវការផឹកទឹកស្រវឹង គឺសុរានិងមេរ័យ ដែលជាហេតុជាទីតាំង នៃសេចក្តីប្រមាទនេះមាន ៦ យ៉ាងគឺ **សន្ទិដ្ឋិកា ធនជានិ** វិនាសទ្រព្យដែលឃើញជាក់ស្តែងខ្លួនឯង ១ **កលហប្បវឌ្ឍនី** ការកឱ្យកើតជំលោះ ១ **រោគានំ អាយតនំ** ហេតុនាំឱ្យកើតរោគទាំងឡាយ១ **អកិត្តិសញ្ជននី** ការនាំឱ្យខូចឈ្មោះ១ **ហិរិកោបិននិទ្ទំសនី** ការបង្ហាញកេរ្តិ៍ខ្មាស ១ ហេតុជាគំរប់ ៦ គឺ **បញ្ញាយ ទុព្វលីករណី** ធ្វើបញ្ញាឱ្យមានកម្លាំងថយ ១ ។ ម្នាលគហបតីបុត្ត ទោសក្នុងការប្រកបរឿយៗនូវការផឹកទឹកស្រវឹងគឺ សុរានិងមេរ័យ ដែលជាហេតុជាទី តាំងនៃសេចក្តីប្រមាទមាន ៦ នេះឯង ។

ម្នាលគហបតីបុត្ត ទោសក្នុងការប្រកបរឿយៗនូវការដើរទៅតាមច្រកល្ហកខុសកាលនេះមាន ៦ យ៉ាង គឺ **អត្តាបិស្ស**

**អគុត្តោ អរក្ខិតោ ហោតិ** អ្នកនោះ ឈ្មោះថា មិនគ្រប់គ្រង មិនរក្សាខ្លួន ១ **បុត្តទារោបិស្ស អគុត្តោ អរក្ខិតោ ហោតិ** អ្នកនោះ ឈ្មោះថា មិនគ្រប់គ្រង មិនរក្សាកូនប្រពន្ធ ១ **សាបតេយ្យំបិស្ស អគុត្តំ អរក្ខិតំ ហោតិ** អ្នកនោះ ឈ្មោះថា មិនគ្រប់គ្រងមិនរក្សាទ្រព្យសម្បត្តិ ១ **សង្កិយោ ច ហោតិ តេសុ តេសុ ឋានេសុ** សេចក្តីរង្កៀសតែងកើតមានក្នុងកន្លែង (ដែលខ្លួនទៅដល់) នោះៗ ១ **អភូតវចនញ្ច តស្មឹ រូហតិ** ពាក្យមិនពិត តែងធ្លាក់មកត្រូវលើបុគ្គលនោះ[១២] ១ **ពហូនញ្ច ទុក្ខធម្មានំ បុរក្ខិតោ ហោតិ** បុគ្គលនោះ ឈ្មោះថា បំពេញនូវធម៌ជាទុក្ខច្រើន ១ ។ ម្នាលគហបតីបុត្ត ទោសក្នុងការប្រកបរឿយៗ នូវកិរិយាត្រាច់ទៅតាមច្រកល្ហកខុសកាលមាន ៦ យ៉ាង នេះឯង ។

ម្នាលគហបតីបុត្ត ទោសក្នុងការដើរមើលល្បែងមហោស្រពនេះ ៦ យ៉ាង គឺ **ក្វ នច្ចំ** របាំក្នុងទីណា ក៏ទៅក្នុងទីនោះ ១ **ក្វ គីតំ** ចំរៀងក្នុងទីណា ក៏ទៅក្នុងទីនោះ ១ **ក្វ វាទិតំ** ការប្រគំក្នុងទីណា ក៏ទៅក្នុងទីនោះ ១ **ក្វ អក្ខាតំ** គេប្រជុំនិយាយ

---

១២. រមែងត្រូវគេចោទបង្កាច់ក្នុងអំពើដែលខ្លួនមិនបានធ្វើសោះ ព្រោះជាន់ដានចោរ ។

រឿងព្រេងឥតប្រយោជន៍ (មានរឿងចម្បាំងនៃមហាភារតៈ និងរឿងនាងសិតាជាដើម) ក្នុងទីណា ក៏ទៅក្នុងទីនោះ ១ **ភូបាណិស្សរំ** ល្បែងវាយគង(១៣) ក្នុងទីណា ក៏ទៅក្នុងទីនោះ ១ **ភូកុម្ភថូនំ** ល្បែងវាយរនាតក្នុងទីណា ក៏ទៅក្នុងទីនោះ ១ ។ ម្នាលគហបតីបុត្ត ទោសក្នុងកិរិយាដើរមើលល្បែងមហោស្រព មាន ៦ យ៉ាងនេះឯង ។

ម្នាលគហបតីបុត្ត ទោសក្នុងការប្រកបរឿយៗ នូវការលេងល្បែងភ្នាល់ ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទ នេះមាន ៦ យ៉ាង គឺ **ជយំ វេរំ បសវតិ** បុគ្គលនោះ បើឈ្នះគេតែងបានពៀរ ១ **ជិនោ វិត្តមនុសោចតិ** បើចាញ់គេតែងសោកស្តាយទ្រព្យសម្បត្តិ ១ **សន្ទិដ្ឋិកា ធនជានិ** វិនាសទ្រព្យសម្បត្តិដែលឃើញជាក់ស្តែងទាន់ភ្នែក ១ **សភាគតស្ស វចនំ ន រូហតិ** កាលបើទៅសាលាវិនិច្ឆ័យ គេមិនជឿស្តាប់ពាក្យ ១ **មិត្តាមច្ចានំ បរិភូតោ ហោតិ** ពួកមិត្តអាមាត្យតែងបោះបង់ចោល ១ **អាវាហវិវាហកានំ អប្បត្ថិតោ ហោតិ អក្ខធុត្តោ បុរិសបុគ្គលោ**

១៣. បើតាមព្យញ្ជនៈនេះត្រូវប្រែថា ល្បែងទះដៃគឺច្រៀងប្របកែ ។

**នាលំ នារភរណាយ** ជាបុគ្គលដែលគេមិនត្រូវការដណ្ដឹង ឬឱ្យកូនស្រី ព្រោះគេគិតថា បុរសបុគ្គលអ្នកលេងល្បែងភ្នាល់មិនអាចចិញ្ចឹមប្រពន្ធបានទេ ១ ។ ម្នាលគហបតីបុត្ត ទោសក្នុងការប្រកបរឿយៗនូវការលេងល្បែង ភ្នាល់ដែលជាហេតុជាទីតាំងនៃសេចក្ដីប្រមាទនេះមាន ៦ យ៉ាងនេះឯង ។

ម្នាលគហបតីបុត្ត ទោសក្នុងការសេពគប់នូវបាបមិត្តនេះមាន ៦ យ៉ាង គឺ **យេ ធុត្តា** ពួកជនដែលជាអ្នកលេងល្បែងភ្នាល់ ១ **យេ សោណ្ឌា** ជនដែលជាអ្នកលេង[១៤] ស្រី ១ **យេ បិបាសា** ជនដែលជាអ្នកលេងផឹកសុរា ១ **យេ នេកតិកា** ជនដែលជាអ្នកបោកប្រាស់បញ្ឆោតអ្នកដទៃ ដោយរបស់ក្លែង ១ **យេ វញ្ចនិកា** ជនដែលជាអ្នកបំបាត់ប្រវ័ញ្ចន៍ អ្នកដទៃ ក្នុងទីចំពោះមុខ ១ **យេ សាហសិកា** ជនដែលជាអ្នកឆក់ ដណ្ដើមទ្រព្យអ្នកដទៃ ១ **త్యాస్స మిత్తా** 

១៤. អ្នកលេងមាន ៤ យ៉ាងគឺ អ្នកលេងស្រី ១ អ្នកលេងភគ្នី ១ អ្នកលេងផឹកស្រា ១ អ្នកលេងមើមឈើ មានស៊ីមើមដំឡូងជាដើម ១ ។

ទោសក្នុងការសេពគប់នូវបាបមិត្តមាន ៦ យ៉ាងនេះឯង ។

ម្នាលគហបតីបុត្ត ទោសក្នុងការប្រកបរឿយៗ នូវសេចក្តីខ្ជិលនេះមាន ៦ យ៉ាង គឺ **អតិសីតន្តិ កម្មំ ន ករោតិ** មិនធ្វើការងារ ដោយអាងថាត្រជាក់ណាស់ ១ **អតិឧណ្ហន្តិ កម្មំ ន ករោតិ** មិនធ្វើការងារ ដោយអាងថា ក្តៅណាស់ ១ **អតិសាយន្តិ កម្មំ ន ករោតិ** មិនធ្វើការងារ ដោយអាងថា ល្ងាចណាស់ ១ **អតិបាតោតិ កម្មំ ន ករោតិ** មិនធ្វើការងារដោយអាងថា ព្រឹកណាស់ ១ **អតិឆ្វាតោស្មីតិ កម្មំ ន ករោតិ** មិនធ្វើការងារដោយអាងថា ឃ្លានណាស់ ១ **អតិបិបាសិតោស្មីតិ កម្មំ ន ករោតិ** មិនធ្វើការងារដោយអាងថា ស្រេកណាស់ ១ ។

**តស្ស ឯវំ កិច្ចាបទេសពហុលស្ស វិហរតោ**
**អនុប្បន្នា ចេវ ភោគា នុប្បជ្ជន្តិ ឧប្បន្នា**
**ច ភោគា បរិក្ខយំ គច្ឆន្តិ**

កាលបើជនអ្នកខ្ជិលច្រអូសនោះ ច្រើនដោយពោលអាងកិច្ចយ៉ាងនេះ ភោគៈទាំងឡាយដែលមិនទាន់កើត ក៏ខានកើតឡើងផង ភោគៈទាំងឡាយដែលកើតឡើងហើយ ក៏ដល់

នូវសេចក្ដីរេចរិលទៅវិញផង ។ ម្នាលគហបតីបុត្ត ទោសក្នុងការប្រកបរឿយៗនូវសេចក្ដីខ្ជិលមាន ៦ យ៉ាង នេះឯង ។ ព្រះមានព្រះភាគ ទ្រង់បានសំដែងធម៌នេះ ហើយព្រះសុគតជាសាស្តា លុះសំដែងធម៌នេះហើយ ទ្រង់សំដែងគាថាពន្ធ័នេះតទៅទៀតថា

**ហោតិ បានសខា នាម ហោតិ សម្មិយសម្មិយោ យោ**
**ច អត្ថេសុ ជាតេសុ សហាយោ ហោតិ សោ សខា**

បុគ្គលខ្លះ ជាមិត្តសម្លាញ់បានតែក្នុងរោងសុរា ក៏មាន បុគ្គលខ្លះ ថាសម្លាញ់ៗ តែនៅចំពោះមុខក៏មាន បុគ្គលណា កាលបើប្រយោជន៍ (ខ្លួន) កើតឡើង ទើបធ្វើជាសម្លាញ់ បុគ្គលនោះ មកធ្វើជាសម្លាញ់នឹងខ្លួនក៏មាន ។

**ឧស្សូរសេយ្យា បរទារសេវនា វេរប្បសវោ**
**ច អនត្ថតា ច បាបា ច មិត្តា សុកទរិយតា**
**ច ឯតេ ឆ ឋានា បុរិសំ ធំសយន្តិ**

កិរិយាដេកដល់ថ្ងៃ ១ ធ្វើសេវនកិច្ចជាមួយប្រពន្ធ អ្នកដទៃ ១ ភាវៈជាអ្នកមានពៀរច្រើន ១ ភាវៈជាអ្នកធ្វើ អំពើឥតប្រយោជន៍ ១ បាបមិត្ត ១ ភាវៈជាអ្នកកំណាញ់ ស្វិតស្វាញ

១ ហេតុទាំង ៦ យ៉ាងនុ៎ះ រមែងបំផ្លាញបុរស (ឱ្យវិនាស) ។

**បាបមិត្តោ បាបសខោ បាបអាចារគោចរោ**

**អស្មា លោកា បរម្ហា ច ឧភយា ធំសតេ នរោ**

នរជនដែលមានមិត្តអាក្រក់ មានសម្លាញ់អាក្រក់ មានមារយាទ និងគោចរអាក្រក់ តែងវិនាសចាកលោក ទាំងពីរ គឺលោកនេះ និង លោកខាងមុខ ។

**អក្ខិត្ថិយោ វារុណី នច្ចគីតំ ទិវាសោប្បំ**

**បារិចរិយា អកាលេ បាបា ច មិត្តា សុកទរិយតា**

**ច ឯតេ ឆ ឋានា បុរិសំ ធំសយន្តិ**

ល្បែងភ្នាល់ ល្បែងស្រី និង ល្បែងសុរា ១ របាំ និងចំរៀង ១ ការដេកថ្ងៃ ១ ការឱ្យគេបំរើខ្លួនក្នុងកាលមិនគួរ ១ ពួកមិត្តអាក្រក់ ១ ភាវៈជាអ្នកមានសេចក្តីកំណាញ់ស្វិតស្វាញ ១ ហេតុទាំង ៦ នេះតែងបំផ្លាញបុរសឱ្យវិនាស ។

**អក្ខេហិ ទិព្វន្តិ សុរំ បិវន្តិ យន្តិត្ថិយោ**

**បាណសមា បរេសំ និហីនសេវី ន ច**

**វុឌ្ឍិសេវី និហីយតិ កាឡបក្ខេវ ចន្ទិមា**

ពួកជនដែលលេងល្បែងភ្នាល់ ផឹកសុរា ធ្វើសេវនកិច្ច

នឹងស្រី ដែលស្មើដោយជីវិតរបស់បុរសដទៃ សេពគប់នឹងបុគ្គលថោកទាប ( ខាតលក្ខណ៍ ) មិនសេពគប់នឹងបុគ្គលដែលមានសេចក្តីចម្រើន ( គ្រប់លក្ខណ៍ ) យសរបស់ពួកជននោះតែងសាបសូន្យ ដូចព្រះចន្ទខាងរនោច ។

**យោ វារុណិ អធនោ អកិញ្ចនោ បិបាសោសិ**
**អត្ថបាគតោ ឧទកមិវ ឥណំ វិគាហតិ**
**អាកុលំ កាហតិ ខិប្បមត្តនោ**

ជនដែលជាអ្នកផឹកសុរា ជាអ្នកខ្សត់ទ្រព្យ ជាអ្នកឥតមានកង្វល់ ដោយការងារចិញ្ចឹមជីវិត មានតែស្រវឹងជានិច្ច ប្រាសចាកសេចក្តីចម្រើន លិចចុះក្នុងបំណុល ដូចដុំថ្មលិចទៅក្នុងទឹក បុគ្គលនោះតែងធ្វើការងារឱ្យវឹកវរដល់ខ្លួនដោយឆាប់ ។

**ន ទិវាសុប្បសីលេន រត្តិនុដ្ឋានទេស្សិនា និច្ចំ**
**មត្តេន សោណ្ឌេន សក្កា អាវសិតុំ ឃរំ ។**

បុគ្គលដេកក្នុងវេលាថ្ងៃជាប្រក្រតី មិនក្រោកឡើងពីយប់ជាប្រក្រតី ជាអ្នកស្រវឹងជានិច្ច ជាអ្នកលេងល្បែងមិនអាចនឹងគ្រប់គ្រងផ្ទះសម្បែងបាន ។

**អតិសីតំ អតិឧណ្ហំ អតិសាយមិទំ អហុ**
**ឥតិ វិស្សដ្ឋកម្មន្តេ អត្ថា អច្ចេន្តិ មាណវេ**

ប្រយោជន៍ទាំងឡាយ តែងកន្លងហួសមនុស្សដែលលះបង់ចោលនូវការងារ ដោយពោលអាងថា វេលានេះត្រជាក់ណាស់ ក្តៅណាស់ ល្ងាចណាស់ ។

**យោ ច សីតញ្ច ឧណ្ហញ្ច តិណា ភិយ្យោ ន មញ្ញតិ**
**ករំ បុរិសកិច្ចានិ សោ សុខា ន វិហាយតិ**

ជនណាមួយធ្វើនូវកិច្ចការរបស់បុរស មិនអើពើនូវត្រជាក់និងក្តៅក្រៃលែងជាងស្មៅ (ទៅទៀត) ជននោះ រមែងមិនសាបសូន្យចាកសេចក្តីសុខឡើយ ។

ម្នាលគហបតីបុត្ត អ្នកត្រូវស្គាល់ពួកមនុស្សដែលមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម ៤ ពួកនេះ គឺអ្នកត្រូវស្គាល់ **អញ្ញទត្ថុហរោ** មនុស្សដែលគិតយកតែប្រយោជន៍ខ្លួន ថាមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម ១ អ្នកត្រូវស្គាល់ **វចីបរមោ** (មនុស្សល្អតែសំដី) ថាមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម ១ អ្នកត្រូវស្គាល់ **អនុប្បិយភាណី** មនុស្សដែលនិយាយចាក់បណ្តោយឱ្យគាប់ចិត្តថា មិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម ១ អ្នកត្រូវស្គាល់ **អបាយសហាយោ** មនុស្សជាសំឡាញ់ ក្នុងការដឹកនាំឱ្យវិនាសភោគៈទាំងឡាយថា មិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម ១ ។

ម្នាលគហបតីបុត្ត មនុស្សគិតយកតែប្រយោជន៍ខ្លួន មិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម (នោះ) អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាង គឺ **អញ្ញទត្ថុហរោ ហោតិ** មិត្តគិតយកតែប្រយោជន៍ខ្លួន ១ **អប្បេន ពហុមិច្ឆតិ** មិត្តប្រាថ្នាយករបស់ច្រើនដោយ (ឱ្យ) របស់តិចតួច ១ **ភយស្ស កិច្ចំ ន ករោតិ** ទាល់តែមានភ័យ ទើបជួយធ្វើកិច្ចរបស់មិត្ត ១ **សេវតិ អត្ថការណា** សេពគប់មិត្ត ព្រោះហេតុតែប្រយោជន៍ ១ ។ ម្នាលគហបតីបុត្ត មិត្តគិតយកតែប្រយោជន៍ខ្លួន មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។

ម្នាលគហបតីបុត្ត មិត្តល្អតែសំដី មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ គឺ **អតីតេន បដិសន្ថរតិ** មិត្តទទួលរាក់ទាក់ ដោយរបស់ដែលកន្លង ហើយ ១ **អនាគតេន បដិសន្ថរតិ** ទទួលរាក់ទាក់ដោយរបស់ដែលមិនទាន់មានមក ១ **និរត្ថកេន សង្គណ្ហាតិ** សង្គ្រោះដោយអំពើឥតប្រយោជន៍ ១ **បច្ចុប្បន្នេសុ កិច្ចេសុ ព្យសនំ ទស្សេតិ** កាល

កិច្ចទាំងឡាយ កើតឡើងភ្លាមៗ ក៏សម្ដែងអាងរបស់ខូចខាត[(១៥)] ១ ម្នាលគហបតីបុត្ត មិត្តល្អតែសំដី មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។

ម្នាលគហបតីបុត្ត មិត្តនិយាយចាក់បណ្ដោយឱ្យគាប់ចិត្ត មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងគឺ **បាបកម្មំបិស្ស អនុជានាតិ** បើមិត្តធ្វើអំពើអាក្រក់ក៏យល់ព្រមតាម ១ **កល្យាណំបិស្ស អនុជានាតិ** មិត្តធ្វើអំពើល្អក៏យល់ព្រមតាម ១ **សម្មុខស្ស វណ្ណំ ភាសតិ** ពណ៌នាគុណមិត្តតែក្នុងទីចំពោះមុខ ១ **បរម្មុខស្ស អវណ្ណំ ភាសតិ** ពោលទោសមិត្តក្នុងទីកំបាំងមុខ ១ ។ ម្នាលគហបតីបុត្ត មិត្តនិយាយចាក់បណ្ដោយឱ្យគាប់ចិត្ត មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។

ម្នាលគហបតីបុត្ត មនុស្សជាសំឡាញ់ក្នុងផ្លូវវិនាស មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយ ស្ថាន ៤ យ៉ាង គឺ **សុរាមេរយមជ្ជប្បមាទដ្ឋានានុយោគេ សហាយោ**

---

១៥ ពឹងការអ្វីមិនបាន បើត្រូវពឹងរកអ្វីៗ ក៏ប្រាប់ថា របស់នោះខូច នេះបាត់ ជាដើម ។

**ហោតិ** ជាសំឡាញ់ក្នុងកិរិយាប្រកបរឿយៗនូវការផឹកទឹកស្រវឹង គឺសុរាមេរ័យ ដែលជាទីតាំងនៃសេចក្ដីប្រមាទ ១ **វិកាល-វិសិខាចរិយានុយោគេ សហាយោ ហោតិ** ជាសំឡាញ់ក្នុងកិរិយាប្រកបរឿយៗនូវការត្រាច់ទៅតាមច្រក ល្ហកខុសកាល ១ **សមជ្ជាភិចរណេ សហាយោ ហោតិ** ជាសំឡាញ់ក្នុងកិរិយាដើរមើលល្បែងមហោស្រព ១ **ជូតប្បមាទដ្ឋានានុយោគេ សហាយោ ហោតិ** ជាសំឡាញ់ ក្នុងកិរិយាប្រកបរឿយៗនូវល្បែងភ្នាល់ដែលជាហេតុជាទី តាំងនៃសេចក្ដីប្រមាទ ១ ។ ម្នាលគហបតីបុត្ត មនុស្សជាសំឡាញ់ក្នុងផ្លូវវិនាស មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។ ព្រះមានព្រះភាគ ទ្រង់បានសម្ដែងសេចក្ដីនេះ លុះព្រះសុគតសាស្ដា សម្ដែងសេចក្ដីនេះហើយ ទើបទ្រង់សម្ដែងពាក្យគាថាព័ន្ធ តទៅទៀតថា

**អញ្ញទត្ថុហរោ មិត្តោ យោ ច មិត្តោ វចីបរមោ**
**អនុប្បិយញ្ច យោ អាហុ អបាយេសុ ច យោ សខា**
**ឯតេ អមិត្តេ ចត្តារោ ឥតិ វិញ្ញាយ បណ្ឌិតោ អារកា**

**បរិវជ្ជេយ្យ មត្តំ បដិភយំ យថា**

បុគ្គលដែលជាមិត្តគិតយកតែប្រយោជន៍ខ្លួន ១ បុគ្គលដែលជាមិត្តល្អតែសំដី ១ បុគ្គលដែលនិយាយចាក់បណ្តោយឱ្យគាប់ចិត្ត ១ បុគ្គលដែលជាសំឡាញ់ក្នុងផ្លូវវិនាស ១ បណ្ឌិតដឹងថាបុគ្គលទាំង ៤ ពួកនុ៎ះ មិនមែនជាមិត្ត ហើយគប្បីចៀសវាងឱ្យឆ្ងាយ ដូចជាអ្នកដំណើរ ចៀសវាងផ្លូវដែលប្រកបដោយភ័យដូច្នោះ។

ម្នាលគហបតីបុត្ត មនុស្ស ៤ ពួកនេះ អ្នកត្រូវដឹងថាជាមិត្តមានសន្តានល្អ គឺ **ឧបការកោ** មិត្តមានឧបការៈ អ្នកត្រូវដឹងថាជាមិត្ត មានសន្តានល្អ ១ **សមានសុខទុក្ខោ** មិត្តរួមសុខទុក្ខ អ្នកត្រូវដឹងថា ជាមិត្តមានសន្តានល្អ ១ **អត្ថក្ខាយី** មិត្តប្រាប់ប្រយោជន៍ អ្នកត្រូវដឹងថា ជាមិត្តមានសន្តានល្អ ១ **អនុកម្បកោ** មិត្តមានសេចក្តីឈឺឆ្អាល អ្នកត្រូវដឹងថា ជាមិត្តមានសន្តានល្អ ១ ។

ម្នាលគហបតីបុត្ត មិត្តមានឧបការៈ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងគឺ **បមត្តំ រក្ខតិ** រក្សាមិត្ត

ដែលធ្វេសប្រហែស ១ **បមត្តស្ស សាបតេយ្យំ រក្ខតិ** រក្សាសម្បត្តិរបស់មិត្តដែលធ្វេសប្រហែស ១ **ភីតស្ស បដិសរណំ ហោតិ** ជាទីពឹងពំនាក់នៃមិត្តដែលមានសេចក្តីភិតភ័យ ១ **ឧប្បន្នេសុ កិច្ចេសុ ករណីយេសុ តទ្ទិគុណំ ភោគំ អនុប្បទេតិ** កាលបើកិច្ចដែលត្រូវធ្វើកើតឡើងហើយ តែងជួយផ្តល់ភោគៈ ជាទ្វិគុណជាងទ្រព្យ ដែលមិត្ត ត្រូវការនោះ ១ ។ ម្នាលគហបតីបុត្ត មិត្តមានឧបការៈ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ។

ម្នាលគហបតីបុត្ត មិត្តរួមសុខទុក្ខ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺ **គុយ្ហមស្ស អាចិក្ខតិ** ប្រាប់នូវអាថ៌កំបាំងរបស់ខ្លួនដល់មិត្ត ១ **គុយ្ហមស្ស បរិគុយ្ហតិ** ជួយបិទបាំងនូវអាថ៌កំបាំងរបស់មិត្ត ១ **អាបទាសុ ន វិជហតិ** មិនបោះបង់គ្នា ក្នុងគ្រាមានវិបត្តិ ១ **ជីវិតំបិស្ស អត្ថាយ បរិច្ចត្តំ ហោតិ** សូម្បីជីវិតក៏ហ៊ានលះបង់ដើម្បីប្រយោជន៍ដល់មិត្ត(ស្ងួប្តូរជីវិត) ១ ។

ម្នាលគហបតីបុត្ត មិត្តរួមសុខទុក្ខ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ។

ម្នាលគហបតីបុត្ត មិត្តប្រាប់ប្រយោជន៍ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺ **បាបា និវារេតិ** ហាមមិត្តឱ្យឃ្លាតចាកអំពើអាក្រក់ ១ **កល្យាណេ និវេសេតិ** ដឹកនាំឱ្យមិត្ត តម្កល់នៅតែក្នុងអំពើល្អ ១ **អស្សុតំ សាវេតិ** ឱ្យបានឮពាក្យ ដែលមិនធ្លាប់បានឮ ១ **សគ្គស្ស មគ្គំ អាចិក្ខតិ** ប្រាប់ផ្លូវឋានសួគ៌ ១ ។ ម្នាលគហបតីបុត្ត មិត្តប្រាប់ប្រយោជន៍ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ។

ម្នាលគហបតីបុត្ត មិត្តមានសេចក្តីឈឺឆ្អាល ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺ **អភវេនស្ស ន នន្ទតិ** ជួយព្រួយចិត្តពីព្រោះមិត្តបានសេចក្តីវិនាស ១ **ភវេនស្ស នន្ទតិ** ជួយត្រេកអរព្រោះមិត្តបាន សេចក្តីចម្រើន ១ **អវណ្ណំ ភណមានំ និវារេតិ** ទទឹងទាស់នឹងមនុស្សដែលពោលទោសមិត្ត ១ **វណ្ណំ ភណមានំ បសំសតិ** សរសើរតែមនុស្សដែលពណ៌នាគុណមិត្ត ១ ។ ម្នាលគហបតីបុត្ត មិត្តមានសេចក្តីឈឺឆ្អាល ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ។ ព្រះមានព្រះភាគទ្រង់បានសម្តែងសេចក្តី

នេះ លុះព្រះសុគត ជាសាស្តាត្រាស់សេចក្តីនេះហើយ ទើបទ្រង់សម្តែងពាក្យជាគាថាពន្ធ័ តទៅទៀតថា

**ឧបការោ ច យោ មិត្តោ សុខទុក្ខោ ច យោ សខា**
**អត្ថក្ខាយី ច យោ មិត្តោ យោ ច មិត្តានុកម្បកោ**

មិត្តដែលមានឧបការៈ សម្លាញ់ដែលរួមសុខទុក្ខ មិត្តដែលប្រាប់ប្រយោជន៍មិត្តដែលមានសេចក្តីឈឺឆ្អាល ។

**ឯតេបិ មិត្តេ ចត្តារោ ឥតិ វិញ្ញាយ បណ្ឌិតោ**
**សក្កច្ចំ បយិរូបាសេយ្យ មាតា បុត្តំវ ឱរសំ**

បណ្ឌិតស្គាល់ជាក់នូវបុគ្គលទាំង ៤ ពួកនុ៎ះថា ជាមិត្តមែនទែនហើយ គប្បីចូលទៅអង្គុយជិតស្និទ្ធស្នាល ដូចជាមាតានិងបុត្តដែលកើតពីទ្រូង ។

**បណ្ឌិតោ សីលសម្បន្នោ ជលំ អគ្គីវ ភាសតិ ភោគេ**
**សំហរមានស្ស ភមរស្សេវ ឥរីយតោ ។**

អ្នកប្រាជ្ញបរិបូណ៌ដោយសីល តែងរុងរឿង ដូចជាភ្លើងដែលភ្លឺដូច្នោះឯង កាលបុគ្គលសន្សំទ្រព្យ រមែងធ្វើទ្រព្យឱ្យជាគំនរដូចជាឃ្មុំដូច្នោះឯង ។

**ភោគា សន្និចយំ យន្តិ ឧម្មិកាឧបចីយតិ ឯវំ**
**ភោគេ សមាហរិត្វា អលមត្តោ កុលេ គិហី**

ភោគៈទាំងឡាយ តែងដល់នូវការពូនជាគំនរ ដូចជាដំបូកដែលកណ្ដៀរកពូនដូច្នោះឯង ។ គ្រហស្ថក្នុងត្រកូលបានសន្សំភោគៈទាំងឡាយយ៉ាងនេះហើយ ទើបអាង (តាំងខ្លួន) ។

**ចតុធា វិភជេ ភោគេ សវេ មិត្តានិ គន្ថតិ**
**ឯកេន ភោគេ ភុញ្ជេយ្យ ទ្វីហិ កម្មំ បយោជយេ**
**ចតុត្ថញ្ច និធាបេយ្យ អាបទាសុ ភវិស្សតីតិ**

កុលបុត្តដែលចែកភោគៈទាំងឡាយជា ៤ ចំណែកគឺ បរិភោគភោគៈទាំងឡាយ ១ ចំណែក ប្រកបការងារពីរចំណែក ទាំងតម្កល់ទុកនូវចំណែកទី ៤ ដោយក្រែងមានអន្តរាយទាំងឡាយ (ទៅខាងមុខ) កុលបុត្រនោះ ទើបឈ្មោះថា ចងបាច់មិត្តទាំងឡាយបាន[១៦] ។

---

១៦. ចំណែកទី ១ បរិភោគប្រើប្រាស់ចាយវាយ ចំណែកទី ២ ទី ៣ ប្រកបការងារ គឺប្រកបកសិកម្ម និងពាណិជ្ជកម្មផ្សេងៗ ចំណែកជាគម្រប់ ៤ ទុកសម្រាប់ការពារអន្តរាយផ្សេងៗ មានអន្តរាយអំពីស្ដេចជាដើម ។ម្យ៉ាងទៀត ឱ្យរំលែកអំពីចំណែក ទាំង ៤ នោះធ្វើកុសល ឬឱ្យជាថ្លៃគ្រឿងស្លៀកពាក់នឹងឈ្នួលកោរកាត់ ( អដ្ឋកថា ) ។

ម្នាលគហបតីបុត្ត អរិយសាវក បិទបាំងទិសទាំង ៦ ដូចម្ដេច ។ ម្នាលគហបតីបុត្ត អ្នកត្រូវដឹងទិសទាំង ៦ ដូច្នេះគឺ **បុរត្ថិមា ទិសា មាតាបិតរោ** មាតាបិតា អ្នកត្រូវដឹងថា ទិសខាងកើត ១ **ទក្ខិណា ទិសា អាចរិយា** អាចារ្យ អ្នកត្រូវដឹងថា ទិសខាងត្បូង ១ **បច្ឆិមា ទិសា បុត្តទារា** កូននិងប្រពន្ធ អ្នកត្រូវដឹងថា ទិសខាងលិច ១ **ឧត្តរា ទិសា មិត្តាមច្ចា** មិត្តអាមាត្យ អ្នកត្រូវដឹងថា ទិសខាងជើង ១ **ហេដ្ឋិមា ទិសា ទាសកម្មករា** ទាសៈនិងកម្មករ[១៧] អ្នកត្រូវដឹងថា ទិសខាងក្រោម ១ **ឧបរិមា ទិសា សមណព្រាហ្មណា** សមណៈព្រាហ្មណ៍ អ្នកត្រូវដឹងថា ទិសខាងលើ ១ ។

ម្នាលគហបតីបុត្ត មាតាបិតាជាទិសខាងកើត កូនត្រូវទំនុកបំរុង ដោយស្ថានទាំងឡាយ ៥ យ៉ាង គឺ **ភតោ នេសំ ភរិស្សាមិ** កូនត្រូវតាំងចិត្តថា អាត្មាអញ មាតាបិតាបានចិញ្ចឹមរក្សាមកហើយ នឹងចិញ្ចឹមមាតាបិតាវិញ ១ **កិច្ចំ នេសំ ករិស្សាមិ** នឹងជួយធ្វើការងាររបស់មាតាបិតា ១ **កុលវំសំ ឋបេស្សាមិ**

---

១៧. ខ្ញុំកំដរនិងអ្នកធ្វើការស៊ីឈ្នួល ។

ទាំងតម្កល់វង្សត្រកូល ១ **ទាយជ្ជំ បដិបជ្ជាមិ** ប្រតិបត្តិឱ្យជាអ្នកសមគួរ ទទួលទ្រព្យមត៌កបាន ១ **អថខា បន បេតានំ កាលកតានំ ទក្ខិណំ អនុប្បទស្សាមិ** មួយទៀត ឧទ្ទិសទក្ខិណាទានដល់មាតាបិតា ដែលធ្វើកាលកិរិយាទៅកាន់បរលោកហើយ ១ ។ ម្នាលគហបតីបុត្ត មាតាបិតាជាទិសខាងកើត ដែលកូនទំនុកបំរុងដោយស្ថានទាំងឡាយ ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះកូនដោយស្ថានទាំងឡាយ ៥ យ៉ាងវិញដូច្នេះ គឺ **បាបា និវារេន្តិ** ហាមឃាត់កូនចាកអំពើអាក្រក់ ១ **កល្យាណេ និវេសេន្តិ** ឱ្យកូនតម្កល់នៅតែក្នុងអំពើល្អ ១ **សិប្បំ សិក្ខាបេន្តិ** ឱ្យកូនរៀនសូត្រសិល្បសាស្ត្រ ១ **បដិរូបេន ទារេន សញ្ញោជេន្តិ** ដណ្តឹងភរិយាស្វាមីសមគួរឱ្យ ១ **សមយេ ទាយជ្ជំ និយ្យាទេន្តិ** ចែកទ្រព្យឱ្យកូនក្នុងសម័យគួរ ១ ។ ម្នាលគហបតីបុត្ត មាតាបិតាជាទិសខាងកើត ដែលកូនទំនុកបំរុងដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះកូនដោយស្ថាន ៥ យ៉ាងនេះ ទិសខាងកើតនោះ ដែលកូនបានបិទបាំងហើយ ជាទិសមានសេចក្តីក្សេម ឥតមានភយន្តរាយយ៉ាងនេះ ។

ម្នាលគហបតីបុត្ត អាចារ្យជាទិសខាងត្បូង ដែលសិស្សត្រូវប្រតិបត្តិ ដោយស្ថាន ៥ យ៉ាងគឺ **ឧដ្ឋានេន** ដោយការក្រោកឡើងទទួល ១ **ឧបដ្ឋានេន** ដោយការគាល់បម្រើ ១ **សុស្សូសាយ** ដោយការជឿស្តាប់ឱវាទ ១ **បារិចរិយាយ** ដោយការបម្រើតូចៗ មានឱ្យទឹកលុបមុខ និង ឈើស្ទន់ជាដើម ១ **សក្កច្ចំ សិប្បំ បដិគ្គហណេន** ដោយការរៀនសិល្បសាស្ត្រដោយគោរព ១ ។ ម្នាលគហបតីបុត្ត អាចារ្យជាទិសខាងត្បូង ដែលសិស្សត្រូវប្រតិបត្តិដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះសិស្សដោយស្ថាន ៥ យ៉ាងវិញ គឺ **សុវិនីតំ វិនេន្តិ** ដឹកនាំល្អ ១ **សុគ្គហិតំ គាហាបេន្តិ** ឱ្យរៀនល្អ ១ **សព្វសិប្បស្សុតំ សមក្ខាយិនោ ភវន្តិ** ប្រៀនប្រដៅសិស្ស ឱ្យចេះត្រឹមត្រូវក្នុងសិល្ប សាស្ត្រសព្វគ្រប់ ១ **មិត្តាមច្ចេសុ បដិវេទេន្តិ** តែងលើកតម្កើងក្នុងទីប្រជុំមិត្តអាមាត្យ ១ **ទិសាសុ បរិត្តាណំ ករោន្តិ** ធ្វើសេចក្តីការពារក្នុងទិសទាំងឡាយ ១ ។ ម្នាលគហបតីបុត្ត ពួកអាចារ្យជាទិសខាងត្បូង ដែលសិស្សត្រូវប្រតិបត្តិដោយស្ថាន ៥ យ៉ាងនេះហើយ រមែងអនុគ្រោះសិស្សដោយស្ថាន ៥

យ៉ាងនេះ ទិសខាងត្បូងនោះ ដែលសិស្សបានបិទបាំងហើយ ជាទិសមានសេចក្តីក្សេម ឥតមានភយន្តរាយយ៉ាងនេះ ។

ម្នាលគហបតីបុត្ត ភរិយាជាទិសខាងលិច ស្វាមីត្រូវទំនុកបំរុងដោយស្ថានទាំងឡាយ ៥ យ៉ាងគឺ **សម្មាននាយ** ដោយការរាប់អាន ជាភរិយាពេញទី ១ **អវិមាននាយ** ដោយមិនមើលងាយ ១ **អនតិចរិយាយ** ដោយមិនប្រព្រឹត្តក្បត់ចិត្ត ១ **ឥស្សរិយវោស្សគ្គេន** ដោយប្រគល់ឱ្យជាធំ (ក្នុងការផ្ទះ) ១ **អលង្ការានុប្បទានេន** ដោយការឱ្យគ្រឿងតែងខ្លួន ១ ។ ម្នាលគហបតីបុត្ត ភរិយាជាទិសខាងលិច ដែលស្វាមីត្រូវទំនុកបំរុងដោយស្ថានទាំងឡាយ ៥ យ៉ាង នេះឯងហើយ រមែងអនុគ្រោះស្វាមីដោយស្ថានទាំងឡាយ ៥ យ៉ាងវិញ គឺ **សុសំវិហិតកម្មន្តា ច ហោតិ** ចាត់ចែងការងារដោយល្អ ១ **សុសង្គហិតបរិជនា ច** សង្គ្រោះជន ជាញាតិទាំងពីរខាងដោយល្អ ១ **អនតិចារិនី ច** មិនប្រព្រឹត្តក្បត់ចិត្ត ១ **សម្ភតញ្ច អនុរក្ខតិ** ថែទាំទ្រព្យដែលស្វាមីរកបានមក ១ **ទក្ខា ច ហោតិ អនលសា សព្វកិច្ចេសុ** ឈ្លាសមិនខ្ជិលច្រអូសក្នុងកិច្ចការសព្វគ្រប់ ១ ។

ម្នាលគហបតីបុត្ត ភរិយាជាទិសខាងលិច ដែលស្វាមីត្រូវទំនុកបំរុងដោយស្ថានទាំងឡាយ ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះស្វាមីដោយស្ថាន ៥ យ៉ាងនេះ ទិសខាងលិចនោះដែលស្វាមីបិទបាំងហើយ ជាទិសមានសេចក្តីក្សេម ឥតមានភយន្តរាយយ៉ាងនេះ ។

ម្នាលគហបតីបុត្ត មិត្តអាមាត្យជាទិសខាងជើង កុលបុត្តត្រូវប្រតិបត្តិដោយស្ថានទាំងឡាយ ៥ យ៉ាង គឺ **ទានេន** ដោយការឱ្យរបស់ ១ **បិយវជ្ជេន** ដោយការនិយាយតែពាក្យគាប់ចិត្ត ១ **អត្ថចរិយាយ** ដោយការប្រព្រឹត្តឱ្យជាប្រយោជន៍ ១ **សមានត្តតាយ** ដោយការប្រព្រឹត្តខ្លួនស្មើ ១ **អវិសំវាទនតាយ** ដោយការមិនកុហក បញ្ឆោត ១ ។ ម្នាលគហបតីបុត្ត មិត្តអាមាត្យ ជាទិសខាងជើង ដែលកុលបុត្តត្រូវប្រតិបត្តិដោយស្ថានទាំងឡាយ ៥ នេះឯងហើយ រមែងអនុគ្រោះកុលបុត្តដោយស្ថាន ៥ យ៉ាងគឺ **បមត្តំ រក្ខន្តិ** រក្សាមិត្តដែលធ្វេសប្រហែស ១ **បមត្តស្ស សាបតេយ្យំ រក្ខន្តិ** ជួយថែទាំទ្រព្យសម្បត្តិ របស់មិត្តដែលធ្វេសប្រហែស ១ **ភីតស្ស សរណំ ហោន្តិ**

ជាទីពឹងរបស់មិត្តដែលមានភ័យ ១ **អាបទាសុ ន ទិជហន្តិ** មិនបោះបង់គ្នាក្នុងគ្រាវិបត្តិ ១ **អបរបជំចិស្ស បជិបូជេន្តិ** រាប់អានរហូតដល់ផៅពង្សរបស់មិត្ត ១ ។ ម្នាលគហបតីបុត្តមិត្តអាមាត្យ ជាទិសខាងជើង ដែលកុលបុត្តត្រូវប្រតិបត្តិដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះកុលបុត្តដោយស្ថាន ៥ យ៉ាងនេះ ទិសខាងជើងនុ៎ះ ដែលកុលបុត្តបានបិទបាំងហើយ ជាទិសមានសេចក្ដីក្សេម ឥតមានភយន្តរាយយ៉ាងនេះ ។

ម្នាលគហបតីបុត្ត ទាសៈនិងកម្មករ ជាទិសខាងក្រោមចៅហ្វាយ នាយត្រូវទំនុកបំរុងដោយស្ថាន ៥ យ៉ាង គឺ **យថាពលំ កម្មន្តំ សំវិធានេន** ដោយការចាត់ចែងការងារ សមគួរតាមកម្លាំង ១ **ភត្តវេតនានុប្បទានេន** ដោយការឱ្យនូវភត្តាហារនិងថ្លៃឈ្នួល ១ **គិលានុបដ្ឋានេន** ដោយការព្យាបាលក្នុងវេលាឈឺថ្កាត់ ១ **អច្ឆរិយានំ រសានំ សំវិភាគេន** ដោយការចែករំលែកនូវរបស់ដែលមានរស ត្រកាលចម្លែក ១ **សមយេ វោស្សគ្គេន** ដោយការឱ្យឈប់សម្រាកក្នុងសម័យគួរ ១ ។

ម្នាលគហបតីបុត្ត ទាសៈនិងកម្មករ ជាទិសខាងក្រោមដែលចៅហ្វាយនាយ ទំនុកបំរុងដោយស្ថាន ៥ នេះឯងហើយ រមែងអនុគ្រោះ ចៅហ្វាយនាយដោយស្ថាន ៥ យ៉ាង គឺ **បុព្វុដ្ឋាយិនោ ច ហោន្តិ** ក្រោកឡើងធ្វើការងារមុនចៅហ្វាយនាយ ១ **បច្ឆានិបាតិនោ ច** ឈប់ធ្វើការងារក្រោយចៅហ្វាយនាយ ១ **ទិន្នាទាយិនោ ច** កាន់យកតែរបស់ដែលចៅហ្វាយនាយឱ្យ ១ **សុកតកម្មករា ច** ធ្វើការងាររបស់ចៅហ្វាយ នាយដោយយកចិត្តទុកដាក់ ១ **កិត្តិវណ្ណហរា ច** នាំកិត្តិគុណរបស់ចៅហ្វាយនាយ ទៅថ្លែងក្នុងទីនោះៗ ១ ។ ម្នាលគហបតីបុត្ត ទាសៈនិងកម្មករជាទិសខាងក្រោម ដែលចៅហ្វាយនាយ ត្រូវទំនុកបំរុងដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះដល់ចៅហ្វាយនាយដោយស្ថាន ៥ យ៉ាងនេះ ទិសខាងក្រោមនុ៎ះ ដែលចៅហ្វាយនាយបានបិទបាំងហើយ ជាទិសមានសេចក្តីក្សេម ឥតមានភយន្តរាយយ៉ាងនេះ ។

ម្នាលគហបតីបុត្ត សមណព្រាហ្មណ៍ជាទិសខាងលើ កុលបុត្តត្រូវផ្គត់ផ្គង់ដោយស្ថាន ៥ យ៉ាង គឺ **មេត្តេន កាយកម្មេន** ដោយកាយកម្មប្រកបដោយមេត្តា ១ **មេត្តេន វចីកម្មេន** ដោយ

វចីកម្មប្រកបដោយមេត្តា ១ **មេត្តេន មនោកម្មេន** ដោយមនោកម្មប្រកបដោយមេត្តា ១ **អនាវដទ្វារតាយ** ជាអ្នកមិនបិទទ្វារ[១៨] ផ្ទះ ១ **អាមិសានុប្បទានេន** ដោយកិរិយាឱ្យអាមិសទាន ១ ។ ម្នាលគហបតីបុត្រ សមណព្រាហ្មណ៍ជាទិសខាងលើ ដែលកុលបុត្រទំនុកបម្រុង ដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះ កុលបុត្រដោយស្ថាន ៦ គឺ **បាបា និវារេន្តិ** ហាមឃាត់ កុលបុត្រឱ្យចាកអំពើអាក្រក់ ១ **កល្យាណេ និវេសេន្តិ** ឱ្យ តាំងនៅតែក្នុងអំពើល្អ ១ **កល្យាណេន មនសា អនុកម្បន្តិ** អនុគ្រោះដោយចិត្តដ៏ល្អ ១ **អស្សុតំ សាវេន្តិ** ឱ្យបានស្តាប់ពាក្យដែលមិនធ្លាប់ស្តាប់ ១ **សុតំ បរិយោទបេន្តិ** បំភ្លឺសេចក្តីដែលធ្លាប់ស្តាប់ហើយ ១ **សគ្គស្ស មគ្គំ អាចិក្ខន្តិ** ប្រាប់ផ្លូវសួគ៌ ១ ។ ម្នាលគហបតីបុត្រ សមណព្រាហ្មណ៍ជាទិសខាងលើ ដែលកុលបុត្រផ្គត់ផ្គង់ដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែង

---

១៨. អដ្ឋកថា ថា ទ្វារផ្ទះបើកទាំងអស់ក្តី បិទទាំងអស់ក្តី បើមិនឱ្យអ្វី ឬធ្វើល្អអ្វីដល់អ្នកមានសីលសោះ ក៏ឈ្មោះថា បិទទ្វារផ្ទះដែរ បើឱ្យ ឬធ្វើល្អអ្វីដល់អ្នកមានសីល ក៏ឈ្មោះថាបើកហើយ ។

អនុគ្រោះ កុលបុត្តដោយស្ថាន ៦ នេះទិសខាងលើនុ៎ះដែលកុលបុត្តបានបិទបាំងហើយ ជាទិសមានសេចក្ដីក្សេម ឥតមានភយន្ដរាយយ៉ាងនេះ ។ ព្រះមានព្រះភាគបានសម្ដែងសេចក្ដីនេះ ព្រះសុគតជាសាស្ដា លុះសម្ដែងសេចក្ដីនេះហើយ ទ្រង់ត្រាស់ពាក្យជាគាថាព័ន្ធតទៅទៀតថា

**មាតាបិតា ទិសា បុព្វា អាចរិយា ទក្ខិណា ទិសា បុត្តទារា ទិសា បច្ឆា មិត្តាមច្ចា ច ឧត្តរា ទាសកម្មករា ហេដ្ឋា ឧទ្ធំ សមណព្រាហ្មណា ឯតា ទិសា នមស្សេយ្យ អលមត្តោ កុលេ គិហី**

មាតាបិតា ជាទិសខាងកើត អាចារ្យជាទិសខាងត្បូង កូនប្រពន្ធ ជាទិសខាងលិច មិត្ត/អាមាត្យជាទិសខាងជើង ទាសៈនិងកម្មករ ជាទិសខាងក្រោម សមណព្រាហ្មណ៍ ជាទិសខាងលើ គ្រហស្ថក្នុងត្រកូលដែលអាចគ្រប់គ្រងផ្ទះ គប្បីនមស្ការទិសទាំងឡាយនុ៎ះ ។

**បណ្ឌិតោ សីលសម្បន្នោ សណ្ហោ ច បដិភាណវា និវាតវុត្តិ អត្ថទ្ធោ តាទិសោ លភតេ យសំ ឧដ្ឋានកោ អនលសោ អាបទាសុ ន វេធតិ អច្ឆិទ្ទវុត្តិ**

**មេធាវី តាទិសោ លភតេ យសំ ។**

បណ្ឌិត[១៩] បរិបូណ៌ដោយសីល មានវាចាដ៏ពីរោះ មានប្រាជ្ញាវៃ[២០] មានកិរិយាប្រព្រឹត្តឱនលំទោនជាប្រក្រតី មិនរឹងត្អឹង បុគ្គលមានសភាពដូច្នោះ រមែងបានយស បុគ្គលមានព្យាយាមរវៀសរវៃ មិនខ្ជិលច្រអូស រមែងមិនញាប់ញ័រក្នុងអន្តរាយទាំងឡាយ បុគ្គលមានកិរិយាប្រព្រឹត្តឥតចន្លោះ មានប្រាជ្ញាវាងវៃ បុគ្គលមានសភាពដូច្នោះ រមែងបានយស ។

**សង្គាហកោ មិត្តករោ វទញ្ញូ វីតមច្ឆរោ**
**នេតា វិនេតា អនុនេតា តាទិសោ លភតេ យសំ**

បុគ្គលមានសេចក្តីសង្គ្រោះ ជាអ្នកចងមិត្ត ជាអ្នកដឹងដំណើរពាក្យ[២១] ជាអ្នកប្រាសចាកសេចក្តីកំណាញ់ ជាអ្នកដឹកនាំពន្យល់ការណ៍ផ្សេងៗ ជាអ្នកណែនាំរឿយៗ បុគ្គលមានសភាពដូច្នោះ រមែងបានយស ។

---

១៩-២០ អដ្ឋកថា បណ្ឌិតមានប្រាជ្ញាវៃ ក្នុងស្ថានជាទីសំពះទិស ។

២១. សំដៅយកមនុស្សនាំពាក្យខ្លួនដែលបានថា ឱ្យរបស់អ្វី ដល់សំឡាញ់ហើយក៏ឱ្យទាល់តែបានដឹងចិត្តសំឡាញ់ថា ចង់បានអ្វី ក៏ឱ្យរបស់នោះ ឬដឹងថា សំឡាញ់ខ្វះខាតអ្វីក៏ឱ្យរបស់នោះ ។

**ទានញ្ច បិយវជ្ជញ្ច អត្ថចរិយា ច យា ឥធ**
**សមានត្តតា ច ធម្មេសុ តត្ថ តត្ថ យថារហំ ។**

ទាន ១ ពាក្យពីរោះ ១ សេចក្ដីប្រព្រឹត្តជាប្រយោជន៍ក្នុងលោកនេះ ១ ភាវៈជាអ្នកមានចិត្តស្មើក្នុងធម៌ទាំឡាយ និងក្នុងបុគ្គលនោះៗ តាមសមគួរ ១ ។

**ឯតេ ខោ សង្គហា លោកេ រថស្សាណីវ យាយតោ**
**ឯតេ ច សង្គហា នាស្សុ ន មាតា បុត្តការណា**
**លភេថ មានំ បូជំ វា បិតា វា បុត្តការណា**

សង្គហធម៌ទាំងនេះ ( មានក្នុងលោក ទើបលោកប្រព្រឹត្តទៅបាន) ដូចជារថមានប្រែកទប់ ទើបប្រព្រឹត្តទៅបានដូច្នោះឯង បើសង្គហធម៌ទាំងនេះ មិនមានហើយ មាតាក្ដី បិតាក្ដី ក៏មិនបានទូវសេចក្ដីរាប់អាន និង ការបូជាអំពីកិច្ចដែលកូនត្រូវធ្វើ ។

**យស្មា ច សង្គហា ឯតេ សមវេក្ខន្តិ បណ្ឌិតា**
**តស្មា មហត្តំ បប្បោន្តិ បាសំសា ច ភវន្តិ តេ**

ព្រោះហេតុតែអ្នកប្រាជ្ញទាំងឡាយ សំឡឹងឃើញសង្គហធម៌ទាំងនោះ ដោយប្រពៃហេតុនោះ បានជាលោក

ដល់នូវភារៈជាធំផងគួរគេសរសើរផង ។

កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ សិង្គាលកគហបតីបុត្រ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះអង្គសម្តែងហើយ ដោយអនេកបរិយាយយ៉ាងនេះ (ភ្លឺច្បាស់ណាស់) ដូចជាមនុស្សផ្ងាររបស់ដែលផ្កាប់ ឬដូចគេបើកបង្ហាញរបស់ដែលបិទបាំង ឬក៏ដូចគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោត ដូចជាគេទ្រោលប្រទីបក្នុងទីងងឹត ដោយគិតថា មនុស្សអ្នកមានចក្ខុទាំងឡាយ រមែងឃើញនូវរូបទាំងឡាយ ខ្ញុំព្រះអង្គនោះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ថាជាសរណៈចាប់ដើមតាំងពីថ្ងៃនេះទៅ សូមព្រះមានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសកដល់នូវសរណៈស្មើដោយជីវិត ចាប់ដើមតាំងពីថ្ងៃនេះរៀងទៅ ។

ចប់សិង្គាលកសូត្រ

## ភាសិតោវាទសង្ខេប

**ឧភាស** : ខ្ញុំសូមគោរព

**យោ បន ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ បដិបត្តិបូជាយ**

អ្នកឯណាមួយ ជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរ ដល់ធម៌ ជាអ្នកប្រតិបត្តិដោយត្រឹមត្រូវ ជាអ្នកប្រព្រឹត្តតាមធម៌ជាប្រក្រតី អ្នកនោះ ឈ្មោះថា ធ្វើសក្ការៈ ធ្វើសេចក្តីគោរពរាប់អានបូជានូវព្រះតថាគត ដោយបដិបត្តិបូជា ជាបូជាដ៏ឧត្តម ។

**សព្វបាបស្ស អករណំ កុសលស្សូបសម្បទា**
**សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ**

កិរិយាមិនធ្វើនូវបាបទាំងពួង កិរិយាបំពេញកុសល កិរិយាធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់ ទាំងនេះ ជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

**ខន្តិ បរមំ តបោ តីតិក្ខា**
**និព្វានំ បរមំ វទន្តិ ពុទ្ធា**

**ន ហិ បព្វជិតោ បរូបឃាតី**
**សមណោ ហោតិ បរំ វិហេឋយន្តោ**

អំណត់គឺសេចក្ដីអត់ធន់ ជាតបៈធម៌ដ៏ឧត្តម ព្រះពុទ្ធទាំងឡាយ ទ្រង់ត្រាស់ថា ព្រះនិព្វានជាគុណជាតដ៏ឧត្តម អ្នកបួសដែលបៀតបៀនសត្វដទៃ សម្លាប់សត្វដទៃ មិនមែនជាបព្វជិត មិនមែនជាសមណៈឡើយ ។

**អនូបវាទោ អនូបឃាតោ បាតិមោក្ខេ ច សំវរោ**
**មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ**
**អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនំ**

កិរិយាមិនតិះដៀល (អ្នកដទៃ) ១ កិរិយាមិនបៀតបៀន (អ្នកដទៃ) ១ កិរិយាសង្រួមក្នុងបាតិមោក្ខ ១ ភាវៈដឹងប្រមាណក្នុងភត្តាហារ ១ ទីដេកនិងទីអង្គុយដ៏ស្ងាត់ ១ កិរិយាបំពេញព្យាយាមក្នុងអធិចិត្ត ១ ទាំងនេះ ជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

**សីលសមាធិគុណានំ ខន្តិ បធានការណំ**
**សព្វេបិ កុសលា ធម្មា ខន្ត្យាយេវ វឌ្ឍន្តិ តេ**

សេចក្ដីអត់ធន់ ជាហេតុជាទីតាំងនៃគុណ គឺសីល និង

សមាធិទាំងឡាយ ធម៌ទាំងឡាយជាកុសលទាំងអស់នោះ តែងចម្រើនដោយសេចក្តីអត់ធន់មែនពិត ។

**ភេទលានំបិ បាបានំ ខន្តិ មូលំ និកន្តតិ**
**គរហកលហាទីនំ មូលំ ខណតិ ខន្តិកោ**

សេចក្តីអត់ធន់ តែងកាត់បង់បាននូវឫសនៃបាបទាំងឡាយទាំងអស់ បុគ្គលអ្នកអត់ធន់ ឈ្មោះថា ជីករំលើងនូវឫសនៃទោសទាំងឡាយ មានពាក្យតិះដៀល និងការឈ្លោះប្រកែកជាដើម ។

**ខន្តិ ធីរស្សលង្ការោ ខន្តិ តបោ តបស្សិនោ**
**ខន្តិ ពលំ វ យតីនំ ខន្តិ ហិតសុខាវហា**

សេចក្តីអត់ធន់ ជាគ្រឿងអលង្ការរបស់អ្នកប្រាជ្ញ សេចក្តីអត់ធន់ ជាគ្រឿងដុតបង់នូវបាបរបស់អ្នកដែលមានតបៈធម៌ សេចក្តីអត់ធន់ជាកម្លាំងរបស់អ្នកប្រព្រឹត្តធម៌ សេចក្តីអត់ធន់ ជាគុណជាតិនាំមកនូវប្រយោជន៍ និងសេចក្តីសុខ ។

**ខន្តិកោ មេត្តវា លាភី យសស្សី សុខសីលវា**
**បិយោ ទេវមនុស្សានំ មនាបោ ហោតិ ខន្តិកោ**

អ្នកអត់ធន់ ជាអ្នកមានមិត្តសំឡាញ់ ជាអ្នកមានលាភ

ជាអ្នកមានយស ជាអ្នកមានសេចក្តីសុខជាប្រក្រតី អ្នកអត់ធន់រមែងជាទីស្រឡាញ់ ជាទីគាប់ចិត្តនៃទេវតា និងមនុស្សទាំងឡាយ ។

**អត្ថនោបិ បរស្សញ្ច អត្ថាវហោ ច ខន្តិកោ**
**សគ្គមោក្ខគមំ មគ្គំ អារុឡ្ហោ ហោតិ ខន្តិកោ**

អ្នកអត់ធន់ ជាអ្នកនាំមកនូវប្រយោជន៍ដល់ខ្លួនឯង ផងដល់ជនទាំងឡាយឯទៀតផង អ្នកអត់ធន់ជាអ្នកឡើង កាន់ផ្លូវជាទីទៅឋានសួគ៌ និង ព្រះនិព្វាន ។

**សត្ថុនោ វចនោវាទំ ករោតិយេវ ខន្តិកោ**
**បរមាយ ច បូជាយ ជិនំ បូជេតិ ខន្តិកោ**

អ្នកអត់ធន់ ឈ្មោះថា ធ្វើតាមនូវព្រះពុទ្ធដីកា ជាឱវាទនៃព្រះសាស្តាមែនពិត អ្នកអត់ធន់ ឈ្មោះថា បូជានូវព្រះវិជិតមារដោយការបូជាដ៏ឧត្តម ។

**ទុល្លភញ្ច មនុស្សត្តំ ពុទ្ធុប្បាទោ ចទុល្លភោ**
**ទុល្លភា ខណសម្បត្តិ សទ្ធម្មោ បរមទុល្លភោ**

ភាវៈកើតជាមនុស្ស គឺសត្វទាំងឡាយ បានដោយកម្រ កិរិយាត្រាស់ជាព្រះពុទ្ធ គឺ សត្វទាំងឡាយ បានដោយកម្រ

កិរិយាដល់ព្រមដោយខណៈ គឺបានកើតជួបនឹងព្រះពុទ្ធ ឬនឹងព្រះពុទ្ធសាសនា គឺសត្វទាំងឡាយបានដោយកម្រ ធម៌របស់សប្បុរស គឺសត្វទាំងឡាយ បានដោយកម្រក្រៃលែង ។

**សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា**
**សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ**

កិរិយាបានត្រាស់នៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្តីសុខ កិរិយាសម្តែងនូវធម៌របស់សប្បុរស នាំមកនូវសេចក្តីសុខ សេចក្តីព្រមព្រៀងគ្នារបស់សង្ឃ ឬ ពួកក្រុមនាំមកនូវសេចក្តីសុខ សេចក្តីព្យាយាមរបស់អ្នកដែលព្រមព្រៀងគ្នាទាំងឡាយនាំមកនូវសេចក្តីសុខ ។

**សុខោ វិវេកោ តុដ្ឋស្ស សុតធម្មស្ស បស្សតោ**
**អព្យាបជ្ឈំ សុខំ លោកេ បាណភូតេសុ សញ្ញមោ**

សេចក្តីស្ងប់ស្ងាត់របស់អ្នកដែលត្រេកអរ (ក្នុងទីស្ងាត់) ជាអ្នកមានធម៌បានស្តាប់ហើយ ពិចារណាឃើញ (នូវធម៌) នាំមកនូវសេចក្តីសុខ កិរិយាមិនបៀតបៀន គឺកិរិយាសង្រួមចំពោះសត្វទាំងឡាយ នាំមកនូវសេចក្តីសុខក្នុងលោក ។

**សុខា វិរាគតា លោកេ កាមានំ សមតិក្កមោ**

**អស្មិមានស្ស វិនយោ ឯតំ វេ បរមំ សុខំ**

ភាវៈប្រាសចាករាគៈ គឺកិរិយាកន្លងនូវកាមទាំងឡាយ នាំមកនូវសេចក្តីសុខក្នុងលោក កិរិយាធ្វើឱ្យវិនាសនូវអស្មិមានះនេះឯង នាំមកនូវសេចក្តីសុខដ៏ឧត្តម ។

**កិច្ឆោ មនុស្សប្បដិលាភោ កិច្ឆំ មច្ចាន ជីវិតំ**
**កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ**

កិរិយាត្រឡប់បានអត្តភាពជាមនុស្ស ជាការលំបាក សេចក្តីរស់នៅរបស់សត្វទាំងឡាយ ជាការលំបាក កិរិយាស្តាប់នូវព្រះសទ្ធម្ម ជាការកម្រ កិរិយាបានត្រាស់នៃព្រះពុទ្ធទាំងឡាយ ជាការលំបាក ។

**សត្ថុនោ សទ្ធម្មំ សុត្វា សព្វស្មឹ ជិនសាសនេ**
**កប្បានិ សតសហស្សានិ ទុគ្គតឹ សោ ន គច្ឆតិ**

បុគ្គលឯណា បានស្តាប់នូវព្រះសទ្ធម្មរបស់ព្រះសាស្តា (ដែលរាប់បញ្ចូល) ក្នុងពាក្យប្រៀនប្រដៅនៃព្រះវិជិតមារទាំងពួង បុគ្គលនោះ រមែងមិនទៅកាន់ទុគ្គតិអស់សែនកប្ប ។

**បុព្វណ្ហេ បិណ្ឌបាតញ្ច សាយណ្ហេ ធម្មទេសនំ**
**បទោសេ ភិក្ខុឱវាទំ អឌ្ឍរត្តេ ទេវបញ្ហានំ**

**បច្ចូសេ គតេ ភាលេ    ភញ្ញភេ្ញ ទិវលោកនំ**
**ឯនេ បញ្ជនិនេ កិច្ចេ    ទិសោធេតិ មុនិបុង្គវោតិ**

ព្រះសម្មាសម្ពុទ្ធ ជាចម្បងជាងអស់អ្នកប្រាជ្ញ ទ្រង់ជំរះនូវពុទ្ធកិច្ចទាំងឡាយ ៥ ប្រការនេះ គឺក្នុងពេលព្រឹកទ្រង់ស្តេចទៅបិណ្ឌបាត ១ ក្នុងពេលល្ងាច ទ្រង់សម្តែងធម៌ទេសនា ១ ក្នុងពេលព្រលប់ ទ្រង់ប្រទានឱវាទដល់ពួកភិក្ខុ ១ ក្នុងពេលអធ្រាត្រ ទ្រង់ដោះប្រស្នានៃទេវតា ១ ក្នុងពេលជិតភ្លឺ[(២២)] ទ្រង់ ប្រមើលមើលនូវសត្វលោក ដែលគួរត្រាស់ដឹង និងមិនគួរត្រាស់ដឹង ១ ។

**កុក្កុដេ គព្ភវាសោ ច    សោណេ ចុនរនិក្ខមិ**
**ឧសភេ វាជសម្បត្តិ    សសេ បញ្ញិនោ ជិនោ**

ព្រះវិជិតមារ ទ្រង់យាងចុះមកអាស្រ័យនៅក្នុងព្រះគភ៌ (នៃព្រះវរមាតា) ក្នុងឆ្នាំរកា ទ្រង់ប្រសូតចាកព្រះគភ៌ ក្នុងឆ្នាំច

២២. ក្នុងអដ្ឋកថាធម្មបទ សម្តែងថា ព្រះអង្គប្រមើលមើល ឧបនិស្ស័យសត្វក្នុង ១ ថ្ងៃ ១ យប់ ពីរដង គឺក្នុងពេលជិតភ្លឺម្តង ពេលល្ងាចម្តង, ពេលជិតភ្លឺទ្រង់ប្រមើលមើលពីកណ្តាប់មាត់ចក្រវាឡ រហូតដល់មកគន្ធកុដិ, ពេលល្ងាចទ្រង់ប្រមើលមើលពីគន្ធកុដិ រហូតដល់ទៅកណ្តាប់មាត់ចក្រវាឡ ។

ទ្រង់សោយរាជ្យសម្បត្តិក្នុងឆ្នាំឆ្លូវ ទ្រង់ព្រះផ្នួសក្នុងឆ្នាំថោះ ។

**កុក្កុដេ សព្វញ្ញូ ពុទ្ធោ គត្ថ ចក្កំ បវត្តយិ**

**និព្វានគមនំ សប្បេ សហស្សំ បញ្ច មូសិកេ**

ទ្រង់ត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធក្នុងឆ្នាំរកា ទ្រង់សម្តែងនូវព្រះធម្មចក្កក្នុងឆ្នាំនោះ ទ្រង់យាងចូលកាន់ព្រះនិព្វានក្នុងឆ្នាំម្សាញ់ ព្រះពុទ្ធសាសនាទ្រង់គ្រប់ ៥០០០ គត់ ក្នុងឆ្នាំជូត ។

**ឱក្កន្តោ ច គរុវារស្មឹ សុក្រវារេ ច និក្ខមិ**

**សម្ពុទ្ធោ ពុធវារស្មឹ អង្គារេ បរិនិព្វុតោ ។**

ទ្រង់យាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា) ក្នុងថ្ងៃព្រហស្បតិ៍ ប្រសូតក្នុងថ្ងៃសុក្រ បានត្រាស់ជាព្រះសម្ពុទ្ធ ក្នុងថ្ងៃពុធ បរិនិព្វានក្នុងថ្ងៃអង្គារ ។

**អាសាឡ្ហបុណ្ណមោក្កន្តោ វិសាខេយេវ និក្ខមិ**

**វិសាខបុណ្ណមី សម្ពុទ្ធោ វិសាខេ បរិនិព្វុតោ**

ព្រះអង្គយាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា) ក្នុងថ្ងៃពេញបូណ៌មីខែអាសាធ ប្រសូតក្នុងថ្ងៃពេញបូណ៌មីខែវិសាខ បានត្រាស់ជាព្រះសម្ពុទ្ធ ក្នុងថ្ងៃពេញបូណ៌មី ខែពិសាខ បរិនិព្វាន ក្នុងថ្ងៃពេញបូណ៌មី ខែវិសាខ ។

**និព្វុតេ លោកនាថម្ហិ សម្ពុទ្ធេ អគ្គបុគ្គលេ**
**បដិមា ពោធិរុក្ខា ច ថូបា ច ជិនធាតុយោ**
**ចតុរាសីតិសហស្ស- ធម្មក្ខន្ធា សុទេសិតា**
**អគ្គប្បវត្តនដ្ឋានេ ឋបិតា ហោន្តិ បាណិនំ**

កាលព្រះសម្មាសម្ពុទ្ធ ជាអគ្គបុគ្គល ជាទីពឹងនៃសត្វលោក បរិនិព្វានទៅហើយ ព្រះបដិមាករផង ពោធិព្រឹក្សផង ព្រះស្តូបផង ព្រះជិនធាតុផង ព្រះធម៌ ៨ ម៉ឺន ៤ ពាន់ ធម្មក្ខន្ធ ដែលព្រះអង្គទ្រង់សម្តែង ហើយដោយប្រពៃផង ជាវត្ថុ គឺព្រះសម្មាសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក ក្នុងឋានដ៏ប្រព្រឹត្តទៅដើម្បីជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វទាំងឡាយ ។

**ឥតិ សម្មាសម្ពុទ្ធេន ទេសិតំ ឱវាទំ ចិត្តេ ឋបេត្វា សម្មាសម្ពុទ្ធេន វុត្តប្បការេន បដិបត្តិបូជាយ បូជំ ករោន្តេន លោកិយលោកុត្តរសម្បត្តិសិទ្ធំ ភាគញ្ច ឧកាស អារាធនំ ករោមិ ។**

បុគ្គលគួរតម្កល់នូវឱវាទ ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងហើយទុកក្នុងចិត្ត ហើយធ្វើការបូជាដោយបដិបត្តិបូជា ដោយនូវប្រការដែលព្រះសម្មាសម្ពុទ្ធ ត្រាស់សម្តែងហើយ គួរ

ធ្វើឱ្យសម្រេចនូវសម្បត្តិជាលោកិយៈ និងលោកុត្តរៈ ខ្ញុំសូមគោរព អារាធនាទុកដោយប្រការដូច្នេះ ។

**ឱកាស សិរីសក្យមុនិសព្វញ្ញុពុទ្ធស្ស ពលវប្បច្ចូស-សមយេ កុសិនារាយ យមកសាលានមន្តរេ អមុម្ហិ សប្បសំវច្ឆរេ គិម្ហឧតុម្ហិ វិសាខមាសេ សុក្កបក្ខេ បណ្ណរសិយា តិថិយំ ភុម្មវារេ ភុម្មយាមេ អនុរាធ-នក្ខត្តទិវសេ បរិនិព្វានំ អហោសិ អនុបាទិសេសាយនិព្វានធាតុយា ។**

ខ្ញុំសូមគោរព សម្តេចព្រះសិរីសក្យមុនីសព្វញ្ញុពុទ្ធ ជាម្ចាស់ ទ្រង់បរិនិព្វានហើយ ដោយអនុបាទិសេសនិព្វាន ធាតុក្នុងចន្លោះដើមសាលព្រឹក្សទាំងគូ ជិតក្រុងកុសិនារា ក្នុងបច្ចូសសម័យដ៏មានកម្លាំង ក្នុងថ្ងៃនៃនក្ខត្តឫក្សឈ្មោះ អនុរាធាក្នុងថ្ងៃអង្គារយាមអង្គារ ជាតិថីពេញបូណ៌មីខាងខ្នើតខែវិសាខក្នុងគិម្ហរដូវឆ្នាំម្សាញ់ឯណោះហោង ។

( ពីនេះទៅត្រូវបកសករាជប្រាប់ថ្ងៃខែឆ្នាំ ដែលកន្លងហើយ និងបច្ចុប្បន្ន និងអនាគតជរាបដល់ចប់ )

**បច្ឆិមពុទ្ធវចនៈ**

**យោ វោ អានន្ទ មយា ធម្មោ ច**

**វិនយោ ច ទេសិតោ បញ្ញត្តោ**

ម្នាលអានន្ទ សភាវៈឯណា គឺព្រះធម៌ក្តី ព្រះវិន័យក្តី ដែលតថាគតបានសម្តែងហើយ បានបញ្ញត្តហើយដល់អ្នកទាំងឡាយ ។

**សោ វោ មមច្ចយេន សត្ថា**

សភាវៈគឺព្រះធម៌ និងព្រះវិន័យនោះ លុះអំណើះតអំពីតថាគតទៅហើយ នឹងបានជាគ្រូ ប្រៀនប្រដៅនូវអ្នកទាំងឡាយ ។

**អហំ ឯកកោវ បរិនិព្វាយិស្សាមិ**

តថាគតជាព្រះពុទ្ធមួយអង្គឯងពិត នឹងបរិនិព្វានទៅ ។

**អហញ្ច បនិទានិ ឯកកោវ ឱវទាមិ អនុសាសេមិ**

តែថាឥឡូវនេះ តថាគតជាព្រះពុទ្ធមួយព្រះអង្គឯងពិត តែងទូន្មានប្រៀនប្រដៅនូវអ្នកទាំងឡាយ ។

**មយិ បរិនិព្វុតេ**

កាលបើតថាគតបរិនិព្វានទៅហើយ

**ឥមានិ ចតុរាសីតិធម្មក្ខន្ធសហស្សានិ**
**តុម្ហេ ឱវទិស្សន្តិ អនុសាសិស្សន្តិ**

ព្រះធម្មក្ខន្ធ ៨ ម៉ឺន ៤ ពាន់នេះ នឹងទូន្មានប្រៀនប្រដៅនូវអ្នកទាំងឡាយ ជាខាងក្រោយ ។

**យោ ភោចិ អានន្ទ ភិក្ខុ វា ភិក្ខុនី វា ឧបាសកោ វា ឧបាសិកា វា ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិ បដិបន្នោ អនុធម្មចារី**

ម្នាលអានន្ទ បុគ្គលឯណាមួយ គឺភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិធម៌វិន័យ តាមសម គួរដល់ធម៌វិន័យ ជាអ្នកប្រតិបត្តិដោយសេចក្តីគោរពកោត ក្រែងដល់ធម៌វិន័យ ប្រព្រឹត្តតាមធម៌ វិន័យជាប្រក្រតី ។

**សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ បដិបត្តិបូជាយ**

បុគ្គលទាំងអស់នោះឈ្មោះថា ធ្វើសក្ការៈនឹងតថាគត ធ្វើនូវសេចក្តីគោរពតថាគត រាប់អាននូវតថាគត បូជានូវតថាគត ដោយបដិបត្តិបូជា ជាបូជាយ៉ាងក្រៃលែង ។

**ឥន្ទានិ ភិក្ខវេ អាមន្តយាមិ វោ ភិក្ខវេ**

**ខយវយធម្មា សង្ខារា អប្បមាទេន សម្បាទេថាតិ**

**ឥទម្បច្ឆិមពុទ្ធវចនំ**

ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតនឹងផ្តាំនូវអ្នកទាំងឡាយ ឱ្យបានដឹងគ្រប់គ្នា នៃភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មានកិរិយាអស់ទៅ និងសាបសូន្យទៅ ជាធម្មតា ។ អ្នករាល់គ្នា ចូរញុំាងប្រយោជន៍ ឱ្យដល់ព្រមដោយអប្បមាទៈ គឺការមិនបណ្ដែតបណ្ដោយក្នុងធម៌ វិន័យ ពាក្យប្រៀនប្រដៅមានប្រមាណប៉ុណ្ណេះជាដើមនេះ ឈ្មោះថា បច្ឆិមពុទ្ធវចនៈ ជាពាក្យផ្តាំពៅបំផុតរបស់ព្រះពុទ្ធជាម្ចាស់នៃយើង ។

**ឧភិន្នមន្តរេ យំ វុត្តំ ឯតំ មជ្ឈិមពុទ្ធវចនំ**

ពាក្យប្រដៅឯណា ដែលទ្រង់ត្រាស់ពោលជាចន្លោះ នៃបឋមពុទ្ធវចនៈ និង បច្ឆិមពុទ្ធវចនៈទាំងពីរនេះ ពាក្យប្រដៅនោះ ឈ្មោះថា មជ្ឈិមពុទ្ធវចនៈ គឺពាក្យប្រដៅជាកណ្តាលរបស់ព្រះពុទ្ធជាបរមគ្រូ (នៃយើង) ។

ចប់បច្ឆិមពុទ្ធវចនៈ

## ពុទ្ធជយមង្គលគាថា

ប្រែជាពាក្យកាព្យ

**១- ពាហុំ សហស្សមភិនិម្មិតសាវុធន្តំ**

**គ្រីមេខលំ ឧទិតឃោរសសេនមារំ**

**ទានាទិធម្មវិធិនា ជិតវា មុនិន្ទោ**

**តន្តេជសា ភវតុ តេ ជយមង្គលានិ**

| | |
|---|---|
| ព្រះមុនិន្ទលោកាចារ្យ | ផ្ចាញ់ក្រុងមារចិត្តមោហន្ធ |
| និម្មិតដៃមួយពាន់ | កាន់សាស្ត្រាវុធនានា ។ |
| ជិះគ្រីមេខលជាតិ | កោញ្ជនាទខ្ទរពសុធា |
| ព្រមដោយមារសេនា | ពន្លឹកលន់កងស័ព្ទស៊ាន ។ |
| ដោយធម្មពិធី | ទានបារមីជាប្រធាន |
| ក្រុងមារចាញ់ទ្រង់ញាណ | ប្រណម្យកាយថ្វាយវន្ទា ។ |
| វីជយមង្គល | ចូរមានដល់អ្នករាល់គ្នា |
| ដោយតេជះជយា | ព្រះឈ្នះមារគ្រានោះហោង ។ |

**២- មារាតិរេកមភិយុជ្ឈិតសព្វរត្តឹ**

**ឃោរម្បនាឡវកមក្ខមថទ្ធយក្ខំ**

**ខន្តី សុទន្តវិធិនា ជិតវា មុនិន្ទោ**

**តន្តេជសា ភវតុ តេ ជយមង្គលានិ**

ព្រះមុនិន្ទពិននាយកៈ ផ្ចាញ់អាឡវកយក្សឃោរឃៅ
រឹងរូសមិនតាំងនៅ ក្នុងខន្តីគុណសត្យា ។
រហូតអស់រាត្រី ព្រះជិនស្រីទ្រង់យុទ្ធនា
ក្រៃលែងក្រុងមារា ក្នុងបឋមសម្ពោធិ ។
ដោយព្រះពិធីញាណ ទ្រង់ទូន្មានដោយខន្តី
ញុំាងចិត្តអសុរី ឱ្យបង់ព្យសនីចុះវន្ទា ។
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ព្រះឈ្នះអាឡវកយក្សហោង ។

**៣- នាឡាគិរឹ គជវរំ អតិមត្តភូតំ**

**ទាវគ្គិចក្កមសនីវ សុទារុណន្តំ**

**មេត្តម្ពុសេកវិធិនា ជិតវា មុនិន្ទោ**

**តន្តេជសា ភវតុ តេ ជយមង្គលានិ ។**

ព្រះមុនិន្ទពិនជិនស្រី ផ្ចាញ់ដំរីឈ្មោះនាឡា
គិរីវរគជា ដ៏ហានក្លាចុះប្រេងព្រេច ។

សាហាវឆាវឆេះក្រៃ ដូចភ្លើងព្រៃឆេះកំទេច
មុតដូចចក្រក្រុតពេជ្រ ខ្លាំងដូចកម្ទអសនី ។
ដោយព្រះពិធីស្រេព ស្រោចទឹកអប់គឺបារមី
មេត្តាព្រះជិនស្រី ញ៉ាំងដំរីឱ្យជ្រះថ្លា ។
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ព្រះឈ្នះនាឡាគីរី ។

## ៤- ឧក្ខិត្តខគ្គមតិហត្ថសុទារុណន្តំ
## ធាវន្តិ យោជនបថង្គុលិមាលវន្តំ
## ឥទ្ធីភិសង្ខតមនោ ជិតវា មុនិន្ទោ
## តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទ្រពិនលោកត្រៃ មានព្រះទ័យធ្វើបាដិហារ្យ
ផ្ចាញ់ចោរអង្គុលិមាល មានកម្រងគឺម្រាមដៃ
នៃមនុស្សដែលគាត់កាត់ មកដោតចាត់ជាមាល័យ
អង់អាចកំណាចក្រៃ ដ៏មានដៃស្ទាត់ប្រហារ
កាន់ដាវងាគ្រវី ដេញព្រះមុនីសាស្តាចារ្យ
ចម្ងាយផ្លូវកន្តារ កណ្តាលព្រៃបីយោជនា ។

| | |
|---|---|
| វីជយមង្គល | ចូរមានដល់អ្នករាល់គ្នា |
| ដោយតេជះជយា | ព្រះឈ្នះអង្គុលិមាល ។ |

**៥-កត្វាន កដ្ឋមុទរំ ឥវ គព្ភិនីយា**
**ចិញ្ចាយ ទុដ្ឋវចនំ ជនកាយមជ្ឈេ**
**សន្តេន សោមវិធិនា ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ ។**

| | |
|---|---|
| ព្រះមុនិន្ទមានព្រះភាគ | ផ្ចាញ់ទ្រុស្តពាក្យនាងចិញ្ចា |
| អំពើធ្វើដូចជា | ស្រីមានគភ៌ចាស់ចើលពោះ ។ |
| យកឈើធ្វើជាកូន | ព័ន្ធពោះខ្លួនពោលទ្រគោះ |
| ព្រះពុទ្ធឈ្នះកាលនោះ | ដោយសមាចារពិធី ។ |
| រម្ងាប់ពាក្យចណ្ឌាល | នាកណ្ដាលជនប្រុសស្រី |
| ចិញ្ចាចាញ់បារមី | គឺសច្ចំពាក្យសត្យា ។ |
| វីជយមង្គល | ចូរមានដល់អ្នករាល់គ្នា |
| ដោយតេជះជយា | ព្រះសាស្ដាឈ្នះចិញ្ចា ។ |

**៦- សច្ចំ វិហាយមតិសច្ចកវាទកេតុំ**
**វាទាភិរោបិតមនំ អតិអន្ធភូតំ**
**បញ្ញាបទីបជលិតោ ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ ។**

ព្រះមុនិន្ទពិនអ្នកប្រាជ្ញ    រុងរឿងស្វាចដោយបញ្ញា
ផ្ចាញ់សច្ចកៈជា    និគ្រន្ថក្រៅពុទ្ធវិន័យ ។
អធ្យាស្រ័យលះបង់    ពាក្យសត្យត្រង់តាមគាប់ចៃ
សរសើរខ្លួនឯងក្រៃ    លើកកម្ពស់ដូចដងទង់ ។
បង្កើតមោហ៍ងងឹត    ដោយពោលឥតពាក្យទៀងត្រង់
ព្រះទ្រង់កំចាត់បង់    ដោយប្រទីបគឺបញ្ញា ។
វិជយមង្គល    ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា    ព្រះឈ្នះសច្ចកនិគ្រន្ថ ។

**៧- នន្ទោបនន្ទភុជគំ វិពុធំ មហិទ្ធឹ**
**បុត្តេន ថេរភុជគេន ទមាបយន្តោ**
**ឥទ្ធូបទេសវិធិនា ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ ។**

ព្រះមុនិន្ទពិនទ្រង់ញាណ ញុាំងមោគ្គល្លានមានអំណាច
ឱ្យប្លែងជានាគរាជ ទៅទូន្មានព្យសន៍ភុជង្គ ។
ឈ្មោះនន្ទោបនន្ទ ចិត្តមោហន្ធរឿងឫទ្ធិរុង
ទិដ្ឋិកាចទ្រនង់ ទ្រង់ផ្ចាញ់ដោយពិធីឈាន ។
គឺឱ្យឧបទេស ឫទ្ធិវិសេសដល់មោគ្គល្លាន
ឫទ្ធិនាគអន្តរធាន ឱនចុះចាញ់ព្រះចេស្ដា ។
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ព្រះភគវាឈ្នះនាគហោង ។

## ៨- ទុគ្គាហទិដ្ឋិភុជគេន សុទដ្ឋហត្ថំ
## ព្រហ្មំ វិសុទ្ធិ ជុតិមិទ្ធិពកាភិធានំ
## ញាណាគទេន វិធិនា ជិតវា មុនិន្ទោ
## តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទពិនគោតម ផ្ចាញ់មហាព្រហ្មឈ្មោះពកា
សំគាល់ថាអាត្មា រុងរឿងដោយគុណបរិសុទ្ធ ។
ដែកាន់អាសិរ្ពិស គឺចិត្តទ្រឹស្ដិដ៏មោះមុត
កាន់ខុសផ្លូវសម្ពុទ្ធ មិនលើកលាក់លះបង់ប្រាណ ។

ទ្រង់ឈ្នះដោយពិធី ឱសថវិសេសសម្រាន្ត
ផ្សំត្រូវគាប់សន្តាន គឺព្រះញាណប្រោសទេសនា ។
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ឈ្នះព្រហ្មាឥតមានហ្មង ។

## ៦គាថា ពុទ្ធជយមង្គលអដ្ឋគាថា

**យោ វាចនោ ទិនទិនេ សរតេ មតន្ទី**
**ហិត្វាន នេកវិវិធានិ ចុបទ្ទវានិ មោក្ខំ**
**សុខំ អធិគមេយ្យ នរោ សបញ្ញោ ។**

**យោ នរោ** ជនឯណា បកបញ្ញាប្រាសក្តីខ្ជិល
ឧស្សាហ៍សាងទានសីល ស្វូត្ររំលឹកព្រះធម៌ថ្លៃ
គាថាប្រាំបីបទ នេះកំណត់ឈ្មោះពុទ្ធជ័យ
ខំស្វូត្រសព្វ ៗ ថ្ងៃ កើតមង្គលជានិរន្តរ៍ ។
**សោ នរោ** វីជននោះ បានរំដោះរោគអាសន្ន
ឧបទ្រពអនេកលន់ មានប្រការផ្សេង ៗ ផង
នឹងដល់ធម៌ក្សេមក្សាន្ត គឺនិព្វានសុខកន្លង
លែងទុក្ខទាំងប្អូនកង ដោយពុទ្ធជ័យមង្គលនេះ ។

“ចប់ ពុទ្ធជ័យមង្គល”

# មង្គលសូត្រ

**ឯវម្មេ សុតំ** (សូត្រនេះឈ្មោះមង្គលសូត្រ) គឺខ្ញុំ (ឈ្មោះអានន្ទ) បានស្តាប់មកហើយយ៉ាងនេះថា:

**ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ** សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។

**អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ** លំដាប់នោះឯងទេវតាអង្គ ១ កាលដែលវេលារាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏ល្អ ញ៉ាំងវត្តជេតពនជុំវិញទាំងអស់ឱ្យភ្លឺស្វាងហើយ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងទីណាក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំចំពោះអង្គ ព្រះដ៏មានព្រះភាគហើយ ឈរនៅក្នុងទីដ៏សមគួរ ។

**ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ គាថាយ អជ្ឈភាសិ** កាលទេវតានោះ ឈរក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគ ដោយពាក្យជាគាថា (យ៉ាងនេះ)ថា:

**ពហូ ទេវា មនុស្សា ច មង្គលានិ អចិន្តយុំ**
**អាកង្ខមានា សោត្ថានំ ព្រូហិ មង្គលមុត្តមំ ។**

ទេវតានិងមនុស្សទាំងឡាយជាច្រើន ប្រាថ្នានូវសេចក្ដីសួស្ដី បានគិតរកនូវមង្គលទាំងឡាយ សូមព្រះអង្គទ្រង់ព្រះមេត្តា សម្ដែងប្រាប់នូវមង្គលដ៏ឧត្តម ។

(ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងតបពាក្យទេវតានោះ ដោយពុទ្ធភាសិតជាគាថាយ៉ាងនេះថា:)

**អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា**
**បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមំ ។**

កិរិយាមិនសេពគប់នូវបុគ្គលពាលទាំងឡាយ ១ កិរិយាសេពគប់ នូវបុគ្គលជាបណ្ឌិតទាំងឡាយ ១ កិរិយាបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ ១ ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម ។

**បដិរូបទេសវាសោ ច　　បុព្វេ ច កតបុញ្ញតា**
**អត្តសម្មាបណិធិ ច　　ឯតម្មង្គលមុត្តមំ ។**

កិរិយានៅក្នុងប្រទេសដ៏សមគួរ ១ ភាវៈនៃបុគ្គលបាន ធ្វើបុណ្យ ទុកហើយក្នុងកាលមុន ១ កិរិយាដំកល់ខ្លួនដោយ ប្រពៃ ១ ទាំង ៣ នេះជាមង្គលដ៏ឧត្តម ។

**ពាហុសច្ចញ្ច សិប្បញ្ច វិនយោ ច សុសិក្ខិតោ**
**សុភាសិតា ច យា វាចា ឯតម្មង្គលមុត្តមំ ។**

ភាវៈនៃបុគ្គលបានស្តាប់ បានរៀនហើយដោយច្រើន ១ សិល្បសាស្ត្រ គឺ សេចក្តីឆ្លៀវឆ្លាសក្នុងហត្ថកម្មរបស់ អ្នកបួសនិងគ្រហស្ថ ១ វិន័យដែលបុគ្គលសិក្សាដោយប្រពៃ ១ វាចាដែល បុគ្គលពោលត្រឹមត្រូវ ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

**មាតាបិតុឧបដ្ឋានំ　　បុត្តទារស្ស សង្គហោ**
**អនាកុលា ច កម្មន្តា　　ឯតម្មង្គលមុត្តមំ ។**

កិរិយាបម្រើនូវមាតា ១ កិរិយាបម្រើនូវបិតា ១ សេចក្តីសង្គ្រោះដល់បុត្រនិងភរិយា ១ ការងារទាំងឡាយ ដែលមិនច្របូកច្របល់ ១ ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។

**ទានញ្ច ធម្មចរិយា ច ញាតកានញ្ច សង្គហោ**
**អនវជ្ជានិ កម្មានិ ឯតម្មង្គលមុត្តមំ ។**

កិរិយាបរិច្ចាគទាន ១ កិរិយាប្រព្រឹត្តនូវធម៌ ១ សេចក្តីសង្គ្រោះ ដល់ញាតិទាំងឡាយ ១ ការងារទាំងឡាយដែលមិនមានទោស ១ ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។

**អារតី វិរតី បាបា មជ្ជបានា ច សញ្ញមោ**
**អប្បមាទោ ច ធម្មេសុ ឯតម្មង្គលមុត្តមំ ។**

កិរិយាមិនត្រេកអរក្នុងបាប និងកិរិយាវៀរចាកបាប ១ សេចក្តីសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង ១ សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយ ១ ទាំង ៣ នេះជាមង្គលដ៏ឧត្តម ។

**គារវោ ច និវាតោ ច សន្តុដ្ឋី ច កតញ្ញុតា**
**កាលេន ធម្មស្សវនំ ឯតម្មង្គលមុត្តមំ ។**

សេចក្តីគោរពចំពោះបុគ្គលដែលគួរគោរព ១ កិរិយាប្រព្រឹត្ត បន្ទាបនូវខ្លួន ១ សេចក្តីត្រេកអរចំពោះរបស់ដែលមាន ១ ភាវៈនៃបុគ្គល អ្នកដឹងនូវឧបការៈដែលអ្នកដទៃធ្វើហើយដល់ខ្លួន ១ កិរិយាស្តាប់នូវធម៌ តាមកាល ១ ទាំង ៥ នេះជាមង្គលដ៏ឧត្តម ។

**ខន្តិ ច សោវចស្សតា សមណានញ្ច ទស្សនំ**
**កាលេន ធម្មសាកច្ឆា ឯតម្មង្គលមុត្តមំ ។**

សេចក្តីអត់ធន់ ១ ភាវៈនៃបុគ្គលដែលគេប្រដៅបានដោយងាយ ១ កិរិយាបានឃើញបានជួបនូវសមណៈទាំងឡាយ ១ ធម្មសាកច្ឆាគឺ កិរិយាសន្ទនាទៅវិញទៅមកនូវធម៌តាមកាល ១ ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។

**តបោ ច ព្រហ្មចរិយញ្ច អរិយសច្ចាន ទស្សនំ**
**និព្វាន សច្ឆិកិរិយា ច ឯតម្មង្គលមុត្តមំ ។**

សេចក្តីព្យាយាមដុតនូវបាបធម៌ ១ កិរិយាប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ១ កិរិយាឃើញនូវអរិយសច្ចទាំងឡាយ ១ កិរិយាធ្វើឱ្យជាក់ច្បាស់នូវព្រះ និព្វាន ១ ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។

**ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ**
**អសោកំ វិរជំ ខេមំ ឯតម្មង្គលមុត្តមំ ។**

ចិត្តនៃបុគ្គលឯណា ដែលលោកធម៌ទាំងឡាយពាល់ត្រូវហើយ មិនរំភើបញាប់ញ័រ ១ មិនមានសេចក្តីសោក ១ មានធូលីគឺរាគៈទៅប្រាស ហើយ ១ ជាចិត្តក្សេមក្សាន្ត ១

ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។

**ឯតាទិសានិ កត្វាន សព្វត្ថមបរាជិតា**

**សព្វត្ថ សោត្ថឹ គច្ឆន្តិ តន្តេសំ មង្គលមុត្តមន្តិ ។**

ទេវតានិងមនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ក្នុងទីទាំងពួង តែងដល់នូវសិរីសួស្តីក្នុងទីទាំងពួង (ម្នាលទេវតាអ្នកចូរប្រកាន់ជឿថា) មង្គលទាំង ៣៨ ប្រការមាន កិរិយាមិនសេពគប់នូវបុគ្គលពាលជាដើមនោះ របស់ទេវតានិងមនុស្ស ទាំងអម្បាលនោះ ជាមង្គលដ៏ឧត្តម ។

"មង្គលសូត្រចប់"

## បរាភវសូត្រ

## បទបញ្ចាវត្ត

(ទេវតាទូលសួរព្រះសាស្តាថា)

**បរាភវន្តំ បុរិសំ　　មយំ បុច្ឆាម គោតមំ**
**ភវន្តំ បុដ្ឋុមាគម្ម　　កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ　មកសូមទូលសួរ　នូវហេតុដែលគួរ
ចម្រើនវិនាស　ប្រុសស្រីក្នុងលោ-　កសន្និវាស
ដែលនឹងវិនាស　សាបសូន្យចាកគុណ ។
ឆ្ពោះព្រះគោតម　ព្រះអង្គមានបុណ្យ　មេត្តានិមន្ត
សម្តែងឱ្យទាន　ធម្មជាតដូចម្តេច　ដែលជាប្រធាន
នាំសត្វឱ្យមាន　សេចក្តីវិនាស ។

(ព្រះសាស្តាឆ្លើយតបនឹងទេវតាថា)

**សុវិជានោ ភវំ ហោតិ　　សុវិជានោ បរាភវោ**
**ធម្មកាមោ ភវំ ហោតិ　　ធម្មទេស្សី បរាភវោ ។**

អ្នកដែលចម្រើន　គេក៏អាចស្គាល់ងាយ　អ្នកដែលអន្តរាយ
គេក៏អាចស្គាល់ពិត　អ្នកប្រាថ្នាធម៌　ល្អិតល្អក្នុងចិត្ត
ហើយខំប្រព្រឹត្ត　នឹងបានចម្រើន ។ អ្នកដែលទ្រុស្តធម៌

ស្អប់ធម៌ឥតកើន ឥតកើតចម្រើន វិនាសទៅមុខ ។

**ឥតិ ហេតំ វិជានាម បឋមោ សោ បរាភវោ**

**ទុតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង
ព្រោះហេតុដូច្នោះ ក្តីវិនាសនេះ បើរាប់សង្គ្រោះ
វិនាសនោះឈ្មោះ ទី ១ ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវ័ន្ត សូមទ្រង់និមន្ត
សម្តែងឱ្យទាន វិនាសទី ២ អ្វីជាប្រធាន
នាំសត្វឱ្យមាន សេចក្តីវិនាស ។

**អសន្តស្ស បិយា ហោន្តិ សន្តេ ន កុរុតេ បិយំ**

**អសតំ ធម្មំ រោចេតិ តំ បរាភវតោ មុខំ ។**

អ្នកដែលស្រឡាញ់ ពេញចិត្តស្នេហា តែនឹងមនុស្សណា
អសប្បុរស តែងមិនស្រឡាញ់ ពេញចិត្តទាំងអស់
នឹងអ្នកសប្បុរស មកធ្វើជាមិត្ត ។
សេចក្តីស្រឡាញ់ ពេញចិត្តគំនិត ហើយទៅគប់មិត្ត
អសប្បុរស គាប់ចិត្តក្នុងធម៌ ឬមួយរបស់
ហេតុនេះទាំងអស់ នាំឱ្យវិនាស ។

**ឥតិ ហេតំ វិជានាម ទុតិយោ សោ បរាភវោ**
**តតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង
ព្រោះហេតុដូច្នោះ ក្តីវិនាសនេះ បើរាប់សង្គ្រោះ
វិនាសនោះឈ្មោះ ទី ២ ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវ័ន្ត សូមទ្រង់និមន្ត
សម្តែងឱ្យទាន វិនាសទី ៣ អ្វីជាប្រធាន
នាំសត្វឱ្យមាន សេចក្តីវិនាស ។

**និទ្ទាសីលី សភាសីលី អនុដ្ឋាតា ច យោ នរោ**
**អលសោ កោធបញ្ញាណោ តំ បរាភវតោ មុខំ ។**

អ្នកដេកច្រើន ១ និយាយច្រើន ១ និងអ្នកឥតព្រួយ
ឥតគិតប្រឹងប្រែង អ្នកខ្ជិលច្រអូស មិនមានខ្នះខ្នែង
ខឹងច្រើនសម្តែង ឱ្យគេឃើញបាន ។
ហេតុធម៌ទាំងនោះ មិនជាកល្យាណ នាំឱ្យខកខាន
ខាតខូចប្រយោជន៍ មានជាប្រធាន តិចច្រើនដោយហោច
នាំបង់ប្រយោជន៍ ហើយឱ្យវិនាស ។

**ឥតិ ហេតំ វិជានាម តតិយោ សោ បរាភវោ**

**ចតុត្ថំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង
ព្រោះហេតុដូច្នោះ ក្តីវិនាសនេះ បើរាប់សង្គ្រោះ
វិនាសនោះឈ្មោះ ទី ៣ ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត
សម្តែងឱ្យទាន វិនាសទី ៤ អ្វីជាប្រធាន
នាំសត្វឱ្យមាន សេចក្តីវិនាស ។

**យោ មាតរំ បិតរំ វា ជិណ្ណកំ គតយោព្វនំ**
**បហុសន្តោ ន ភរតិ តំ បរាភវតោ មុខំ ។**

នរជនណា មានទ្រព្យធនធាន ហើយខ្លួនមិនបាន
ចិញ្ចឹមរក្សា មាតាបិតា ដែលចាស់ជរា
ហេតុនោះទៅជា នាំឱ្យវិនាស ។

**ឥតិ ហេតំ វិជានាម ចតុត្ថោ សោ បរាភវោ**
**បញ្ចមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង
ព្រោះហេតុដូច្នោះ ក្តីវិនាសនេះ បើរាប់សង្គ្រោះ
វិនាសនោះឈ្មោះ ទី ៤ ទាន់ហន់ ។

បពិត្រព្រះអង្គ ព្រះនាមភគវ័ន្ត សូមទ្រង់និមន្ត
សម្ដែងឱ្យទាន វិនាសទី ៥ អ្វីជាប្រធាន
នាំសត្វឱ្យមាន សេចក្ដីវិនាស ។

**យោ ព្រាហ្មណំ សមណំ វា អញ្ញំ វាបិ វនិព្វកំ**
**មុសាវាទេន វញ្ចេតិ តំ បរាភវតោ មុខំ ។**

ជនបញ្ឆោតព្រាហ្មណ៍ ឬពួកសមណៈ ពួកស្មូមឬអ្នក
ដទៃៗ ដោយមុសាវាទ ឃ្លាតពាក្យប្រពៃ
នោះប្រធាននៃ សេចក្ដីវិនាស ។

**ឥតិ ហេតំ វិជានាម បញ្ចមោ សោ បរាភវោ**
**ឆដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្ដែង វិនាសនេះឯង
ព្រោះហេតុដូច្នោះ ក្ដីវិនាសនេះ បើរាប់សង្គ្រោះ
វិនាសនោះឈ្មោះ ទី ៥ ទាន់ហន់ ។

បពិត្រព្រះអង្គ ព្រះនាមភគវ័ន្ត សូមទ្រង់និមន្ត
សម្ដែងឱ្យទាន វិនាសទី ៦ អ្វីជាប្រធាន
នាំសត្វឱ្យមាន សេចក្ដីវិនាស ។

**បហុតវិត្តោ បុរិសោ សហិរញ្ញោ សភោជនោ**

**ឯកោ ភុញ្ជតិ សាទូនិ តំ បរាភវតោ មុខំ ។**

បុរសអ្នកមាន ទ្រព្យធនធានច្រើន មាសប្រាក់ចម្រើន
និងគ្រឿងអាហារ លបលាក់របស់ ដែលឆ្ងាញ់ពិសារ
ស៊ីម្នាក់ឯងជា ប្រធានវិនាស ។

**ឥតិ ហេតំ វិជានាម ឆដ្ឋមោ សោ បរាភវោ**

**សត្តមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង
ព្រោះហេតុដូច្នោះ ក្តីវិនាសនេះ បើរាប់សង្គ្រោះ
វិនាសនោះឈ្មោះ ទី ៦ ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវ័ន្ត សូមទ្រង់និមន្ត
សម្តែងឱ្យទាន វិនាសទី ៧ អ្វីជាប្រធាន
នាំសត្វឱ្យមាន សេចក្តីវិនាស ។

**ជាតិត្ថទ្ធោ ធនត្ថទ្ធោ គោត្តត្ថទ្ធោ ច យោ នរោ**

**សញ្ញាតឹ អតិមញ្ញេតិ តំ បរាភវតោ មុខំ ។**

អ្នកដែលប្រកាន់ ជាតិទ្រព្យត្រកូល ហើយមិនប្រមូល
សាច់ញាតិសន្តាន មើលងាយញាតិខ្លួន ដោយអាងខ្លួនមាន
នោះជាប្រធាន សេចក្តីវិនាស ។

**ឥតិ ហេតំ វិជានាម សត្តមោ សោ បរាភវោ**

**អដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង

ព្រោះហេតុដូច្នោះ ក្តីវិនាសនេះ បើរាប់សង្គ្រោះ

វិនាសនោះឈ្មោះ ទី ៧ ទាន់ហន់ ។

បពិត្រព្រះអង្គ ព្រះនាមភគវ័ន្ត សូមទ្រង់និមន្ត

សម្តែងឱ្យទាន វិនាសទី ៨ អ្វីជាប្រធាន

នាំសត្វឱ្យមាន សេចក្តីវិនាស ។

**ឥត្ថីធុត្តោ សុរាធុត្តោ អក្ខធុត្តោ ច យោ នរោ**

**លទ្ធំ លទ្ធំ វិនាសេតិ តំ បរាភវតោ មុខំ ។**

ជនអ្នកប្រព្រឹត្ត ល្បែងបីប្រការ ល្បែងស្រីល្បែងស្រា

ល្បែងភ្នាល់ទាំងឡាយ ធ្វើទ្រព្យខ្លួនមាន ឱ្យអន្តរាយ

ការល្បែងទាំងឡាយ នោះនាំវិនាស ។

**ឥតិ ហេតំ វិជានាម អដ្ឋមោ សោ បរាភវោ**

**នវមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង

ព្រោះហេតុដូច្នោះ ក្តីវិនាសនេះ បើរាប់សង្គ្រោះ

វិនាសនោះឈ្មោះ ទី ៨ ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវ័ន្ត សូមទ្រង់និមន្ត
សម្ដែងឱ្យទាន វិនាសទី ៩ អ្វីជាប្រធាន
នាំសត្វឱ្យមាន សេចក្ដីវិនាស ។

**សេហិ ទារេហិ អសន្តុដ្ឋោ វេសិយាសុ បទុស្សតិ**
**ទុស្សតិ បរទារេសុ តំ បរាភវតោ មុខំ ។**

ប្រុសមិនត្រេកអរ នឹងប្រពន្ធខ្លួន ហើយទៅជាប់ជួន
នឹងស្រីពេស្យា ទ្រុស្តនឹងប្រពន្ធ កូនជននានា
ហេតុនោះទៅជា នាំឱ្យវិនាស ។

**ឥតិ ហេតំ វិជានាម នវមោ សោ បរាភវោ**
**ទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្ដែង វិនាសនេះឯង
ព្រោះហេតុដូច្នោះ ក្ដីវិនាសនេះ បើរាប់សង្គ្រោះ
វិនាសនោះឈ្មោះ ទី ៩ ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវ័ន្ត សូមទ្រង់និមន្ត
សម្ដែងឱ្យទាន វិនាសទី ១០ អ្វីជាប្រធាន
នាំសត្វឱ្យមាន សេចក្ដីវិនាស ។

**អតីតយោព្វនោ បោសោ អានេតិ តិម្ពរុត្ថនឹ**

**តស្សា តស្សា ន សុបតិ តំ បរាភវតោ មុខំ ។**

បុរសមានវ័យ ដែលចាស់ហួសពេក ហើយមានតម្រេក
ដោយក្តីតណ្ហា នាំយកស្រីក្មេង មកធ្វើភរិយា
ហេតុនោះទៅជា នាំឱ្យវិនាស ។

**ឥតិ ហេតំ វិជានាម ទសមោ សោ បរាភវោ**

**ឯកាទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង
ព្រោះហេតុដូច្នោះ ក្តីវិនាសនេះ បើរាប់សង្គ្រោះ
វិនាសនោះឈ្មោះ ទី ១០ ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវ័ន្ត សូមទ្រង់និមន្ត
សម្តែងឱ្យទាន វិនាសទី ១១ អ្វីជាប្រធាន
នាំសត្វឱ្យមាន សេចក្តីវិនាស ។

**ឥត្ថឹ សោណ្ឌឹ វិកិរណឹ បុរិសំ វាបិ តាទិសំ**

**ឥស្សរិយស្មឹ ឋបេតិ តំ បរាភវតោ មុខំ ។**

បុរសតាំងស្រី អ្នកលេងខ្ជះខ្ជាយ ឬស្រីទាំងឡាយ
តាំងបុរសនោះ ដែលជាអ្នកលេង ខ្ជះខ្ជាយដូច្នោះ
អំពើទាំងនោះ នាំឱ្យវិនាស ។

**ឥតិ ហេតំ វិជានាម ឯកាទសមោ សោ បរាភវោ**

**ទ្វាទសមំ ភគវា ព្រូហិ   កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ  បានដឹងជាក់ស្តែង  វិនាសនេះឯង
ព្រោះហេតុដូច្នោះ  ក្តីវិនាសនេះ  បើរាប់សង្គ្រោះ
វិនាសនោះឈ្មោះ  ទី ១១ ទាន់ហាន់ ។
បពិត្រព្រះអង្គ  ព្រះនាមភគវ័ន្ត  សូមទ្រង់និមន្ត
សម្តែងឱ្យទាន  វិនាសទី ១២  អ្វីជាប្រធាន
នាំសត្វឱ្យមាន  សេចក្តីវិនាស ។

**អប្បភោគោ មហាតណ្ហោ  ខត្តិយេ ជាយតេ កុលេ**
**សោ ច រជ្ជំ បត្ថយតិ   តំ បរាភវតោ មុខំ ។**

ជនណាកើតក្នុង  ត្រកូលជាក្សត្រ  អ្នកខ្សត់សម្បត្តិ
ហើយប្រាថ្នាធំ  ចង់បានជាស្តេច  សោយរាជ្យស្តុកស្តម្ភ
ហេតុនោះនឹងនាំ  ឱ្យដល់វិនាស ។

**ឯតេ បរាភវេ លោកេ   បណ្ឌិតោ សមវេក្ខិយ**
**អរិយទស្សនសម្បន្នោ   ស លោកំ ភជតេ សិវំ ។**

ជនជាបណ្ឌិត  គំនិតប្រសើរ  បានឃើញដំណើរ
នៃហេតុវិនាស  ដល់សត្វក្នុងលោ-  កសន្និវាស
គេចពីវិនាស  គប់រកចម្រើន ។

**បរាភវសុត្តំ និដ្ឋិតំ** បរាភវសូត្រ ចប់

## វិធីបវារណាបច្ច័យ ៤ ចំពោះភិក្ខុសង្ឃ

ទាយកជាម្ចាស់ទាន កាលប្រាថ្នាទុកដាក់ប្រាក់ ឬ លុយសម្រាប់បច្ច័យ ៤ ដល់ភិក្ខុរូបណាមួយ គប្បីចូលទៅរកវេយ្យាវច្ចករបស់ភិក្ខុនោះ ហើយប្រគល់ប្រាក់ ឬ លុយជាអកប្បិយវត្ថុនោះ ក្នុងដៃវេយ្យាវច្ចករ ហើយពោលពាក្យបវារណាប្រាប់ភិក្ខុនោះថា :

**"កប្បិយការកានំ ហត្ថេ ភវិស្សតិ**

**ភន្តេ តុម្ហេ បច្ចយេ បរិភុញ្ជថ"**

បពិត្រលោកម្ចាស់ដ៏ចម្រើន អកប្បិយវត្ថុនោះ (ប្រាក់ ឬលុយ)ចំនួន (..........) ខ្ញុំព្រះករុណា នឹងទុកដាក់ក្នុងដៃវេយ្យាវច្ចកររបស់លោកម្ចាស់ ឈ្មោះ (............) សូមលោកម្ចាស់ បរិភោគប្រើប្រាស់នូវបច្ច័យ ៤ តែម្យ៉ាង (ដើម្បីសម្រេចនូវបុណ្យកុសល ដល់ខ្ញុំព្រះករុណាទាំងឡាយ សូមលោកម្ចាស់ជ្រាប) ។

បើមិនអាចពោលដោយខ្លួនឯងទេ គប្បីឱ្យវេយ្យាវច្ចករនោះ បវារណាជំនួសក៏បាន ។

## បត្តិទានគាថា

ពុទ្ធសាសនិកជន ដែលបានធ្វើកុសលឯណាមួយរួចហើយ បើមានប្រាថ្នានឹងឱ្យចម្រើនផលានិសង្សដល់ខ្លួន ដ៏ច្រើនឡើងទៀតនោះ គប្បីឧទ្ទិសផ្សាយផលនៃកុសលនោះដល់សត្វទាំងឡាយ ដោយកុសលចិត្តជាបុញ្ញកិរិយាវត្ថុ ១០ យ៉ាងដែលហៅថា បត្តិទាន គឺ កិរិយាឱ្យនូវចំណែកបុណ្យដល់អ្នកដទៃ ដោយបត្តិទានគាថានេះ ដូច្នេះថា :

**យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម កាយេន**
**វាចា មនសា តិទសេ សុគតំ កតំ យេ សត្តា**
**សញ្ញិនោ អត្ថិ យេ ច សត្តា អសញ្ញិនោ កតំ**
**បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ យេ តំ**
**កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា យេ ច តត្ថ**
**ន ជានន្តិ ទេវា គន្ត្វា និវេទយុំ សព្វេ លោកម្ហិ**
**យេ សត្តា ជីវន្តាហារហេតុកា មនុញ្ញំ ភោជនំ**
**សព្វេ លភន្តុ មម ចេតសាតិ ។**

ប្រែថា **យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម** អំពើជាកុសលឯណាមួយដែលខ្ញុំគប្បីធ្វើ **កាយេន វាចា មនសា** ដោយ

ទ្វារទាំងបី គឺ កាយវាចាចិត្ត **តិធរសេ សុគតំ កតំ** អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយ ជាកុសលអាចនឹងនាំឱ្យទៅកើតក្នុងស្ថានត្រៃត្រិង្សស្ឋគ៌បាន **យេ សត្តា សញ្ញិនោ អត្ថិ** សត្វទាំងឡាយឯណា គឺមនុស្ស ឬ ទេវតា ឬព្រហ្ម ដែលជាសត្វមានសញ្ញាក្តី **យេ ច សត្តា អសញ្ញិនោ** សត្វទាំងឡាយឯណាជាអសញ្ញិសត្វ គឺសត្វដែលឥតសញ្ញាក្តី **កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុតេ** សត្វទាំងឡាយ ទាំងអស់នោះ ចូរឱ្យបាននូវចំណែកផលនៃបុណ្យហើយ ចូរសោយនូវផល នៃបុណ្យដែលខ្ញុំបានធ្វើហើយបាន ឧទ្ទិសផ្សាយទៅឱ្យនេះចុះ **យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា** បុណ្យដែលខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយ ឯណាបានដឹងច្បាស់ហើយ សត្វទាំងឡាយនោះ ចូរឱ្យបានសោយនូវផលនៃបុណ្យដែលខ្ញុំបានឧទ្ទិសឱ្យទៅនោះចុះ **យេ ច តត្ថ ន ជានន្តិ** ម្យ៉ាងទៀត បណ្តាអស់សត្វទាំងនោះ បើសត្វទាំងឡាយឯណាមិនបានដឹងនូវបុណ្យ ដែលខ្ញុំបានធ្វើហើយនោះ **ទេវា គន្ត្វា និវេទយុំ** សូមទេវតាទាំងឡាយ អញ្ជើញទៅឱ្យដំណឹងដល់សត្វទាំងឡាយនោះឱ្យបានដឹងផង ថាជនឯណោះគេបានធ្វើបុណ្យ

ហើយគេឧទ្ទិសផ្សាយផលបុណ្យនោះ មកដល់អ្នកទាំងឡាយៗ ចូរអនុមោទនា ត្រេកអរនឹងបុណ្យគេនោះចុះ **សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា** សត្វទាំងឡាយឯណាក្នុងលោកទាំងអស់ ដែលអាស្រ័យនូវអាហារ ហើយរស់នៅ **មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសា** សត្វទាំងឡាយ ទាំងអស់នោះ ចូរឱ្យបាននូវភោជនជាទីគាប់ចិត្ត ដែលសម្រេចដោយបុញ្ញឫទ្ធិ តាមចិត្តដែលខ្ញុំឧទ្ទិសផ្សាយទៅឱ្យនេះចុះ ។

## បត្តិទានគាថា

**យា ទេវតា សន្តិ វិហារវាសិនី ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ តា ធម្មទានេន ភវន្តុ បូជិតា សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ ថេរា ច មជ្ឈា នវកា ច ភិក្ខវោ សារាមិកា ទានបតី ឧបាសកា គាមា ច ទេសា និគមា ច ឥស្សរា សប្បាណភូតា សុខិតា ភវន្តុ តេ ជលាពុជា យេបិ ច អណ្ឌសម្ភវា សំសេទជាតា អថោបបាតិកា និយ្យានិកំ ធម្មវរំ បដិច្ច តេ សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ ។ ឋាតុ ចិរំ សតំ ធម្មោ ធម្មធរា**

**ច បុគ្គលា សខ្យោ ហោតុ សមគ្គោ ៦ អត្ថាយ ច ហិតាយ ច អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ ទុឡ្ហី សម្បាបុណេយ្យាម ធម្មារិយប្បវេទិតេ**

ប្រែថា : **យា ទេវតា សន្តិ វិហារវាសិនី ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ** ទេវតាទាំងឡាយឯណាមានប្រក្រតីនៅក្នុងទីវត្តជាទីនៅនៃសង្ឃ ឰដ៏ខឿនព្រះស្តូប ឰដ៏ខឿនព្រះពោធិព្រឹក្សក្នុងទីនោះៗ **តា ធម្មទានេន ភវន្តុ បូជិតា** ទេវតាទាំងឡាយនោះ ជាបុគ្គលគឺយើងទាំងឡាយ បូជាហើយដោយធម្មទាន **សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ** ចូរធ្វើនូវសួស្តីក្នុងមណ្ឌលនៃវត្តជាទីនៅនៃសង្ឃនេះ **ថេរា ច មជ្ឈា នវកា ច ភិក្ខវោ** ភិក្ខុទាំងឡាយជាថេរៈក្តី ជាកណ្តាលក្តី ទើបនឹងបួសក្តី **សារាមិកា ទានបតី ឧបាសកា** ឧបាសកនិងឧបាសិកាទាំងឡាយ ដែលជាម្ចាស់នៃទាន ព្រមទាំងអារាមិកជន គឺ ញោមវត្តក្តី, **គាមា ច ទេសា និគមា ច ឥស្សរា** ជនទាំងឡាយដែលជាអ្នកស្រុកក្តី ជាអ្នកប្រទេសក្តី ជាអ្នកនិគមក្តី ដែលជាឥស្សរៈ ជាធំក្តី **សប្បាណ-ភូតា សុខិតា ភវន្តុ តេ** សត្វទាំងឡាយនោះៗ ចូរឱ្យបានដល់នូវសេចក្តីសុខ **ជលាពុជា យេបិ ច អណ្ឌសម្ភវា សំសេទជាតា**

**អថខោបបាតិកា** មួយវិញទៀត សត្វទាំងឡាយឯណា ដែលជាជលាពុជៈ កំណើតក្តី ដែលជាអណ្ឌជៈកំណើតក្តី ដែលជាសំសេទជៈកំណើតក្តី ដែលជាឧបបាតិកៈកំណើតក្តី **និយ្យានិកំ ធម្មវរំ បដិច្ច តេ សព្វេបិ ទុក្ខស្ស ករោន្តុ សង្ខយំ** សត្វទាំងឡាយទាំងអស់នោះ កាលបើបានអាស្រ័យនូវធម៌ដ៏ប្រសើរ ជានិយ្យានិកធម៌ហើយ ចូរធ្វើនូវធម៌ជាគ្រឿងអស់ទៅនៃទុក្ខចុះ **ឋាតុ ចិរំ សតំ ធម្មោ** សូមឱ្យធម៌របស់សប្បុរសទាំងឡាយ ស្ថិតនៅអស់កាលយូរអង្វែងទៅ **ធម្មធរា ច បុគ្គលា** បុគ្គលអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ (ចូរស្ថិតនៅអស់កាលយូរ អង្វែងទៅ) **សង្ឃោ ហោតុ សមគ្គោ ច** សូមព្រះសង្ឃព្រមព្រៀងគ្នា **អត្ថាយ ច ហិតាយ ច** ដើម្បីសេចក្តីចម្រើនផង ដើម្បីសេចក្តីសម្រេចផលប្រយោជន៍ផង **អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ** សូមព្រះសទ្ធម្មរក្សានូវយើងទាំងឡាយ សូមរក្សានូវអ្នកដែលប្រព្រឹត្តធម៌ទាំងឡាយទាំងអស់ផង **វុឌ្ឍឹ សម្បាបុណេយ្យាម ធម្មារិយប្បវេទិតេ** សូមឱ្យយើងទាំងឡាយ បានដល់នូវសេចក្តីចម្រើន ក្នុងធម៌ដែលព្រះអរិយៈទាំងឡាយលោកសម្តែងហើយ ។

## ធម៌សម្រាប់សូធ្យផ្សាយមេត្តាទាំង ១០ ទិស

**១-សព្វេបុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសបូព៌ា កុំបីមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

**២-សព្វេបុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសអាគ្នេយ៍ កុំបីមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

**៣-សព្វេទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសទក្សិណ កុំបីមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

**៤-សព្វេទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសនិរតី កុំបីមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

**៥-សព្វេបច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសបស្ចឹម កុំបីមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

**៦-សព្វេបច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសពាយ័ព្យ កុំបីមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

**៧-សព្វេឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសឧត្តរ កុំបីមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

**៨-សព្វេឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសឦសាន កុំបីមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

**៩-សព្វេឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសខាងលើ កុំបីមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

**១០-សព្វេហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសខាងក្រោម កុំបីមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

**សព្វេ សត្តា អវេរា ហោន្តុ, សុខិតា ហោន្តុ, និទ្ទុក្ខា ហោន្តុ, អព្យាបជ្ឈា ហោន្តុ, អនីឃា ហោន្តុ, ទីឃាយុកា ហោន្តុ, អរោគា ហោន្តុ, សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តា នំ បរិហរន្តុ**

សត្វទាំងឡាយទាំងពួង ចូរកុំមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ចូរកុំមានទុក្ខ ចូរកុំមានព្យាបាទនឹងគ្នា ចូរឱ្យជាអ្នកឥតមានសេចក្តីទុក្ខភ័យ ចូរឱ្យមានអាយុវែង ចូរកុំឱ្យមានរោគ ចូរឱ្យបានសម្រេច ដោយសម្បត្តិទាំងឡាយ ចូររក្សាខ្លួនឱ្យបានសេចក្តីសុខចុះ ។

**ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា**
**សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ**

សត្វទាំងឡាយទាំងពួងដែលដល់ហើយ នូវសេចក្តីទុក្ខ សូមឱ្យជាសត្វបាត់សេចក្តីទុក្ខទៅ ដែលដល់ហើយ នូវភ័យ សូមឱ្យជាសត្វបាត់ភ័យទៅ ដែលដល់ហើយ នូវសេចក្តីសោក សូមឱ្យជាសត្វបាត់សេចក្តីសោកទៅ ។